**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **រិទ្ធ រតនា**

កញ្ញា **ស្រេង គីណាល់វិនរ៉ូហ្សា**

ណែនាំដោយ

លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **រិទ្ធ រតនា**

កញ្ញា **ស្រេង គីណាល់វិនរ៉ូហ្សា**

ណែនាំដោយ

លោក **ហេង បូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **រិទ្ធ រតនា** និងឈ្មោះ **ស្រេង គីឈាល់ទិនរ៉ូហ្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៣ លេខកូដថ្នាក់ L4C4 ឆ្នាំសិក្សា២០១៩-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

លោកឪពុក និងអ្នកម្តាយ ដែលជាអ្នកផ្តល់កំណើត និងជាអ្នកមានគុណដ៏ធំធេងចំពោះកូនក្នុងការចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ទំនុកបម្រុង ទូន្មានប្រៀនប្រដៅប្រកបទៅដោយព្រហ្មវិហារធម៌ តាំងពីតូចរហូតដល់ធំពេញវ័យ ទាំងកម្លាំងកាយកម្លាំងចិត្ត មិនគិតពីភាពនឿយហត់លំបាកនោះទេ និងការឧបត្ថម្ភគ្រប់បែបយ៉ាងដើម្បីឱ្យរូបយើងខ្ញុំមានឱកាស ពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាពរបស់កូន តាំងពីដើមរហូតបានបញ្ចប់ការសិក្សាដោយភាពជោគជ័យ និងមានអនាគតល្អ។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់៖**

**ឯកឧត្តម សាកលវិទ្យាធិការ** ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំយ៉ាងយកចិត្តទុកដាក់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត នូវគ្រប់មុខវិជ្ជា ដែលជាទៀនបំភ្លឺផ្លូវដល់រូបយើងខ្ញុំនាពេលអនាគត។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូ **ហេង មូរ៉ា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ការបង្ហាត់បង្រៀន ព្រមទាំងបានដឹកនាំរូបយើងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ចាប់តាំងពីពេលចាប់ផ្តើមដំបូងរហូតដល់ពេលបញ្ចប់យ៉ាងជោគជ័យ។ លោកគ្រូថែមទាំងបានផ្តល់ជាមតិយោបល់ល្អៗ ហើយបានណែនាំដល់រូបយើងខ្ញុំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ព្រមទាំងបានជម្រុញលើកទឹកចិត្ត ត្រួតពិនិត្យ កែលម្អនូវសារណារបស់យើងខ្ញុំជាច្រើនលើកជាច្រើនសារ និងបានពន្យល់បន្ថែមនូវចំណុចខ្វះខាតរបស់យើងខ្ញុំ ព្រមទាំងប្រគល់ឯកសារជាច្រើនដែលសុទ្ធសឹងតែជាឯកសារដ៏មានតម្លៃ និងសារៈប្រយោជន៍ក្នុងការស្រាវជ្រាវអំពីប្រធានបទសារណាមួយនេះ។

សូមអរគុណដល់លោកតា លោកយាយ បងប្អូន ព្រមទាំងសិស្សច្បង និងមិត្តភក្តិទាំងអស់ដែលបានផ្តល់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងជួយផ្តល់មតិយោបល់ល្អៗដល់រូបយើងខ្ញុំក្នុងការសិក្សាពេលកន្លងមក។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំសូមធ្វើការលំអោនកាយលើកដៃប្រណមបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយ សូមប្រោះព្រំ សព្វសាធុការពរ សិរីសួស្តី ជ័យមង្គល សូមប្រសិទ្ធពរបវរមហាប្រសើរជូនដល់មាតាបិតា បងប្អូន ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ លោកសាស្ត្រាចារ្យណែនាំ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ៤ឆ្នាំ កន្លងផុតទៅ យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំបង្រៀនយ៉ាងយកចិត្តទុកដាក់ ចាប់តាំងពីឆ្នាំមូលដ្ឋានរហូតដល់ឆ្នាំចុងក្រោយ។ តាមរយៈការសិក្សាកន្លងមកនេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី **"ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ"** ដែលជាផ្នែកមួយនៃមុខវិជ្ជានីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សា និងដើម្បីទុកតម្កល់ជាស្នាដៃមួយសម្រាប់ឱ្យមិត្តនិស្សិត អ្នកស្រាវជ្រាវ និងសាធារណៈជនគ្រប់មជ្ឈដ្ឋាន ក្នុងការសិក្សាស្រាវជ្រាវបន្ថែមដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត។

លើសពីនេះទៅទៀត ក្នុងការសរសេរសារណានូវប្រធានបទនេះ យើងខ្ញុំមានគោលបំណងចង់បង្ហាញអំពីនីតិវិធីមួយក្នុងចំណោមនីតិវិធីដែលមានក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងជាពិសេសជានីតិវិធីមួយ ដែលសិស្សនិស្សិតជំនាន់ក្រោយគួរតែយល់ដឹង ដើម្បីជាផលប្រយោជន៍ នៅពេលដែលជួបប្រទះភាពជាក់ស្តែងនូវបញ្ហានេះ និងដោះស្រាយវិវាទដែលកើតមានក្នុងកាលៈទេសៈ ឬស្ថានភាពមួយដែលបារម្ភថានឹងមានការខូចខាត ឬខូចប្រយោជន៍អ្វីមួយនាពេលអនាគតដែលមិនអាចអនុវត្តបានជាដើម។ ម៉្យាងវិញទៀត ក្នុងការបកស្រាយប្រធានបទមួយនេះ យើងខ្ញុំបានបកស្រាយដោយផ្អែក និងយោងតាមមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តនានា ព្រមទាំងភ្ជាប់មកជាមួយឧទាហរណ៍យកមកបញ្ជាក់ឱ្យការបកស្រាយរបស់យើងខ្ញុំឱ្យកាន់តែមានភាពស៊ីជម្រៅ និងបានក្បោះក្បាយបន្ថែមទៀត។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាការបកស្រាយ និងចងក្រងនូវសារណាមួយនេះ ដែលជាស្នាដៃមួយរបស់យើងខ្ញុំ អាចជាជំនួយដល់មិត្តនិស្សិតជំនាន់ក្រោយ មិត្តអ្នកអាន និងអ្នកស្រាវជ្រាវនានា ក្នុងការយល់ដឹងបន្ថែមពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនេះ ទោះបីជាក្នុងកម្រិតណាមួយក៏ដោយ។

យ៉ាងណាមិញ យើងខ្ញុំបានខិតខំប្រឹងប្រែងចងក្រងអត្ថបទនេះឡើងយ៉ាងអស់ពីសមត្ថភាពរបស់យើងខ្ញុំ ដូច្នេះ ក្នុងករណីដែលមានកំហុសអចេតនាណាមួយបានកើតមានឡើង ដូចជាការប្រើពាក្យពេចន៍មានភាពខុសឆ្គងឃ្លោងឃ្លា និងប្រយោគណាមួយដែលមានចន្លោះខ្វះខាត សូមមិត្តនិស្សិតជំនាន់ក្រោយ មិត្តអ្នកអានធ្វើការកែលម្អដើម្បីស្ថាបនា និងកែតម្រូវនូវចំណុចខុសឆ្គងនោះ ដើម្បីទុកជាមេរៀនក្នុងការសិក្សាបន្តទៅមុខទៀត។ ជាពិសេស យើងខ្ញុំសង្ឃឹមថានឹងទទួលបានការយោគយល់ អធ្យាស្រ័យ ពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិត មិត្តអ្នកអាន ដោយក្តីអនុគ្រោះ និងក្តីសោមនស្សរីករាយ ដើម្បីឱ្យសារណារបស់យើងខ្ញុំទាំងពីរកាន់តែមានភាពប្រសើរឡើងមួយកម្រិតទៀត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

**ផ្នែកទី១. គោលបំណងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**....... ៥

**កថាភាគទី១. លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន**........................ ៥

១.១. សិទ្ធិទាមទារដែលត្រូវរក្សាការពារ ........................ ៥

១.២. សិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌ ឬពេលកំណត់........................ ៦

១.៣. បណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលពាក់ព័ន្ធ........................ ៧

**កថាភាគទី២. ភាពចាំបាច់នៃការរក្សាការពារ** ........................ ៧

**ផ្នែកទី២. រចនាសម្ព័ន្ធនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន**........................ ៨

**កថាភាគទី១. ដំណាក់កាលនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន** ........................ ៨

**កថាភាគទី២. លក្ខណៈពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន**........................ ៨

២.១. លក្ខណៈបណ្តោះអាសន្ន ........................ ៨

២.២. លក្ខណៈបន្ទាន់បង្ហំ........................ ៩

២.៣. លក្ខណៈបន្ទាប់បន្សំ........................ ៩

២.៤. លក្ខណៈសម្ងាត់........................ ១១

**កថាភាគទី៣. កម្មវត្ថុ និងភាគីនៃការរឹបអូសជាបណ្តោះអាសន្ន**........................ ១២

៣.១. កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន........................ ១២

៣.២. ភាគីនៃការរឹបអូសជាបណ្តោះអាសន្ន........................ ១៣

## ជំពូកទី២

## នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

**ផ្នែកទី១. នីតិវិធីនៃការសម្រេចសេចក្តី (ការសម្រេចរឹបអូសជាបណ្តោះអាសន្ន)**....... **១៥**

**កថាភាគទី១. សមត្ថកិច្ចតុលាការ** ........................................................................................ **១៥**

១.១. សមត្ថកិច្ចតាមបណ្តឹងអង្គសេចក្តី........................................................................................ **១៥**

១.២. សមត្ថកិច្ចតាមវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន.............................................. **១៦**

**កថាភាគទី២. ការដាក់ពាក្យសុំ** ........................................................................................**១៧**

២.១. អត្តសញ្ញាណគូភាគី និងអ្នកតំណាង..................................................................................**១៧**

២.២. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ........................................ **១៨**

២.៣. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ................................................ **១៨**

២.៤. ភាពចាំបាច់នៃការរក្សាការពារ .......................................................................................... **១៩**

**កថាភាគទី៣. ឯកសារដែលត្រូវភ្ជាប់ជាមួយ** .............................................................**២០**

៣.១. ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង.................................................................................**២០**

៣.១.១. ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ.............**២១**

៣.១.២. ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ ........................................**២១**

៣.២. ឯកសារសម្រាប់បញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ............................................**២២**

៣.៣. ឯកសារសម្រាប់បញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ...................................**២៣**

៣.៤. ឯកសារផ្សេងៗ......................................................................................................................**២៣**

**កថាភាគទី៤. សោហ៊ុយ** ...................................................................................................... **២៤**

៤.១. ពន្ធដាក់ពាក្យសុំ ................................................................................................................ **២៤**

៤.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........................................................................................ **២៤**

៤.៣. បន្ទុកនៃប្រាក់ប្រដាប់ក្តី........................................................................................................ **២៤**

**កថាភាគទី៥. ការពិនិត្យទៅលើពាក្យសុំដីកាសម្រេច** ........................................................ **២៥**

**កថាភាគទី៦. ប្រាតិភោគ និងប្រាក់រំដោះ**.......................................................................**២៦**

៦.១. ប្រាតិភោគ...........................................................................................................................**២៦**

៦.១.១. គោលបំណងនៃប្រាតិភោគ........................................................................................ ២៦
៦.១.២. ចំនួននៃប្រាតិភោគ ............................................................................................... ២៧
៦.១.៣. វិធីនៃការដាក់ប្រាតិភោគ......................................................................................... ២៨
៦.១.៤. អំឡុងពេលនៃការដាក់ប្រាតិភោគ ............................................................................. ២៩
៦.២. ប្រាក់រំដោះ................................................................................................................... ២៩
៦.២.១. គោលបំណងនៃប្រាក់រំដោះ ..................................................................................... ២៩
៦.២.២. ចំនួននៃប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ........................................................ ៣០
**កថាភាគទី៧. នីតិវិធីនៃការពិនិត្យរឿងក្តី និងការទាញហេតុផលដោយផ្ទាល់មាត់ ៣០**
៧.១. នីតិវិធីនៃការពិនិត្យរឿងក្តី ........................................................................................... ៣០
៧.១.១. ការពិនិត្យភស្តុតាងជាឯកសារ .................................................................................. ៣០
៧.១.២. ការសាកសួរម្ចាស់បំណុល........................................................................................ ៣០
៧.១.៣. ការសាកសួរកូនបំណុល........................................................................................... ៣១
៧.២. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ...................................................................... ៣២
**កថាភាគទី៨. ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ..៣២**
**កថាភាគទី៩. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ.៣២**
៩.១. ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន .......................................................................... ៣៣
៩.២. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្តឹង ................................................................ ៣៣
៩.៣. វិធីនៃការបញ្ជូន............................................................................................................ ៣៤
៩.៣.១. ការបញ្ជូនដោយការប្រគល់ ...................................................................................... ៣៤
៩.៣.២. ការបញ្ជូនដោយជួបប្រទះ......................................................................................... ៣៤
៩.៣.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច........................................................................................ ៣៤
៩.៣.៤. ការបញ្ជូនដោយទុកចោល ........................................................................................ ៣៥
៩.៣.៥. ការបញ្ជូនទៅបរទេស ............................................................................................. ៣៥

៩.៣.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ............................................................ ៣៥

**ផ្នែកទី២. នីតិវិធីនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**........................ ៣៦

**កថាភាគទី១. សមត្ថកិច្ចអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ...................... ៣៦

**កថាភាគទី២. ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ................ ៣៧

២.១. ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ................................................ ៣៧

២.២. ឯកសារដែលត្រូវភ្ជាប់ជាមួយ........................................................................................ ៣៧

**កថាភាគទី៣. ការពិនិត្យមើលពាក្យសុំ**........................................................................ ៣៨

**កថាភាគទី៤. ការពិនិត្យលក្ខខណ្ឌចាំបាច់នៃការអនុវត្តដីកាសម្រេច**........................... ៣៨

៤.១. លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ................................................ ៣៨

៤.២. អំឡុងពេល ....................................................................................................... ៣៩

៤.៣. ផ្សេងៗ ............................................................................................................ ៣៩

**កថាភាគទី៥.វិធីអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ** ៣៩

៥.១. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី.......................................... ៤០

៥.២. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី............................. ៤១

**កថាភាគទី៦. ការផ្អាក និងការលុបចោលនូវការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន** ................................................................................................ ៤២

៦.១. ការផ្អាកការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ........................................................... ៤៣

៦.១.១. ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន.............................................. ៤៣

៦.១.២. មូលហេតុដែលនាំឱ្យមានការផ្អាកការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ...... ៤៣

៦.២. ការលុបចោលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន.......................................... ៤៥

៦.២.១. ខ្លឹមសារនៃការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ...................................... ៤៥

៦.២.២. មូលហេតុដែលនាំឱ្យលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន.............................. ៤៦

**កថាភាគទី៧. ការលុបចោលប្រាតិភោគ**........................................................................ ៤៦

**កថាភាគទី៨. ការផ្អាកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន......៤៧**

**ផ្នែកទី៣. បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ... ៤៨**

**កថាភាគទី១. ការតវ៉ាចំពោះដីកាសម្រេច ...................................................... ៤៨**

១.១. អត្ថន័យនៃការដាក់ពាក្យសុំតវ៉ា ................................................................ ៤៨

១.២. ការធ្វើពាក្យសុំតវ៉ា ................................................................................. ៤៨

១.៣. ការវិនិច្ឆ័យលើពាក្យសុំតវ៉ា ........................................................................ ៤៩

**កថាភាគទី២. ការលុបចោលដីកាសម្រេច ..................................................... ៥០**

២.១. ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍ .................... ៥១

២.២. ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព ................................................. ៥១

**កថាភាគទី៣. បណ្តឹងជំទាស់ ..................................................................... ៥២**

៣.១. អត្ថន័យនៃបណ្តឹងជំទាស់ ........................................................................ ៥២

៣.២. ការធ្វើបណ្តឹងជំទាស់ ................................................................................ ៥៣

៣.២.១. តុលាការមានសមត្ថកិច្ច ..................................................................... ៥៣

៣.២.២. ដីកាសម្រេច និងអំឡុងពេលដែលអាចប្តឹងជំទាស់ ........................................ ៥៣

៣.៣. របៀបប្តឹងជំទាស់ .................................................................................. ៥៣

៣.៤. អានុភាពនៃបណ្តឹងជំទាស់ ........................................................................ ៥៤

៣.៥. ការវិនិច្ឆ័យលើបណ្តឹងជំទាស់ ..................................................................... ៥៥

**កថាភាគទី៤. ការសុំឱ្យជំនុំជម្រះសាជាថ្មី ..................................................... ៥៦**

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

**ផ្នែកទី១. បញ្ហាប្រឈម ............................................................................ ៥៨**

**កថាភាគទី១. បញ្ហាប្រឈមក្នុងនីតិវិធីនៃការសម្រេចសេចក្តី ................................ ៥៨**

១.១. ទិដ្ឋភាពជាក់ស្តែងរបស់ចៅក្រមក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ................ ៥៨

១.១.១. ការយល់ដឹងរបស់ចៅក្រមនៅមានកម្រិត ..... ៥៨
១.១.២. ភាពយឺតយ៉ាវនៃនីតិវិធី ..... ៥៩
១.១.៣. ការធ្វេសប្រហែសក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ..... ៥៩
១.២. សកម្មភាពរបស់ម្ចាស់បំណុលក្នុងនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ..... ៦០
**កថាភាគទី២. បញ្ហាប្រឈមក្នុងនីតិវិធីនៃការអនុវត្តដីកាសម្រេច ..... ៦០**
២.១. ទិដ្ឋភាពជាក់ស្ដែងរបស់មន្ត្រីអនុវត្ត (ក្រឡាបញ្ជី) ..... ៦០
២.១.១. ភាពយឺតយ៉ាវនៃនីតិវិធី ..... ៦០
២.១.២. ការបញ្ជូនលិខិតផ្អាកផ្ដាក់ឱ្យចុះបញ្ជី ..... ៦១
២.២. ទិដ្ឋភាពជាក់ស្ដែងរបស់មន្ត្រីចុះបញ្ជីផ្អាកផ្ដាក់ (មន្ត្រីសុរិយោដី) ..... ៦១
**កថាភាគទី៣. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល ..... ៦២**
៣.១. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់តតិយជន ..... ៦២
៣.២. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ..... ៦៣
**កថាភាគទី៤. បន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល ..... ៦៣**
៤.១. បន្ទុកសោហ៊ុយសម្រាប់សេវាផ្នែកច្បាប់ និងសោហ៊ុយផ្សេងៗ ..... ៦៣
៤.២. បន្ទុកសោហ៊ុយក្នុងការស្វែងរកអត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុល ..... ៦៤
៤.២.១. អចលនវត្ថុដែលបានចុះបញ្ជី ..... ៦៤
៤.២.២. អចលនវត្ថុដែលមិនបានចុះបញ្ជី ..... ៦៤
៤.៣. សោហ៊ុយអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមិនបានចុះបញ្ជី ..... ៦៥
**ផ្នែកទី២. ដំណោះស្រាយ ..... ៦៥**
**កថាភាគទី១. ដំណោះស្រាយក្នុងនីតិវិធីនៃការសម្រេចសេចក្ដី ..... ៦៥**
១.១. ដំណោះស្រាយនៃបញ្ហាប្រឈមពាក់ព័ន្ធនឹងចៅក្រម ..... ៦៥
១.១.១. ការពង្រឹងចំណេះដឹងតាមរយៈការបណ្ដុះបណ្ដាលបន្ត ..... ៦៥

១.១.២. ការពន្លឿននីតិវិធីនៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ................. ៦៥
១.១.៣. ទណ្ឌកម្មវិន័យ ........................................................................................ ៦៦
១.២. ដំណោះស្រាយនៃបញ្ហាប្រឈមពាក់ព័ន្ធនឹងម្ចាស់បំណុល ........................................ ៦៦
**កថាភាគទី២. ដំណោះស្រាយបញ្ហាប្រឈមក្នុងនីតិវិធីនៃការអនុវត្តដីកាសម្រេច ៦៧**
២.១. ការពន្លឿននីតិវិធីរបស់មន្ត្រីអនុវត្ត (ក្រឡាបញ្ជី) ................................................ ៦៧
២.១.១. ឆន្ទៈក្នុងការអនុវត្តច្បាប់ ........................................................................ ៦៧
២.១.២. ការពង្រឹងនីតិវិធីបញ្ជូនលិខិតផ្អកផ្ដាក់ឱ្យចុះបញ្ជីកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័ស .... ៦៧
២.២. ការពង្រឹងសមត្ថភាពរបស់មន្ត្រីចុះបញ្ជីផ្អកផ្ដាក់ (មន្ត្រីសុរិយោដី) ............................ ៦៨
**កថាភាគទី៣. ដំណោះស្រាយចំពោះការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលមិនមែនជារបស់កូនបំណុល ........................................................ ៦៨**
៣.១. អចលនវត្ថុដែលជាកម្មសិទ្ធិរបស់តតិយជន ........................................................ ៦៨
៣.២. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ .......................................................... ៦៨
**កថាភាគទី៤. បន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល ............................................... ៦៩**
៤.១. បង្កើតយន្តការក្នុងការកាត់បន្ថយចំណាយ និងការផ្ដល់សេវាប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃ ..... ៦៩
៤.២. បង្កើតយន្តការគ្រប់គ្រងទិន្នន័យរបស់អចលនវត្ថុ ................................................ ៦៩
៤.២.១. យន្តការគ្រប់គ្រងទិន្នន័យលើអចលនវត្ថុដែលបានចុះបញ្ជី ...................................... ៦៩
៤.២.២. យន្តការគ្រប់គ្រងទិន្នន័យលើអចលនវត្ថុដែលមិនបានចុះបញ្ជី ................................. ៦៩
៤.៣. សោហ៊ុយអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជី ............... ៧០
**សេចក្ដីសន្និដ្ឋាន ........................................................................................ ៧១**
**អនុសាសន៍ .............................................................................................. ៧៤**
**សន្ទានុក្រម**
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមមួយតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយទំនាក់ទំនងទាំងនោះអាចបង្កើតទៅជាចំណងគតិយុត្តជាច្រើន ហើយក្នុងករណីដែលភាគី ឬបុគ្គលណាមួយមិនបានអនុវត្តកាតព្វកិច្ចទាំងនោះនឹងបង្កើតឱ្យមានវិវាទរវាងសិទ្ធិ និងកាតព្វកិច្ចកើតមានឡើង។ ជាមួយគ្នាផងដែរ ក្នុងការដោះស្រាយវិវាទខាងលើនេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីយន្តការដោះស្រាយវិវាទ ក៏ដូចជាយន្តការអនុវត្តសិទ្ធិតាមផ្លូវតុលាការ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងសង្គម។

នៅក្នុងរឿងក្តីរដ្ឋប្បវេណីអ្នកដែលមានសិទ្ធិហៅថា **ម្ចាស់បំណុល** ចំណែកឯអ្នកដែលមានកាតព្វកិច្ចហៅថា **កូនបំណុល**។ ទម្រាំមានការសម្រេចជាស្ថាពរ ម្ចាស់បំណុល ត្រូវប្រើពេលវេលាយូរ ដែលនាំឱ្យសិទ្ធិត្រូវអនុវត្តនាពេលអនាគតអាចនឹងត្រូវពិបាកក្នុងការអនុវត្ត ឬពេលខ្លះអាចនឹងអនុវត្តមិនបានថែមទៀត ដោយសារការប្រែប្រួលនូវស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងអំឡុងពេលនៃនីតិវិធីបណ្តឹង។ ហេតុនេះ ដើម្បីសម្របសម្រួលស្ថានភាពនេះ ក៏ដូចជាការរំពឹងរបស់ម្ចាស់បំណុលថាក្រោយពេលឈ្នះក្តីហើយ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនបានដោយរលូន។ ដូច្នេះ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តដោយបង្ខំនាពេលអនាគត គឺត្រូវការជាចាំបាច់នូវការចាត់ចែងរក្សាការពារ។

របបរក្សាការពារ ជានីតិវិធីមួយមានលក្ខណៈបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលរងចាំសាលក្រមចុងក្រោយដែលត្រូវអនុវត្ត។ នៅពេលមានបណ្តឹងលើអង្គសេចក្តីដែលត្រូវចាត់ការនោះ គឺត្រូវចំណាយពេលវេលាវែងដែលមិនអាចកំណត់បាន នៅក្នុងអំឡុងពេលនីតិវិធីអង្គសេចក្តីនេះ ពេលខ្លះម្ចាស់បំណុលអាចបាត់បង់នូវផលប្រយោជន៍ ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុលដែលលាក់ទុកទ្រព្យសម្បត្តិ តាមរយៈការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំ ប្រទានកម្ម សន្តតិកម្ម ហ៊ីប៉ូតែក ជាដើម ដែលធ្វើឱ្យម្ចាស់បំណុលជួបការលំបាកក្នុងការអនុវត្តសិទ្ធិនៅពេលឈ្នះក្តី។ ហេតុដូច្នេះ បានជាក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានគិតគូរដល់ផលលំបាកនេះ ហើយក៏បានកំណត់ជាក្បួនច្បាប់ ក្នុងការធ្វើការចាត់ចែងការរក្សាការពារក្នុងគោលបំណងការពារផលប្រយោជន៍របស់ម្ចាស់បំណុលរហូតដល់នីតិវិធីអង្គសេចក្តីត្រូវបានបញ្ចប់។

ការចាត់ចែងរក្សាការពារ ជាវិធានការមួយដែលមានលក្ខណៈបន្ទាន់បង្ខំ ហើយត្រូវបានធ្វើឡើង ដោយមានលក្ខណៈសម្ងាត់ មុនពេលចេញដីកាសម្រេចរក្សាការពារនេះ ហើយជាយន្តការការពារជាបឋមចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល។ ការចាត់ចែងរក្សាការពារអាចត្រូវបានចេញមុននីតិវិធីអង្គសេចក្តីក៏បាន ឬក្នុងអំឡុងពេលនីតិវិធីអង្គសេចក្តីក៏បាន។ ការចាត់ចែងរក្សាការពារ ត្រូវបានបែងចែងជា ៣ (បី) ប្រភេទរួមមាន

ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។ ប៉ុន្តែនៅក្នុងអត្ថបទសារណានេះ នឹងជ្រើសរើសយកតែ **"ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ"** មកសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ សូមបញ្ជាក់ប្រាប់ថា កម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវរាប់បញ្ចូលទាំងអចលនវត្ថុដែលបានចុះបញ្ជី និងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី។ ម្យ៉ាងវិញទៀត អត្ថបទសារណានេះ ត្រូវបានសិក្សាចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ព្រមទាំងបង្ហាញអំពីនីតិវិធីលម្អិតដែលម្ចាស់បំណុលត្រូវប្រតិបត្តិតាម ដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។ ទន្ទឹមនឹងនេះ អត្ថបទសារណានេះ នឹងឆ្លើយតបចំពោះបញ្ហាប្រឈមមួយចំនួនដែលត្រូវជួបប្រទះក្នុងពេលអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ និងដំណោះស្រាយផ្សេងៗ ដើម្បីជៀសវាងពីការបាត់បង់ផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុលដោយសារបញ្ហាទាំងអស់នោះ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវបានប្រើប្រាស់តែក្នុងករណីដែលសិទ្ធិទាមទារមានគោលបំណងឱ្យសងជាប្រាក់តែប៉ុណ្ណោះ។ ក្នុងករណីដែលម្ចាស់បំណុលមានសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ម្ចាស់បំណុលអាចដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល ក្នុងគោលបំណងដើម្បីការពារសិទ្ធិលើបំណុលរបស់ខ្លួន ជៀសវាងកូនបំណុលគេចវេស ឬ ព្យាយាមបង្វែរអចលនវត្ថុរបស់ខ្លួនពីការទទួលខុសត្រូវលើសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលមុនពេលដែលមានសេចក្ដីសម្រេចជាស្ថាពរលើបណ្ដឹងអង្គសេចក្ដី។ ដោយហេតុថា នីតិវិធីនៃបណ្ដឹងអង្គសេចក្ដីជានីតិវិធីដែលត្រូវចំណាយពេលយូរ និងមានភាពស្មុគស្មាញ ដើម្បីទទួលបានសេចក្ដីសម្រេចស្ថាពរលើបណ្ដឹងអង្គសេចក្ដី។

ដើម្បីឆ្លើយតបនឹងប្រធានបទ **"ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ"** ខាងលើ អត្ថបទសារណានេះនឹងបង្ហាញអំពីចម្លើយគតិយុត្ត ដែលពាក់ព័ន្ធនឹងសំណួរគតិយុត្តដូចតទៅ៖ តើការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមានខ្លឹមសារយ៉ាងដូចម្ដេច? ហើយដើម្បីអនុញ្ញាតឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តើម្ចាស់បំណុលត្រូវបំពេញលក្ខខណ្ឌតាមច្បាប់អ្វីខ្លះ? តើការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបណាខ្លះ? តើស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ? តើការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមានបញ្ហាប្រឈម និងដំណោះស្រាយដូចម្ដេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវអត្ថបទសារណានេះ គឺដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុទាំងផ្នែកទ្រឹស្ដី និងការអនុវត្តជាក់ស្ដែង។ ដោយហេតុថាក្នុងការអនុវត្តជាក់ស្ដែង នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុអាចកើតមានឡើងនូវបញ្ហាប្រឈមផ្សេងៗ ដូចជា នីតិវិធីមានភាពយឺតយ៉ាវ និងស្មុគស្មាញដែលខុសពីគោលគំនិតនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដែលត្រូវធ្វើឡើងដោយបន្ទាន់បង្កុំក្នុងគោលបំណងការពារផលប្រយោជន៍ជូនម្ចាស់បំណុល។ ដូច្នេះ ការចងក្រងអត្ថបទសារណានេះឡើង ដើម្បីជួយឱ្យសិស្សនិស្សិតមិត្តអ្នកអានគ្រប់ជាន់ថ្នាក់ទាំងអស់ទុកសម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងប្រធានបទនេះឱ្យបានទូលំទូលាយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការចាត់ចែងរក្សាការពារមាន ០៣ (បី) ប្រភេទ ហើយនីតិវិធីត្រូវបានបែងចែកដាច់ដោយឡែកពីគ្នា ប៉ុន្តែអត្ថបទសារណាមួយនេះ បានជ្រើសរើសនូវប្រធានបទដែលទាក់ទងទៅនឹង **"ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ"** មកសិក្សាស្រាវជ្រាវ ដោយហេតុថា ការរឹបអូសជាបណ្ដោះអាសន្នអាចធ្វើឡើងចំពោះកម្មវត្ថុជាច្រើន។ ដូច្នេះ ប្រធានបទនេះ ត្រូវបានសិក្សាតែចំពោះករណីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។ ម្យ៉ាងវិញទៀត ប្រធានបទសារណានេះ គឺជាការសិក្សាស្រាវជ្រាវដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមមាន ក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ក្នុងគន្ថីទី៧ នៃប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីលេខ៥៩ ប្រក.ដនស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ និងប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីលេខ២១៤ ប្រក.ដនស ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។ អចលនវត្ថុក្នុងន័យនេះ ត្រូវបានរាប់បញ្ចូលទាំងអចលនវត្ថុដែលបានចុះបញ្ជី និងអចលនវត្ថុដែលមិនបានចុះបញ្ជី។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

អត្ថបទសារណានេះ ជាសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងព្យាយាមអស់ពីលទ្ធភាពក្នុងការរៀបរៀង និងសម្រិតសម្រាំងយ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីទុកជាប្រភពឯកសារសម្រាប់ឱ្យសិស្សនិស្សិតជំនាន់ក្រោយអាចទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។ សារៈសំខាន់នៃអត្ថបទសារណានេះ មានគោលបំណងមួយវិញទៀត ដែលខ្លឹមសារក្នុងអត្ថបទនេះប្រាកដជា

អាចឱ្យសិស្សនិស្សិតជំនាន់ក្រោយអាចយកទៅប្រើប្រាស់ ដើម្បីដោះស្រាយនូវបញ្ហាផ្សេងៗដែលកើតឡើងក្នុងជីវភាពជាក់ស្តែងនាពេលបច្ចុប្បន្ន។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានសារណានេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវលម្អិតនូវខ្លឹមសារដោយដកស្រង់ចេញពីប្រភពជាច្រើន។ ប្រភពចម្បងដែលត្រូវបានដកស្រង់មកសិក្សាស្រាវជ្រាវភាគច្រើន គឺផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ក្នុងគន្ថីទី៧ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីលេខ៥៩ ប្រក.ដនស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ និងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីលេខ២១៤ ប្រក.ដនស ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។ ក្រមនីតិវិធីរដ្ឋប្បវេណី ជាកម្រងនៃច្បាប់ទម្រង់ដែលជាមូលដ្ឋានសម្រាប់យកទៅអនុវត្តក្នុងនីតិវិធីបណ្តឹងក្នុងវិវាទរដ្ឋប្បវេណីក្នុងសង្គមជាក់ស្តែង។ រីឯប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីជាសេចក្តីសម្រេចរវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីណែនាំនិងសម្រួលដល់ការអនុវត្តជាក់ស្តែងក្នុងការចុះបញ្ជីអចលនវត្ថុក្នុងសំណុំរឿងរដ្ឋប្បវេណី ដើម្បីឈានទៅរកការការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីបណ្តឹង។ មួយវិញទៀត អត្ថបទសារណានេះ ក៏បានសិក្សាស្រាវជ្រាវទៅលើប្រភពផ្សេងទៀតដែលមានដូចជា សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី និងសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ផងដែរ។

ក្រៅពីប្រភពខាងលើ អត្ថបទសារណានេះ ក៏បានប្រមូលព័ត៌មានទន្និន័យផ្សេងទៀតមកសិក្សាស្រាវជ្រាវរួមមាន អ្នកបំពេញមុខងារក្នុងវិជ្ជាជីវៈច្បាប់ និងសេចក្តីសម្រេចរបស់តុលាការជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវលើប្រធានបទសារណានេះ ត្រូវបានចែកចេញជា ០៣ (បី) ជំពូក ដូចខាងក្រោម៖

**ជំពូកទី១ សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។**

**ជំពូកទី២ នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។**

**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ។**

# ជំពូកទី១

# សញ្ញាណទូទៅនៃការរើបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

# ជំពូកទី១

# សញ្ញាណទូទៅនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

## ផ្នែកទី១. គោលបំណងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។[1] ជាក់ស្តែង ការចាប់ផ្តើមការអនុវត្តដោយបង្ខំ គឺតម្រូវឱ្យបំពេញលក្ខខណ្ឌដូចជាអត្ថិភាពនៃលិខិតអនុវត្ត និងការមកដល់នៃពេលវេលាកំណត់នៃការសងជាអាទិ៍។ ក៏ប៉ុន្តែ ទោះបីជាការអនុវត្តដោយបង្ខំ មិនអាចចាប់ផ្តើមបានបើខ្វះលក្ខខណ្ឌណាមួយក៏ដោយ ក៏ត្រូវតែទប់ស្កាត់ជាមុន មិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែងដែរ ក្នុងករណីដែលការសម្រេចសិទ្ធិទាមទារដោយការអនុវត្តដោយបង្ខំទំនងជាមិនអាចធ្វើទៅបាន ឬទំនងជាមានការលំបាកយ៉ាងខ្លាំង នៅពេលដែលគ្រប់លក្ខខណ្ឌទាំងអស់សម្រាប់ការអនុវត្ត ត្រូវបានបំពេញនាពេលអនាគត ប្រសិនបើកូនបំណុលត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដោយសេរីនោះ។

នៅក្នុងការចាត់ចែងរក្សាការពារ រួមមាន ការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន។ ប៉ុន្តែនៅក្នុងប្រធានបទសារណានេះ គឺសិក្សាតែលើការរឹបអូសជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ ការរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងក្នុងករណីសិទ្ធិដែលត្រូវរក្សាការពារ គឺជាសិទ្ធិទាមទារឱ្យសងជាប្រាក់។ ទន្ទឹមនឹងនេះ ការរឹបអូសជាបណ្តោះអាសន្នគឺជាការកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត។

### កថាភាគទី១. លក្ខខណ្ឌនៃការរឹបអូសជាបណ្តោះអាសន្ន

#### ១.១. សិទ្ធិទាមទារដែលត្រូវរក្សាការពារ

សិទ្ធិដែលត្រូវរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់(សិទ្ធិទាមទារឱ្យសងជាប្រាក់)។[2] ជាក់ស្តែង សិទ្ធិដែលត្រូវរក្សាការពារជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដូចជាម្ចាស់បំណុលមានសិទ្ធិលើបំណុលចំពោះកូនបំណុលចំនួន ១០ លានរៀល ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ជាអាទិ៍។ មួយវិញទៀត សិទ្ធិលើទ្រព្យសម្បត្តិ ប្រសិនបើចង់

[1] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៤។

[2] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣១។

សម្រេចដោយសងជាប្រាក់ក៏អាចសុំឱ្យចាត់ចែងរក្សាការពារតាមរយៈការរឹបអូសជាបណ្ដោះអាសន្នដែរ។[3]

**ឧទាហរណ៍៖** លោក **ក** ជំពាក់ប្រាក់លោក **ខ** ចំនួន ២០០ ០០០ ដុល្លារ។ លោក **ក** ជាកូនបំណុលមានដី ១ (មួយ) កន្លែង ដែលមានតម្លៃប្រហែល ១០០ ០០០ ដុល្លារ។ នៅក្នុងនីតិវិធីបណ្ដឹងទាមទារប្រាក់នេះ ត្រូវចំណាយពេលវេលាច្រើន ករណីនេះម្ចាស់បំណុល **ខ** អាចនឹងបាត់បង់ផលប្រយោជន៍ក្នុងករណីដែលកូនបំណុល **ក** យកដីនោះទៅចាត់ចែងអស់។ ដូច្នេះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ម្ចាស់បំណុល **ខ** ត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុរបស់កូនបំណុល **ក** ដើម្បីធានាការអនុវត្តរបស់ម្ចាស់បំណុល **ខ** នៅពេលដែលគាត់ឈ្នះក្ដី។ ដូច្នេះ ក្រោយពេលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុល **ក** ហើយកូនបំណុល **ក** ត្រូវបានកម្រិតនូវសិទ្ធិចាត់ចែងខ្លួនលើអចលនវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន។

### ១.២. សិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌ ឬពេលកំណត់

សិទ្ធិទាមទារដែលត្រូវរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នឹងលក្ខខណ្ឌ ឬពេលកំណត់បាន។[4] ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់នឹងលក្ខខណ្ឌបង្អង់ ចាំបាច់មានអត្ថិភាពមូលដ្ឋាននៃសិទ្ធិ។ ប្រសិនបើមានសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ទោះបីជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់នេះភ្ជាប់នឹងលក្ខខណ្ឌ ឬ ពេលកំណត់ក៏ដោយ ក៏អាចក្លាយជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ ជាក់ស្ដែង សិទ្ធិទាមទារឱ្យសងសំណងនាពេលអនាគតរបស់អ្នកធានា និងសិទ្ធិរបស់អ្នកដាក់ពាក្យបណ្ដឹងក្នុងការទាមទារឱ្យសងវិញនូវប្រាក់ប្រដាប់ក្ដីនាពេលអនាគតចំពោះភាគីម្ខាងទៀត។ ក៏ប៉ុន្តែចំពោះសិទ្ធិទាមទារដែលពុំមានការទទួលស្គាល់តម្លៃជាទ្រព្យសម្បត្តិបច្ចុប្បន្ន ដូចជាករណីដែលលក្ខខណ្ឌរបស់វាកម្រនឹងបានសម្រេច ឬករណីដែលពេលកំណត់ស្ថិតនៅឆ្ងាយពេកជាដើមនោះ មិនអាចត្រូវបានទទួលស្គាល់នូវលក្ខខណ្ឌនៃសិទ្ធិដែលត្រូវរក្សាការពារទេ។[5]

**ឧទាហរណ៍៖** កិច្ចសន្យាខ្ចីបរិភោគដែលអ្នកខ្ចីមានករណីយកិច្ចដាក់ប្លង់ដី ដើម្បីធានាការសងប្រាក់ប្រសិនបើអ្នកខ្ចីបានយកដីដែលជាកម្មវត្ថុនៃការធានាត្រូវចាត់ចែងឱ្យអ្នកដទៃ ទោះបីជាការកំណត់នៃការសងប្រាក់មិនទាន់បានមកដល់ ក៏អ្នកឱ្យខ្ចីអាចយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានលក្ខខណ្ឌ ឬ ពេលកំណត់ទៅដាក់ពាក្យសុំរឹបអូសបណ្ដោះអាសន្នលើដីនោះបានផងដែរ។

---

[3] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី២។

[5] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៦។

### ១.៣. បណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលពាក់ព័ន្ធ

បណ្តឹងអង្គសេចក្តីអំពីសិទ្ធិដែលមានការពាក់ព័ន្ធនោះ មិនអាចដាក់ទៅតុលាការកម្ពុជាបាន ដូចជា ករណីនៃសិទ្ធិទាមទារដែលភ្ជាប់នឹងកិច្ចសន្យាមជ្ឈត្តកម្ម ឬសិទ្ធិទាមទារដែលស្ថិតក្រោមសមត្ថកិច្ចនៃតុលាការបរទេស ជាអាទិ៍ ក៏អាចអនុវត្តការរឹបអូសជាបណ្តោះអាសន្នបានដែរ ដោយយោងទៅលើភាពចាំបាច់នៃការរក្សាការពារ។ ចំពោះសិទ្ធិទាមទារដែលកើតចេញពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង (ការទាមទារឱ្យផ្តល់អាហារកាតព្វកិច្ច ការទាមទារឱ្យបែងចែងទ្រព្យសម្បត្តិ ជាអាទិ៍) ក៏ត្រូវអនុវត្តដូចគ្នាដែរ។

### កថាភាគទី២. ភាពចាំបាច់នៃការរក្សាការពារ

ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនត្រឹមតែផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកលើភាពចាំបាច់នៃការរក្សាការពារផងដែរ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំបើបណ្តោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែលប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថា ការរក្សាការពារមានភាពចាំបាច់។[6] ដូច្នេះ ប្រសិនបើមានត្រឹមតែអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ ហើយពុំមានភាពចាំបាច់ដែលត្រូវរក្សាការពារនោះការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏ពុំអាចធ្វើទៅបានផងដែរ។

មួយវិញទៀត ការរក្សាការពារត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬនឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្តូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សាការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្តូរលំនៅឋានជាច្រើនលើកជាច្រើនសារ បង្កឱ្យមានការពិបាកក្នុងការដឹងពីទ្រព្យសម្បត្តិរបស់កូនបំណុល ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ។ ចំពោះភាពចាំបាច់នៃការរក្សាការពារ ចាំបាច់ត្រូវសរសេរអង្គហេតុបង្ហាញស្ថានភាពទាំងនោះឱ្យបានលម្អិត។ ការកំណត់នេះ មិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។

ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារត្រូវចាត់ទុកថាមានភាពចាំបាច់។ តួយ៉ាង ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍។ ម៉្យាងវិញទៀត ទោះបីជាក្នុងករណីដែលបានបំពេញតាមលក្ខខណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារអាចនឹងត្រូវបានបដិសេធដែរ។ **ឧទាហរណ៍៖** ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬករណីដែលសិទ្ធិលើបំណុល បំពេញ

[6] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

លក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានលក្ខខណ្ឌ។

## ផ្នែកទី២. រចនាសម្ព័ន្ធនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន

### កថាភាគទី១. ដំណាក់កាលនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន

នីតិវិធីចាត់ចែងរក្សាការពារមានចរិតលក្ខណៈ ជានីតិវិធីដែលបំពេញបន្ថែមទៅលើការអនុវត្តដោយបង្ខំ ដែលនៅក្នុងនោះ មានការបែងចែកជាពីរដំណាក់កាលដូចជា នីតិវិធីនៃការសម្រេចសេចក្តីដែលវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ និងនីតិវិធីនៃការអនុវត្តដែលសម្រេចដោយបង្ខំនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញ ដោយយកដីកាសម្រេចនេះមកធ្វើជាលិខិតអនុវត្ត។[7]

ដំណាក់កាលទីមួយ អាចហៅថាការសម្រេចរក្សាការពារ។ ឯដំណាក់កាលទីពីរ អាចហៅថាការអនុវត្តរក្សាការពារ។ ការបែងចែកនេះមានលក្ខណៈដូចគ្នានឹងការបែងចែករវាងនីតិវិធីបណ្តឹង និងនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។ ក៏ប៉ុន្តែគោលបំណងនៃដីកាសម្រេចរក្សាការពារ អាចសម្រេចបានលុះត្រាតែមានការអនុវត្តដោយបង្ខំ។ ហេតុនេះហើយ ទំនាក់ទំនងរវាងការសម្រេចរក្សាការពារ និងការអនុវត្តរក្សាការពារ មានលក្ខណៈជិតស្និទ្ធជាងទំនាក់ទំនងរវាងនីតិវិធីបណ្តឹង និងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

### កថាភាគទី២. លក្ខណៈពិសេសនៃការរឹបអូសជាបណ្តោះអាសន្ន

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជាវិធានការមួយដែលមានលក្ខណៈបន្ទាន់បង្ខំ ហើយត្រូវបានធ្វើឡើង ដោយមានលក្ខណៈសំងាត់ មុនពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ ហើយជាយន្តការការពារជាបឋមចំពោះផលប្រយោជន៍របស់ម្ចាស់បំណុល។ ការចាត់ចែងរក្សាការពារអាចត្រូវបានចេញមុននីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន ឬក្នុងអំឡុងពេលនីតិវិធីនៃបណ្តឹងអង្គសេចក្តីក៏បាន។ ដូច្នេះ លក្ខណៈពិសេសនៃការរឹបអូសបណ្តោះអាសន្នចំពោះអចលនវត្ថុរួមមាន (**២.១**) លក្ខណៈបណ្តោះអាសន្ន (**២.២**) លក្ខណៈបន្ទាន់បង្ខំ (**២.៣**) លក្ខណៈបន្ទាប់បន្សំ និង (**២.៤**) លក្ខណៈសម្ងាត់ ដែលចរិតលក្ខណៈពិសេសទាំងអស់នេះ ត្រូវបានដកស្រង់ចេញពីក្រមនីតិវិធីរដ្ឋប្បវេណី។[8]

#### ២.១. លក្ខណៈបណ្តោះអាសន្ន

ផ្អែកតាមមាត្រា៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យ **"បណ្តោះអាសន្ន"** មានន័យថាគ្រប់ប្រភេទនៃការចាត់ចែងរក្សាការពារ គឺមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ។ វិធានរក្សាការពារមានលក្ខណៈបណ្តោះអាសន្នពុំមានឥទ្ធិពលចំពោះសេចក្តីសម្រេចនៃបណ្តឹងអង្គសេចក្តីឡើយ ទោះបីជាតុលាការបានចេញដីកាសម្រេចរក្សាការពារ

---

[7] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*. ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៥។

[8] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣១ មាត្រា៥៥៧ មាត្រា៥៦២។

តាមការស្នើសុំរបស់ម្ចាស់បំណុលក៏ដោយ ក៏ពុំមានន័យថា តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទក្នុងបណ្តឹងអង្គសេចក្តីនោះដែរ។

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺជានីតិវិធីមួយដែលធ្វើឡើងដោយបណ្តោះអាសន្ន បានន័យថាដីកាសម្រេចរក្សាការពារពុំមានឥទ្ធិពលទៅលើសេចក្តីសម្រេច ដោយសាលក្រមក្នុងបណ្តឹងអង្គសេចក្តីឡើយ ឬ ធ្វើឱ្យសេចក្តីសម្រេចប្រែប្រួលទេ។ ទោះបីដីកាសម្រេចរក្សាការពារដែលបានចេញដោយតុលាការក៏ដោយ ក៏សិទ្ធិលើបំណុល ឬសិទ្ធិទាមទារផ្សេងៗទៀតរបស់បណ្តឹងអង្គសេចក្តីមិនត្រូវបានបញ្ជាក់ថា មានអត្ថិភាព ឬនត្ថិភាពឡើយ។

**២.២. លក្ខណៈបន្ទាន់បន្ទំ**

ផ្អែកតាមមាត្រា៥៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការចាត់ចែងរក្សាការពារមានលក្ខណៈ **"បន្ទាន់បង្ខំ"** ពោលគឺត្រូវអនុវត្តឱ្យបានលឿនជាងមុនពេលកូនបំណុលចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ហេតុនេះការអនុវត្តរក្សាការពារអាចធ្វើទៅបាន មុនពេលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅកូនបំណុល។ វិធានរក្សាការពារមានលក្ខណៈប្រញាប់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬបង្ការកុំឱ្យមានការខូចខាតធ្ងន់ធ្ងរកើតមានឡើងចំពោះម្ចាស់បំណុល តាមរយៈការទទួលស្គាល់សិទ្ធិរបស់ម្ចាស់បំណុលនៅពេលមានការស្នើសុំ ដោយមិនចាំបាច់ធ្វើការសាកសួរកូនបំណុលនោះទេ គ្រាន់តែពិនិត្យសេចក្តីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់។

នីតិវិធីនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬការពារការខូចខាតដែលរំពឹងថានឹងកើតឡើងនាពេលឆាប់ៗខាងមុខជាក់ជាមិនខាន ដូច្នេះចៅក្រមមានឆន្ទានុសិទ្ធិជ្រើសរើសយកនីតិវិធីណាមួយក៏បាន ប៉ុន្តែនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចៅក្រមកម្រនឹងធ្វើណាស់ ព្រោះពេលខ្លះធ្វើឱ្យខូចខាតដល់កម្មវត្ថុដែលត្រូវរក្សាការពារ ដែលបង្កឡើងដោយកូនបំណុល ចៅក្រមច្រើនតែជ្រើសរើសយកនីតិវិធីការសាកសួរម្ចាស់បំណុល គឺមានលក្ខណៈល្អជាង គ្រាន់តែពិនិត្យភស្តុតាងជាឯកសារ ឬឱ្យភាគីធ្វើសេចក្តីបញ្ជាក់ដំបូងល្មមៗបានហើយ។ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើដោយផ្អែកលើភស្តុតាងដែលអាចឱ្យគេពិនិត្យបានភ្លាមៗ។ បន្ទាប់ពីធ្វើសេចក្តីបញ្ជាក់ដំបូងដែលនាំឱ្យចេញរក្សាការពារ ហើយដីកាសម្រេចនេះត្រូវទុករយៈពេលនៃការអនុវត្តក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលចាប់បញ្ជូនទៅម្ចាស់បំណុល បើម្ចាស់បំណុលមិនសុំអនុវត្តទេ នោះដីកាសម្រេចត្រូវអស់អានុភាព ប៉ុន្តែពេលអនុវត្តដីកាសម្រេចនេះមិនចាំបាច់មានរូបមន្តអនុវត្ត។ ម៉្យាងទៀត ដើម្បីឱ្យបានលឿន និងបន្ទាន់ផង ច្បាប់បានតម្រូវទៅលើសមត្ថកិច្ចផ្តាច់មុខ បានន័យថា ភាគីមិនអាចផ្លាស់ប្តូរសមត្ថកិច្ច ដោយការព្រមព្រៀងឡើយ។

**២.៣. លក្ខណៈបន្ទាប់បន្សំ**

ផ្អែកតាមមាត្រា៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការចាត់ចែងរក្សាការពារមានលក្ខណៈ **"បន្ទាប់បន្សំ"** ពីព្រោះក្នុងករណីម្ចាស់បំណុល មិនដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមពាក្យសុំរបស់កូនបំណុល ក្នុងអំឡុងពេល

ដែលច្បាប់បានកំណត់ទេនឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារដែលបានចេញពីមុន។ វិធានរក្សាការពារមានលក្ខណៈរណបឱ្យបណ្តឹងអង្គសេចក្តី មានខ្លឹមសារថា តុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់បណ្តឹងអង្គសេចក្តីក្នុងអំឡុងពេលសមរម្យ ប្រសិនបើមានការស្នើសុំរបស់កូនបំណុល។ ករណីនេះ ប្រសិនបើម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងលើអង្គសេចក្តីក្នុងអំឡុងពេលកំណត់ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ តាមការស្នើសុំរបស់កូនបំណុល។ មួយវិញទៀត វិធានរក្សាការពារស្តីពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវការពារ គឺមានលក្ខណៈដូចគ្នានឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារក្នុងបណ្តឹងអង្គសេចក្តី មានន័យថាប្រសិនបើគ្មានសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ តុលាការនឹងមិនចេញដីកាសម្រេចរក្សាការពារតាមការស្នើសុំរបស់ម្ចាស់បំណុលនោះទេ ឬក្នុងករណីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវបានរលត់នាពេលក្រោយ ដោយមូលហេតុកាតព្វកិច្ចរបស់កូនបំណុល ឬម្ចាស់បំណុលចាញ់បណ្តឹងអង្គសេចក្តី សេចក្តីសម្រេចនៃបណ្តឹងអង្គសេចក្តីបានចូលជាស្ថាពរ ជាមូលហេតុដែលតុលាការអាចលុបចោលដីកាសម្រេចការពារនោះវិញបាន តាមពាក្យសុំរបស់កូនបំណុល។

នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ គឺជានីតិវិធីបន្ទាប់បន្សំដើម្បីធ្វើបណ្តឹងអង្គសេចក្តីនៅក្នុងចំណុចមួយចំនួន។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជានីតិវិធីមួយដែលធ្វើឡើងបណ្តោះអាសន្ន វាពុំមានឥទ្ធិពលទៅលើបណ្តឹងអង្គសេចក្តីទៅតុលាការដែលមានសមត្ថកិច្ច នោះការរក្សាការពារត្រូវតែសុំទៅតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តីនោះដែរ។ ដូច្នេះ រឿងក្តីនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។[9]

**ឧទាហរណ៍៖** ការរឹបអូសជាបណ្តោះអាសន្នទៅលើដីមួយកន្លែងរបស់កូនបំណុល គឺត្រូវបានធ្វើឡើងដើម្បីធានាការសងសិទ្ធិលើបំណុលដល់ម្ចាស់បំណុល។ ប្រសិនបើកូនបំណុលបានយកប្រាក់ដែលជំពាក់ទៅសងដល់ម្ចាស់បំណុលតាមការទាមទារ នោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរវាងកូនបំណុល និងម្ចាស់បំណុលនឹងត្រូវបានរលត់។ ដូច្នេះ មិនត្រឹមតែតុលាការដែលបានចេញដីកាសម្រេចរក្សាការពារប៉ុណ្ណោះទេ ដែលអាចលុបចោលដីកាសម្រេចរក្សាការពារនេះបាន គឺថែមទាំងតុលាការដែលវិនិច្ឆ័យលើបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារនោះវិញបានទៅតាមពាក្យសុំរបស់ភាគី (មាត្រា៥៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១។

### ២.៤. លក្ខណៈសម្ងាត់

ការចាត់ចែងរក្សាការពារត្រូវអនុវត្តមានលក្ខណៈ **"សម្ងាត់"** (ស្ងាត់ៗមិនឱ្យកូនបំណុលដឹង) បើពុំដូច្នេះទេ ដីកាសម្រេចរក្សាការពារនឹងក្លាយជាគ្មានន័យ។ វិធានរក្សាការពារត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារ ផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល ដោយមិនឱ្យកូនបំណុលបានដឹងខ្លួនជាមុនតាមរយៈការអនុវត្ត ដីកាសម្រេចរក្សាការពាររួចរាល់ហើយ ទើបជូនដំណឹងទៅកូនបំណុលជាក្រោយ ពីព្រោះប្រសិនបើកូនបំណុល បានដឹងជាមុន នោះការអនុវត្តដីកាសម្រេចរក្សាការពារអាចនឹងមិនទទួលបានជោគជ័យទេ។ ហេតុនេះ ដើម្បីបញ្ចៀស នូវហានិភ័យបែបនេះ តុលាការត្រូវអនុវត្តនីតិវិធីរក្សាការពារដោយសម្ងាត់។ ក្នុងករណីនេះ ប្រសិនបើកូនបំណុល យល់ថាប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន អាចធ្វើការតវ៉ាបាន ហើយប្រសិនបើតុលាការទទួលស្គាល់ ការតវ៉ារបស់កូនបំណុល តុលាការនឹងលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។

ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តែងតែបារម្ភថា នៅពេលដែលតុលាការកំណត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តជាស្ថាពរហើយ ខ្លួនមិនអាចអនុវត្តនូវកិច្ចការទាំងនោះ បានទេ ហើយម្ចាស់បំណុលតែងតែស្នើសុំមកតុលាការឱ្យចាត់ចែងការរក្សាការពារ ប៉ុន្តែពេលខ្លះតុលាការតម្រូវឱ្យ ម្ចាស់បំណុលដាក់ប្រាតិភោគ ដើម្បីកុំឱ្យប្រើសិទ្ធិនេះហួសហេតុពេក រីឯកូនបំណុលវិញ កាលបើខ្លួនដឹងថាចាញ់ក្តី ពេលនោះខ្លួនក៏បានលួចចាត់ចែងទ្រព្យនោះទៅឱ្យអ្នកដទៃផ្សេងទៀត ក្នុងគោលបំណងគេចវេសមិនទទួល ខុសត្រូវ។ ភាពសម្ងាត់នេះ គឺរក្សាផលប្រយោជន៍ឱ្យម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំដែលនីតិវិធីនេះធ្វើឱ្យ បាត់បង់គោលការណ៍ចំពោះមុខ ប៉ុន្តែដោយសារមានលក្ខណៈសម្ងាត់បែបនេះហើយ ទើបច្បាប់តម្រូវឱ្យម្ចាស់បំណុល ដែលជាអ្នកដាក់ពាក្យសុំយកដីកាសម្រេចនេះ ទៅអនុវត្តមុនការបញ្ជូនទៅដល់កូនបំណុលបានទៀតផង។[10] ម្យ៉ាងវិញទៀត ចៅក្រមអាចជ្រើសរើសយកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដូចជាការពិនិត្យភស្តុតាង និងការសាកសួរភាគីបានដែរ ប៉ុន្តែនីតិវិធីនេះអាចធ្វើជាសាធារណៈ ដូច្នេះអាចមានហានិភ័យកើតឡើងដោយ កូនបំណុល ឬតតិយជនផ្សេងទៀតធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុល។ ដើម្បីចៀសវាងនូវហានិភ័យនេះ តុលាការត្រូវធ្វើនីតិវិធីរក្សាការពារជាសម្ងាត់ ដូច្នេះ តុលាការអាចជ្រើសរើសនីតិវិធីនៃការពិនិត្យឯកសារ ឬសាកសួរ ម្ចាស់បំណុល ដើម្បីចេញដីកាសម្រេច។[11] ប្រសិនបើកូនបំណុលយល់ឃើញថា ការចាត់ចែងរក្សាការពាររឹបអូស ជាបណ្តោះអាសន្ននេះ ប៉ះពាល់ផលប្រយោជន៍របស់ខ្លួន ដោយមិនសមរម្យ ទើបរបបចាត់ចែងរក្សាការពារនេះ អាចអនុញ្ញាតឱ្យកូនបំណុលមានសិទ្ធិប្តឹងតវ៉ាបាន ហើយតុលាការក៏ពិចារណាពីបណ្តឹងតវ៉ានេះ ដែលនាំឱ្យ តុលាការទទួលស្គាល់ផ្លាស់ប្តូរ ឬលុបចោលការចាត់ចែងរក្សាការពារនេះបានតែម្តង។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី៣។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា១១៤ កថាខណ្ឌទី២។

## កថាភាគទី៣. កម្មវត្ថុ និងភាគីនៃការរឹបអូសជាបណ្តោះអាសន្ន

### ៣.១. កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន

កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននៅក្នុងប្រធានបទសារណានេះ គឺសំដៅទៅលើអចលនវត្ថុ។

តាមច្បាប់ភូមិបាល អចលនវត្ថុបានបែងចែកចេញជា ៣ (បី) ប្រភេទមានដូចជា អចលនវត្ថុពីកំណើត អចលនវត្ថុតាមការកំណត់របស់ច្បាប់ និងអចលនវត្ថុតាមភ័ព្វវាសនា។

ក. អចលនវត្ថុពីកំណើត រួមមាន ដីធម្មជាតិ ដីព្រៃឈើ ដីដាំដុះ ដីទុកចោល ឬមិនអាចដាំដុះដីលិចទឹកដោយទឹងនៅនឹង ឬទឹកកំពុងហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាហ្នឹងមួយកន្លែងកើតឡើងមិនអាចរំកិល ឬផ្លាស់ទីបានឡើយ។[12]

ខ. អចលនវត្ថុតាមការកំណត់ដោយច្បាប់ ជាសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុតាមការ ឬលើចលនវត្ថុដែលច្បាប់បានសន្មត់ថាជាអចលនវត្ថុ។[13]

គ. អចលនវត្ថុតាមភ័ព្វវាសនា សំដៅដល់វត្ថុជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយ ដែលមិនអាចបំបែកចេញបានដោយមិនធ្វើឱ្យ ឬមិនដូរសភាពដើម ដូចជា កង្ហារ ពិដាន ម៉ាស៊ីន ត្រជាក់ ជាដើម។[14]

ចំណែកឯក្រមរដ្ឋប្បវេណី អចលនវត្ថុត្រូវសំដៅលើ ដីធ្លី និងវត្ថុដែលជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ហើយចំពោះវត្ថុផ្សេងៗ ក្រៅពីនេះទៀត ត្រូវបានរាប់បញ្ចូលជាចលនវត្ថុ។[15] អចលនវត្ថុក្នុងន័យនេះ ត្រូវបានរាប់បញ្ចូលទាំងអចលនវត្ថុដែលបានចុះបញ្ជី និងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ហើយជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ដែលអាចជាកម្មវត្ថុនៃចាត់ចែងរក្សាការពារទុកសម្រាប់ធ្វើការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលនៅពេលក្រោយ។

អចលនវត្ថុដែលបានចុះបញ្ជី គឺសំដៅដល់ដីដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានចេញ។[16] អចលនវត្ថុដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដី និងចំណែកឯកជននៃអាគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី។[17] ម៉្យាងវិញទៀត ដីដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើដីដែលមិនទាន់បានចុះក្នុងសៀវភៅចុះបញ្ជី ហើយដែលតុលាការបានសន្មត់ថាកូនបំណុល

---

[12] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី២។

[13] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី៤។

[14] ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា២ កថាខណ្ឌទី៣។

[15] ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧, មាត្រា១២០ កថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣។

[16] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៣។

[17] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៤។

នៃការអនុវត្ត ឬកូនបំណុលដែលជាកម្មសិទ្ធិករ ឬភោគីនៃដីនោះ ដោយផ្អែកតាមមាត្រា៤១៧ កថាខណ្ឌទី៣ និង មាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

មួយវិញទៀត ចំណែកឯកជននៃអាគារសហកម្មសិទ្ធិដែលមិនទាន់បានចុះបញ្ជី គឺសំដៅលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលមិនទាន់បានចុះក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលតុលាការបានសន្មត់ថាកូនបំណុលនៃការអនុវត្ត ឬកូនបំណុលជាកម្មសិទ្ធិករ ឬជាម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ នៃចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះ ដោយផ្អែកតាមមាត្រា៤១៧ កថាខណ្ឌទី៣ និងមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ម្យ៉ាងវិញទៀត កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវទ្រព្យសម្បត្តិជាក់លាក់ស្ថិតក្រោមកម្មសិទ្ធិរបស់កូនបំណុល ផ្អែកតាមមាត្រា៥៦៤ មាត្រា៥៦៤ និងមាត្រា៣៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដោយហេតុថា គោលដៅនៃការរឹបអូសជាបណ្តោះអាសន្ន គឺរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងសងជាប្រាក់។[18]

### ៣.២. ភាគីនៃការរឹបអូសជាបណ្តោះអាសន្ន

ភាគីនៅក្នុងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមាន ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសបណ្តោះអាសន្នចំពោះអចលនវត្ថុហៅថា **អ្នកដាក់ពាក្យសុំ ឬម្ចាស់បំណុល** ហើយចំណែកឯភាគីម្ខាងទៀត ហៅថា **កូនបំណុល**។[19]

ទន្ទឹមនឹងនេះ បុគ្គលដែលអះអាងថាខ្លួនមានសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ហើយបានដាក់ពាក្យសុំរក្សាការពារមកតុលាការហៅថា **ម្ចាស់បំណុល** រីឯភាគីម្ខាងទៀតនៃពាក្យសុំនេះ ហៅថា **កូនបំណុល** ( សំណុំរឿងរក្សាការពារ )។

លើសពីនេះទៅទៀត ចំពោះសំណុំរឿងអនុវត្តរក្សាការពារ បុគ្គលដែលបានទទួលសេចក្តីសម្រេចពីតុលាការដែលបានចេញដីកាសម្រេចចាត់ចែងរក្សាការពារ និងបានដាក់ពាក្យសុំអនុវត្តដីកាសម្រេចនេះ ហៅថា **ម្ចាស់បំណុល** រីឯភាគីម្ខាងទៀតនៃពាក្យសុំនេះ ហៅថា **កូនបំណុល** (សំណុំរឿងអនុវត្តរក្សាការពារ) ពីព្រោះនៅក្នុងមាត្រា៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនរាប់បញ្ចូលមាត្រា៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ នាំឱ្យបកស្រាយថា មិនអាចប្រើពាក្យម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តនៅក្នុងសំណុំរឿងអនុវត្តរក្សាការពារបានឡើយ ហើយការអនុវត្តរក្សាការពារមិនមានលំហូរនីតិវិធីស្មុគស្មាញ និងវែងឆ្ងាយដូចសំណុំរឿងអនុវត្តដោយបង្ខំឡើយ។

---

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣១ ចំណុច ក។

[19] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១៩៥។

# ជំពូកទី២
# នីតិវិធីនៃការរឹបអូសជា
# បណ្តោះអាសន្នចំពោះអចលនវត្ថុ

# ជំពូកទី២
# នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ
## ផ្នែកទី១. នីតិវិធីនៃការសម្រេចសេចក្តី (ការសម្រេចរឹបអូសជាបណ្តោះអាសន្ន)
### កថាភាគទី១. សមត្ថកិច្ចតុលាការ

សមត្ថកិច្ចរបស់តុលាការ គឺជាទំហំនៃសិទ្ធិអំណាច ដែលអាចអនុវត្តសិទ្ធិនៃការសម្រេចសេចក្តី ហើយសិទ្ធិអំណាចទាំងនេះ ត្រូវបានប្រគល់ឱ្យទៅតុលាការគ្រប់ជាន់ថ្នាក់។ ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។[20] សមត្ថកិច្ចតុលាការនៃការរឹបអូសជាបណ្តោះអាសន្ននេះ ជាសមត្ថកិច្ចផ្តាច់មុខ។[21] ហើយតុលាការមានសមត្ថកិច្ចលើរឿងក្តីនៃការរឹបអូសជាបណ្តោះអាសន្ន រួមមាន (១.១) សមត្ថកិច្ចតាមបណ្តឹងអង្គសេចក្តី និង (១.២) សមត្ថកិច្ចតាមវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។[22]

#### ១.១. សមត្ថកិច្ចតាមបណ្តឹងអង្គសេចក្តី

តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី **"អង្គសេចក្តី"** សំដៅទៅលើរឿងក្តីនៃពាក្យបណ្តឹងត្រូវបានដាក់ចំពោះសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសជាបណ្តោះអាសន្ន អង្គសេចក្តីក៏អាចជារឿងក្តីមជ្ឈត្តកម្ម ឬរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែរ។[23]

នៅមុនពេលដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការមានសមត្ថកិច្ច គឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីនៃបណ្តឹងដែលនឹងធ្វើនាពេលអនាគត ហើយបើមានតុលាការដែលមានសមត្ថកិច្ចបែបនេះច្រើន នោះអាចជ្រើសរើសយកតុលាការណាមួយក្នុងចំណោមតុលាការទាំងនោះបាន។ នៅពេលដែលអង្គសេចក្តីកំពុងត្រូវបានចាត់ការ ជាគោលការណ៍តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះលើកទី១។ ប៉ុន្តែ ប្រសិនបើអង្គសេចក្តីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា៥៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីដែលអង្គសេចក្តីកំពុងត្រូវបានចាត់ការនៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខនោះ គឺតុលាការដែលជាអ្នកមានសមត្ថកិច្ចលើអង្គសេចក្តី គឺតុលាការនៃការជំនុំជម្រះលើកទី១។ ដោយហេតុថា ជាគោលការណ៍តុលាការកំពូលជាតុលាការអង្គច្បាប់មិនវិនិច្ឆ័យលើអង្គហេតុនោះទេ ហើយសិទ្ធិជម្រះពីរដងរបស់គូភាគីនៃសំណុំរឿងរក្សាការពារមិនអាចត្រូវបានផ្តល់ជូនឡើយ បើទទួលស្គាល់តុលាការកំពូលក្នុងនាមជាតុលាការអង្គសេចក្តីចំពោះ

---

[20] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៣។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០ កថាខណ្ឌទី១។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤០។

សំណុំរឿងរក្សាការពារ ដូច្នេះ ប្រសិនបណ្តឹងអង្គសេចក្តី ត្រូវបានជំនុំជម្រះនៅតុលាការកំពូល ហើយមានភាគីណាមួយយល់ថា ត្រូវធ្វើនីតិវិធីចាត់ចែងរក្សាការពារ ត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះទៅតុលាការនៃការជំនុំជម្រះលើកទី១ វិញ (តុលាការមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី)។

**ឧទាហរណ៍៖** លោក **ខ** មានសិទ្ធិលើបំណុលចំពោះលោក **ក** ចំនួន ១០ ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ក្រោយមកលោក **ក** មិនបានអនុវត្តកាតព្វកិច្ចសងប្រាក់របស់ខ្លួន។ លោក **ក** មានដីមួយកន្លែងស្ថិតនៅរាជធានីភ្នំពេញ។ ករណីនេះ សំណុំរឿងបណ្តឹងតាមអង្គសេចក្តីរបស់ លោក **ក** កំពុងចាត់ការនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ដូច្នេះ លោក **ខ** ក៏អាចដាក់ពាក្យសុំរក្សាការពារដីមួយកន្លែងរបស់លោក **ក** នៅសាលាឧទ្ធរណ៍ភ្នំពេញបានផងដែរ ដោយផ្អែកលើសមត្ថកិច្ចតាមបណ្តឹងអង្គសេចក្តី។

គួរបញ្ជាក់បន្ថែមថា ទោះបីជាពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវបានដាក់ទៅតុលាការដែលអាចធ្វើបានដោយមិនចាំបាច់ឱ្យតុលាការនៃបណ្តឹងអង្គសេចក្តី ផ្ញើសំណុំរឿងអង្គសេចក្តីមកតុលាការដែលកំពុងចាត់ការសំណុំរឿងរក្សាការពារឡើយ ពីព្រោះតុលាការរក្សាការពារពិនិត្យសេចក្តីបញ្ជាក់ដំបូងតែប៉ុណ្ណោះ។

**១.២. សមត្ថកិច្ចតាមវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏អាចដាក់ពាក្យសុំមកតុលាការដែលមានសមត្ថកិច្ចលើទីតាំងដែលអចលនវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នបានផងដែរ។

**ឧទាហរណ៍៖** លោក ខ មានសិទ្ធិលើបំណុលចំពោះលោក **ក** ចំនួន ១០ ម៉ឺនដុល្លារ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ក្រោយមកលោក **ក** មិនបានអនុវត្តកាតព្វកិច្ចសងប្រាក់របស់ខ្លួន។ លោក **ក** មានដីមួយកន្លែងស្ថិតនៅរាជធានីភ្នំពេញ។ ករណីនេះ ដីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នស្ថិតនៅភ្នំពេញ អ្នកដាក់ពាក្យអាចដាក់ពាក្យសុំមកសាលាដំបូងរាជធានីភ្នំពេញ ហើយតុលាការនេះមានសមត្ថកិច្ចផ្អែកតាមវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។

បើវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាវត្ថុក្រៅពីអចលនវត្ថុ នោះត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុនោះ។ ក្នុងករណីដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន គឺជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវចាត់ទុកថាសិទ្ធិនោះស្ថិតនៅឯលំនៅឋានជាអាទិ៍ របស់កូនបំណុលទី៣ ឬបុគ្គលដែលមានលក្ខណៈដូចជាកូនបំណុលទី៣ (មាត្រា៥៤០ កថាខណ្ឌទី៣ និងទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី)។[24]

ជាក់ស្តែង ក្នុងករណីសមត្ថកិច្ចរបស់តុលាការមានច្រើន ដូចជា ដី ១ កន្លែង ស្ថិតនៅភ្នំពេញ ដី ១ កន្លែងទៀត ស្ថិតនៅខេត្តកណ្តាល (កម្មវត្ថុដែលត្រូវរក្សាការពារមានទីតាំងខុសៗគ្នា) នាំឱ្យសមត្ថកិច្ចរបស់តុលាការ

[24] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី១។

អាចជាសាលាដំបូងរាជធានីភ្នំពេញ ឬសាលាដំបូងខេត្តកណ្តាល ហេតុនេះ ម្ចាស់បំណុលអាចដាក់ពាក្យសុំទៅសាលាដំបូងណាមួយក៏បាន មានន័យថាដាក់ទៅភ្នំពេញ ដោយរួមជាបញ្ចូលដីទាំងពីរកន្លែងនេះ នាំឱ្យសាលាដំបូងរាជធានីភ្នំពេញ មានសមត្ថកិច្ចចាត់ការលើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះដីទាំងអស់ (មាត្រា៥៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ មាត្រា១១ មាត្រា១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ពីព្រោះមូលដ្ឋាននៃការកំណត់ពេលវេលាសម្រាប់កំណត់សមត្ថកិច្ចតុលាការ គឺពេលដាក់ពាក្យសុំ ហើយចំពោះពាក្យសុំដែលមានការទាមទារច្រើនចំណុចស្ថិតនៅក្រោមសមត្ថកិច្ចតុលាការផ្សេងៗគ្នា អាចដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ចណាមួយក្នុងចំណោមតុលាការដែលមានសមត្ថកិច្ចនានា ក៏បានដោយរួមបញ្ចូលការទាមទារផ្សេងៗទៀតជាមួយគ្នា។

**កថាភាគទី២. ការដាក់ពាក្យសុំ**

ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរជាលាយលក្ខណ៍អក្សរ។[25] ការកំណត់បែបនេះ គឺមានគោលបំណងដើម្បីធានានូវភាពច្បាស់លាស់។ ការដាក់ពាក្យសុំនេះ ត្រូវបង់ពន្ធចំនួន ៥ ០០០ (ប្រាំពាន់) រៀល ។[26]

ម្យ៉ាងវិញទៀត ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានដូចខាងក្រោមនេះ៖

(១) ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

(២) ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

(៣) សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

(៤) ភាពចាំបាច់នៃការរក្សាការពារ។

ចំពោះចំណុចទី៣ និងចំណុចទី៤ នៃកថាខណ្ឌទី១ខាងលើ អ្នកដាក់ពាក្យសុំ គប្បីសរសេរឱ្យបានច្បាស់លាស់ និងត្រូវសរសេរនូវភស្តុតាងតាមហេតុនីមួយៗដែលត្រូវបញ្ជាក់។

**២.១. អត្តសញ្ញាណគូភាគី និងអ្នកតំណាង**

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរនូវអត្តសញ្ញាណរបស់ភាគីឱ្យបានច្បាស់លាស់ ដូចជាឈ្មោះ អាយុ លេខអត្តសញ្ញាណប័ណ្ណ អាសយដ្ឋានបច្ចុប្បន្ន ជាដើម។ មិនតែប៉ុណ្ណោះ អ្នកតំណាងដែលច្បាប់បានកំណត់ ក៏ដូចទៅនឹងភាគីដែរ ពោលគឺត្រូវសរសេរនូវអត្តសញ្ញាណឱ្យបានច្បាស់លាស់

[25] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៤ ចំណុច ក។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១។

នៅក្នុងពាក្យសុំនោះ។ ជាពិសេស ដើម្បីឱ្យមានភាពងាយស្រួលក្នុងការជូនដំណឹង ភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ គប្បីសរសេរនូវលេខទូរស័ព្ទបន្ថែមនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

**២.២. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ**

ជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវកំណត់ឱ្យបានជាក់លាក់។[27] ក៏ប៉ុន្តែ ក្នុងករណីដែលកម្មវត្ថុនោះ គឺជាចលនវត្ថុ មិនចាំបាច់កំណត់ជាក់លាក់អំពីចលនវត្ថុនីមួយៗនោះទេ[28] តែត្រូវបញ្ជាក់អំពីទីកន្លែងនៃចលនវត្ថុ។[29] មានន័យថា ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ជាចំណុចសំខាន់ដែលពុំអាចខ្វះបាន និងត្រូវមានសរសេរនូវអត្ថន័យឱ្យបានច្បាស់លាស់ ដោយសារតែខ្លឹមសារនៃការចេញដីកាសម្រេចរក្សាការពារនេះ ជាកម្មវត្ថុនៃការចេញដីកាសម្រេចការពារ។ ជាក់ស្តែង ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ អាចសរសេរថា "រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់កូនបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធ"។ ក្នុងករណីការរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុច្បាប់មិនតម្រូវឱ្យកំណត់អត្តសញ្ញាណជាក់លាក់នោះនេះ ពោលគឺ ចង្អុលទីតាំងចលនវត្ថុនោះស្ថិតនៅគ្រាប់គ្រាន់។

**ឧទាហរណ៍៖** អ្នកដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ត្រូវសរសេរពីខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឱ្យបានច្បាស់លាស់ និងកំណត់នូវអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងសិទ្ធិលើបំណុលឱ្យបានជាក់លាក់។

**២.៣. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ**

ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី១ ចំណុច "គ" នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺសិទ្ធិទាមទារដែលមានកំណត់នៅក្នុងច្បាប់សារជាតុ ដែលដូចគ្នានឹងសិទ្ធិទាមទារនៅក្នុងបណ្តឹងអង្គសេចក្តីដែរ។ ម្យ៉ាងវិញទៀត សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ត្រូវជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។

ផ្អែកតាមមាត្រា៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី អ្នកដាក់ពាក្យសុំ គប្បីសរសេរឱ្យច្បាស់លាស់ និងសរសេរនូវភស្តុតាងតាមអង្គហេតុនីមួយៗដែលត្រូវបញ្ជាក់ចំពោះចំណុចស្តីពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលដូចនឹងត្រូវបានរក្សាការពារ។ ហេតុនេះ ដើម្បីឱ្យមានភាពច្បាស់លាស់ អ្នកដាក់ពាក្យសុំ គប្បីសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ ដូចមានបញ្ញត្តិនៅក្នុងមាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

[27] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦ វាក្យខណ្ឌទី១។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦ វាក្យខណ្ឌទី២។

[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៥ កថាខណ្ឌទី១។

ដូច្នេះ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ត្រង់ចំណុចនេះត្រូវសរសេរពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗផ្សេងទៀត ព្រោះថាការសរសេរអំពីអង្គហេតុទាំងពីរនេះ គឺដើម្បីបង្កើតសិទ្ធិ។ ជាការពិតអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង ប៉ុន្តែដីការក្សាការពារអាចចេញបានមុនការដាក់ពាក្យបណ្តឹង ត្រង់នេះមានន័យថា សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ ត្រូវសរសេរយ៉ាងណាឱ្យអត្ថន័យ និងខ្លឹមសារដូចជាការសរសេរអង្គហេតុដែលជាមូលហេតុនៃការទាមទារ។[30] បើម្ចាស់បំណុលអាចមើលឃើញអង្គហេតុតវ៉ាដែលនឹងអះអាង ដោយកូនបំណុលជាចំណុចប្រសើរ ដោយម្ចាស់បំណុលត្រូវបញ្ចូលនូវការបដិសេធអំពីអង្គហេតុតវ៉ានោះ ព្រោះមានប្រយោជន៍សម្រាប់តុលាការក្នុងការចេញដីកាសម្រេច និងសម្រេចអំពីចំនួនប្រាតិភោគ។

**២.៤. ភាពចាំបាច់នៃការរក្សាការពារ**

ផ្អែកតាមមាត្រា៥៤៥ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវសរសេរនូវភាពចាំបាច់នៃការរក្សាការពារ។ ភាពចាំបាច់នៃការរក្សាការពារ គឺជាអង្គហេតុទាំងឡាយណាដែលបញ្ជាក់អំពីការបារម្ភរបស់ម្ចាស់បំណុលថា មិនអាចធ្វើបាន ឬមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

**ឧទាហរណ៍៖** កូនបំណុលកំពុងតែប្រកាសលក់ដី ឬម្ចាស់បំណុលមិនបានស្គាល់ទ្រព្យសម្បត្តិមានតម្លៃផ្សេងទៀតរបស់កូនបំណុលក្រៅពីសម្បត្តិទាំងនេះ ជាអាទិ៍។

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន មិនត្រឹមតែត្រូវផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកលើភាពចាំបាច់នៃការរក្សាការពារផងដែរ។ មានន័យថា មានតែក្នុងករណីដែលការអនុវត្តដោយបង្ខំនាពេលអនាគតនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ បើបណ្ដោយឱ្យស្ថានភាពបច្ចុប្បន្នស្ថិតនៅដដែលប៉ុណ្ណោះទេ ដែលត្រូវចាត់ទុកថាការរក្សាការពារមានភាពចាំបាច់។[31]

ការរក្សាការពារត្រូវបានចាត់ទុកថាមានភាពចាំបាច់ នៅក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាបរិមាណ ឬជាគុណភាព ឬនឹងមានតែទ្រព្យសម្បត្តិដែលពិបាកប្ដូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំប៉ុណ្ណោះដែលនៅសល់ ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ ជាអាទិ៍។ ការរក្សាការពារ ក៏ត្រូវបានចាត់ទុកថាមានភាពចាំបាច់ដែរ នៅក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្ដូរលំនៅឋានជាច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញ

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៥។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៥ កថាខណ្ឌទី១។

ថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំ។ ការកំណត់នេះ មិនត្រូវកម្រិតតែត្រឹមអ្វីដែលផ្អែកលើទង្វើផ្ទាល់ខ្លួនរបស់កូនបំណុលតែប៉ុណ្ណោះទេ។

ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំទំនងជានឹងត្រូវធ្វើនៅបរទេស នោះការរក្សាការពារត្រូវចាត់ទុកថាមានភាពចាំបាច់។ ឧទាហរណ៍ ករណីដែលកូនបំណុលបានបង្ហាញសញ្ញានៃការចាត់ចែងទ្រព្យសម្បត្តិ និងការធ្វើអន្តោប្រវេសន៍ទៅបរទេស ជាអាទិ៍។

ទោះបីជា ក្នុងករណីដែលបានបំពេញតាមលក្ខខណ្ឌទូទៅហើយក៏ដោយ ក៏ភាពចាំបាច់នៃការរក្សាការពារអាចនឹងត្រូវបានបដិសេធដែរ។ ជាក់ស្ដែង ករណីដែលសិទ្ធិលើបំណុល មានភ្ជាប់នឹងសិទ្ធិប្រាតិភោគប្រត្យក្សគ្រប់គ្រាន់ហើយ ឬករណីដែលសិទ្ធិលើបំណុល បំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយគ្មានលក្ខខណ្ឌ។

**កថាភាគទី៣. ឯកសារដែលត្រូវភ្ជាប់ជាមួយ**

នៅក្នុងពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា ឯកសារសម្រាប់ធ្វើសេចក្ដីបញ្ជាក់ដំបូង ឯកសារសម្រាប់បញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ឯកសារសម្រាប់បញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន និងឯកសារផ្សេងៗទៀត។

**៣.១. ឯកសារសម្រាប់ធ្វើសេចក្ដីបញ្ជាក់ដំបូង**

ពាក្យ "សេចក្ដីបញ្ជាក់ដំបូង" សំដៅលើភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។[32] សេចក្ដីបញ្ជាក់ដំបូងជារបៀបទទួលស្គាល់អង្គហេតុ ដោយប្រើភស្តុតាងដែលងាយពិនិត្យបានភ្លាមៗ ហេតុនេះ ភស្តុតាងដែលប្រើពេលច្រើនដូចជាលទ្ធផលកោសល្យវិច័យ ឬការសាកសួរសាក្សី មិនត្រូវបានទទួលស្គាល់ថាជាសេចក្ដីបញ្ជាក់ដំបូងនោះទេ។

នៅក្នុងលិខិតសេចក្ដីបញ្ជាក់ដំបូង គប្បីសរសេរអំពីចំណុចសំខាន់ៗ ដូចជា ខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ សិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ភាពចាំបាច់នៃការរក្សាការពារ ស្ថានភាពបច្ចុប្បន្នរបស់កូនបំណុល ភស្តុតាង និងសំណូមពរ ជាដើម។ ឯកសារសម្រាប់បញ្ជាក់ដំបូងគឺជាឯកសារជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន នៅពេលធ្វើសេចក្ដីបញ្ជាក់ដំបូង។ ឯកសារសម្រាប់ធ្វើសេចក្ដីបញ្ជាក់ដំបូងដែលត្រូវភ្ជាប់ជាមួយពាក្យសុំនោះ មានដូចជា ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ និងឯកសារដែលបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារ។[33]

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា១៣១។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣។

**៣.១.១. ឯកសារបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ**

អ្នកដាក់ពាក្យសុំដីកាសម្រេចចាត់ចែងរក្សាការពារ (ម្ចាស់បំណុល) ចាំបាច់ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ។ ដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូងចំពោះសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារអ្នកដាក់ពាក្យសុំត្រូវធ្វើការបញ្ជាក់ពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ភស្តុតាងដែលត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូងគឺជាឯកសារ។

**ឧទាហរណ៍៖** ឯកសារដែលបញ្ជាក់ពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ គឺមានទៅតាមប្រភេទនៃរឿងក្ដីដូចជារឿងក្ដីទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ គឺលិខិតកិច្ចសន្យាខ្ចីបរិភោគ រឿងក្ដីដែលទាក់ទងនឹងការទាមទារឱ្យប្រគល់អចលនវត្ថុ គឺប័ណ្ណកម្មសិទ្ធិ ហើយរឿងក្ដីដែលទាក់ទងនឹងការឱ្យប្រគល់ផ្ទះដោយសារតែការបញ្ចប់នូវភតិសន្យា ឬការបញ្ចប់កិច្ចសន្យាខ្ចីប្រើ គឺលិខិតភតិសន្យា ឬកិច្ចសន្យាខ្ចីប្រើជាដើម។

ផ្ទុយទៅវិញ បើម្ចាស់បំណុលខកខានមិនបានដាក់ឯកសារដែលបញ្ជាក់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារទេ គឺចៅក្រមមិនអាចដឹង ឬអាចកំណត់អំពីសិទ្ធិរបស់ម្ចាស់បំណុលបានឡើយ។ ការខ្វះឯកសារនេះ គឺខុសពីលក្ខខណ្ឌចាំបាច់ក្នុងការដាក់ពាក្យសុំ ដែលជាហេតុនាំឱ្យចៅក្រមត្រូវលើកចោលនូវពាក្យសុំនេះ ដោយដីកាសម្រេច។[34]

**៣.១.២. ឯកសារបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារ**

ក្រៅពីឯកសារបញ្ជាក់ដំបូងអំពី សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានការពារ មានលក្ខខណ្ឌមួយទៀតដែលចៅក្រមត្រូវពិចារណាដែរថា តើមានភាពចាំបាច់នៃការរក្សាការពារដែរឬទេ។ មានន័យថាចៅក្រមមិនអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ដោយសំអាងទៅលើត្រឹមលក្ខខណ្ឌ សិទ្ធិ ឬទំនាក់ទំនងគតិយុត្តតែមួយប៉ុណ្ណោះទេ គឺចាំបាច់ត្រូវមានលក្ខខណ្ឌនៃភាពចាំបាច់នៃការរក្សាការពារ ទើបចៅក្រមអាចចេញដីកាសម្រេចបាន។ ភាពចាំបាច់នៃការរក្សាការពារនេះ មានសារៈសំខាន់ណាស់ដែលមិនអាចខ្វះបាន ព្រោះថាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុល។

**ឧទាហរណ៍៖** ឯកសារបញ្ជាក់អំពីភាពចាំបាច់ដែលម្ចាស់បំណុលត្រូវសរសេរមានដូចជា ករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងនឹងធ្លាក់ថ្លៃជាបរិមាណ ឬជាគុណភាព ឬនឹងមានតែទ្រព្យសម្បត្តិដែលពិបាកដូរជាប្រាក់នៅក្នុងការអនុវត្តដោយបង្ខំតែប៉ុណ្ណោះដែលនៅសល់ដោយសារតែការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការបំបាត់ជាអាទិ៍។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១។

ដូច្នេះ ម្ចាស់បំណុលដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចាំបាច់ត្រូវធ្វើសេចក្ដីបញ្ជាក់ជំបូងពីភាពចាំបាច់នេះ គឺត្រូវផ្ដល់ឯកសារដែលត្រូវបញ្ជាក់ពីភាពចាំបាច់នៃការរក្សាការពារដោយសរសេរពីមូលហេតុ និងស្ថានភាពផ្សេងៗ ដែលកូនបំណុលរបស់ខ្លួនមានដើម្បីបង្ហាញពីភាពចាំបាច់របស់ខ្លួន ដើម្បីធ្វើការរក្សាការពារ (ធ្វើឱ្យខ្លួនមានការបារម្ភពីសិទ្ធិរបស់ខ្លួនចំពោះកូនបំណុល) ដើម្បីឱ្យចៅក្រមធ្វើការពិចារណាឈានទៅដល់ការចេញដីកាសម្រេច។

**៣.២. ឯកសារសម្រាប់បញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ**

អ្នកដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្នមានសិទ្ធិជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដើម្បីធ្វើសកម្មភាពបណ្ដឹងជំនួសខ្លួន។ អ្នកតំណាងដោយអាណត្តិធ្វើសកម្មភាពដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមានអ្នកតំណាងដោយអាណត្តិ អ្នកដាក់ពាក្យសុំដីកាសម្រេចត្រូវដាក់ឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះភ្ជាប់មកជាមួយពាក្យសុំ។ លិខិតបញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះ ត្រូវមានលិខិតប្រគល់សិទ្ធិឱ្យអ្នកតំណាងដោយអាណត្តិ ដែលក្នុងលិខិតនេះមានហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។ ម៉្យាងវិញទៀត លិខិតបញ្ជាក់អំពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិនេះ មានសារៈសំខាន់ណាស់សម្រាប់ចៅក្រមក្នុងការកំណត់ពីទំហំសិទ្ធិរបស់អ្នកតំណាងនោះ ដើម្បីធានាស្ថេរភាពនៃនីតិវិធីនៃរឿងក្ដី។ ក្នុងករណីដែលគ្មានលិខិតប្រគល់សិទ្ធិ អាចជាហេតុនាំឱ្យមានការប្រើប្រាស់នូវសិទ្ធិហួសពីឆន្ទៈរបស់ភាគីផ្ទាល់ ដែលអាចនាំឱ្យរឿងក្ដីគ្មានស្ថេរភាព ជាពិសេសនោះអាចប៉ះពាល់ទៅដល់ផលប្រយោជន៍ និងសិទ្ធិរបស់ភាគីផ្ទាល់តែម្ដង។

បើគ្មានលិខិតបញ្ជាក់ពីសិទ្ធិតំណាងដោយអាណត្តិទេ តុលាការមិនអាចលើកពាក្យសុំនេះបានទេ គឺគ្រាន់តែឱ្យភាគីកែតម្រូវ ដោយណែនាំឱ្យភាគីដាក់លិខិតនេះ។ ផ្ទុយទៅវិញ បើភាគីមិនបានដាក់ទៀត តុលាការមិនអាចទទួលស្គាល់អ្នកតំណាងដោយអាណត្តិនោះទេ គឺភាគីត្រូវមកធ្វើសកម្មភាពក្នុងនីតិវិធីរក្សាការពារនេះដោយខ្លួនឯង។

អ្នកតំណាងដោយអាណត្តិ ជាគោលការណ៍ជាមេធាវី លើកលែងតែក្នុងលក្ខខណ្ឌមួយចំនួន ដូចជាករណីដែលច្បាប់ បានអនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ឬករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬស្ថាប័នរដ្ឋដទៃទៀត និងដែលស្ថាប័ននោះ ឬ អ្នកតំណាងនៃស្ថាប័ននោះតែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង ឬករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្ដីដែលតម្លៃកម្មវត្ថុនៃបណ្ដឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល។[35]

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១។

**ឧទាហរណ៍៖** ឯកសារដែលបញ្ជាក់ពីភាពតំណាងដោយអាណត្តិ គឺលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ។

ដូច្នេះ លិខិតប្រគល់សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ គឺមានផលប្រយោជន៍សម្រាប់តុលាការក្នុងការចាត់ការនីតិវិធីរក្សាការពារប្រកបដោយយុត្តិធម៌ និងស្ថេរភាពសម្រាប់ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីនៃនីតិវិធីចាត់ចែងរក្សាការពារផងដែរ។

**៣.៣. ឯកសារសម្រាប់បញ្ជាក់អំពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន**

ខ្លឹមសារមាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ខ ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវសរសេរនូវចំណុចខ្លឹមសារនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលអ្នកដាក់ពាក្យសុំទាមទារដែលរួមមានប្រភេទដីកាសម្រេចកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងគោលបំណងនៃការរក្សាការពារ។ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ក៏ត្រូវមានឯកសារដើម្បីបញ្ជាក់ភ្ជាប់ជាមួយពាក្យសុំ ពីព្រោះថាដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូស លើកលែងតែករណីចលនវត្ថុ។

ករណីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នជាអចលនវត្ថុ ឬសិទ្ធិលើបំណុល តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយកំណត់ជាក់លាក់នូវកម្មវត្ថុនេះ។

ឯកសារបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ត្រូវមានភ្ជាប់មកជាមួយនឹងពាក្យសុំដីកាសម្រេច ពីព្រោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននោះ។ ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយកំណត់ជាក់លាក់នូវកម្មវត្ថុនោះ។[36] ជាក់ស្តែង ឯកសារសម្រាប់បញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ននេះ អ្នកដាក់ពាក្យសុំត្រូវមានឯកសារដែលជាលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់កូនបំណុលចំពោះទ្រព្យសម្បត្តិនោះ ពោលគឺបញ្ជាក់ថាទ្រព្យសម្បត្តិនោះ គឺកូនបំណុលជាកម្មសិទ្ធិករពិតប្រាកដមែន ពុំមែនជារបស់តតិយជន ឬជនដទៃទៀតឡើយ។

**ឧទាហរណ៍៖** អ្នកដាក់ពាក្យសុំអាចបញ្ជាក់ថា ដី ផ្ទះ នោះជាកម្មសិទ្ធិរបស់កូនបំណុល ដែលមានការបញ្ជាក់ពីមន្ត្រីសុរិយោដី ឬប័ណ្ណកម្មសិទ្ធិ ឬមានការបញ្ជាក់ពីមេភូមិ មេឃុំ ចៅសង្កាត់។ល។

**៣.៤. ឯកសារផ្សេងៗ**

ក្រៅពីឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង ឯកសារសម្រាប់បញ្ជាក់ពីសិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ ឯកសារសម្រាប់បញ្ជាក់ពីកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន តុលាការអាចទាមទារឯកសារផ្សេងៗទៀត ដើម្បីឱ្យអ្នកដាក់ពាក្យសុំភ្ជាប់មកជាមួយ ដូចជាឯកសារបញ្ជាក់ពីភាគី លិខិតបញ្ជាក់របស់នីតិបុគ្គលដើម្បី

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៦។

បញ្ជាក់ពីសមត្ថភាពរបស់ភាគី ក្នុងករណីដែលម្ចាស់បំណុលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិបត្ថម្ភ ត្រូវមានឯកសារបញ្ជាក់ពីអ្នកតំណាងដែលច្បាប់បានកំណត់ភ្ជាប់មកជាមួយពាក្យសុំ។

ឯកសារនៃសេចក្តីបញ្ជាក់ដំបូង : ចំពោះចំណុចទី៣.៣ និងចំណុចទី៣.៤ ដោយសារថាអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ដូច្នេះអ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់ជាមួយនឹងពាក្យសុំជាលាយលក្ខណ៍អក្សរនូវឯកសារដើម្បីធ្វើសេចក្តីបញ្ជាក់ដំបូង។[37] ម្យ៉ាងវិញទៀត អ្នកតំណាងដោយអាណត្តិដែលមានសិទ្ធិតំណាងនៅក្នុងបណ្តឹងអំពីសិទ្ធិដែលត្រូវរក្សាការពារ ក៏ត្រូវមានសិទ្ធិតំណាងនៅក្នុងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែរ។[38] សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។

## កថាភាគទី៤. សោហ៊ុយ

### ៤.១. ពន្ធដាក់ពាក្យសុំ

ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវបង់ពន្ធចំនួន ៥ ០០០ (ប្រាំពាន់) រៀល។[39] ក្នុងករណីដែលម្ចាស់បំណុលមិនបានបង់ពន្ធដាក់ពាក្យសុំ តុលាការត្រូវបង្គាប់ឱ្យម្ចាស់បំណុលបង់ពន្ធក្នុងអំឡុងពេលសមរម្យមួយ។[40] ម្យ៉ាងវិញទៀត បើសិនម្ចាស់បំណុលមិនបានបង់ពន្ធដាក់ពាក្យសុំក្នុងអំឡុងពេលដែលតុលាការបានបង្គាប់ តុលាការត្រូវលើកពាក្យសុំនោះចោលដោយដីកាសម្រេច។[41]

### ៤.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្តីតុលាការដែលភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្តីត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ ចំពោះក្នុងរឿងរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ បន្ថែមពីលើពន្ធដាក់ពាក្យសុំសម្រាប់តុលាការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀត។ល។

**ឧទាហរណ៍៖** សោហ៊ុយសម្រាប់ការបញ្ជូនដីកាសម្រេចទៅកូនបំណុល។[42]

### ៤.៣. បន្ទុកនៃប្រាក់ប្រដាប់ក្តី

នៅពេលដែលការសម្រេចសេចក្តីលើកចោលនូវពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានធ្វើឡើង សេចក្តីសម្រេចនោះត្រូវកំណត់អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី (បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចនេះ

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤១ កថាខណ្ឌទី៣។
[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី២។
[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៧ កថាខណ្ឌទី១។
[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី១។
[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៧៨ កថាខណ្ឌទី២។
[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៣។

អាចត្រូវបានប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដូច្នេះសេចក្ដីសម្រេចនេះឆ្លើយតបទៅនឹងសេចក្ដីសម្រេចដែលបញ្ចប់រឿងក្ដីនៅតុលាការ។[43]

ពេលដែលដីកាសម្រេចទទួលស្គាល់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវបានធ្វើមានលទ្ធភាពពីរផ្លូវៈ

ទស្សនៈទី១ គឺថាដីកាសម្រេចនេះមិនត្រូវកំណត់បន្ទុកនៃប្រាក់ប្រដាប់ក្ដី (បណ្ដឹងតវ៉ាចំពោះដីកាសម្រេចនេះអាចត្រូវបានដាក់ទៅតុលាការដែលចេញដីកាសម្រេច និងដីកាសម្រេចនេះមិនឆ្លើយតបទៅនឹងការសម្រេចសេចក្ដីដែលបញ្ចប់រឿងក្ដីនៅក្នុងតុលាការ។[44]

ទស្សនៈទី២ គឺថាដីកាសម្រេចដែលទទួលស្គាល់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នត្រូវកំណត់នូវប្រាក់ប្រដាប់ក្ដី។

**កថាភាគទី៥. ការពិនិត្យនៅលើពាក្យសុំដីកាសម្រេច**

ចៅក្រមដែលទទួលបន្ទុកចាត់ការទៅលើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ចៅក្រមត្រូវធ្វើការពិនិត្យទៅលើចំណុចដូចតទៅៈ

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ
- សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ
- ភាពចាំបាច់នៃការរក្សាការពារ (មាត្រា៥៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម៉្យាងវិញទៀត តុលាការនឹងធ្វើការពិនិត្យបន្ថែមទៅលើសមត្ថកិច្ចតុលាការ គឺថានៅក្នុងពាក្យសុំនោះអ្នកដាក់ពាក្យសុំបានដាក់មកតុលាការដែលមានសមត្ថកិច្ច ឬមិនមាន។ លើសពីនេះទៅទៀត តុលាការធ្វើការពិនិត្យថាតើអ្នកដាក់ពាក្យសុំបានបង់ពន្ធដាក់ពាក្យសុំហើយឬនៅ។

ក្នុងករណីដែលអ្នកសុំមិនទាន់បានបង់ពន្ធ តុលាការនឹងចេញដីកាបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យសុំដោយកំណត់អំឡុងពេលសមរម្យមួយ ប្រសិនបើអ្នកសុំមិនបានបង់ពន្ធដាក់ពាក្យសុំនៅក្នុងអំឡុងពេលនោះ តុលាការនឹងលើកពាក្យសុំចោលដោយដីកាសម្រេច។ ជាក់ស្ដែង នៅក្នុងករណីដែលអ្នកដាក់ពាក្យសុំបានដាក់ពាក្យសុំខុសសមត្ថកិច្ចតុលាការ តុលាការដែលមិនមានសមត្ថកិច្ចត្រូវផ្ទេររឿងក្ដីនោះទៅឱ្យតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬឆន្ទានុសិទ្ធិរបស់តុលាការ។ ក្នុងករណីដែលនៅក្នុងពាក្យសុំសរសេរខ្វះខាតនូវចំណុចមួយណា

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៦៥ កថាខណ្ឌទី១។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

ឬសរសេរផ្ទុយពីបញ្ញត្តិមាត្រា៥៤១ កថាខណ្ឌទី១ តុលាការត្រូវបង្គាប់ឱ្យអ្នកដាក់ពាក្យសុំកែតម្រូវនូវចំណុចខ្វះខាតនោះ ក្នុងអំឡុងពេលសមរម្យមួយ។

**កថាភាគទី៦. ប្រាតិភោគ និងប្រាក់រំដោះ**

**៦.១. ប្រាតិភោគ**

ដីកាសម្រេចរក្សាការពារអាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន។ ការឱ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ ត្រូវអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ។ ប្រាតិភោគ សំដៅដល់មធ្យោបាយមួយដែលជាលក្ខខណ្ឌក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដើម្បីធានាការសងការខូចខាតចំពោះកូនបំណុល ករណីដែលការរឹបអូសជាបណ្ដោះអាសន្នមានភាពខុសពីការពិត ។ ម៉្យាងវិញទៀត ជំនួសឱ្យការដាក់ប្រាតិភោគជាមុន តុលាការក៏អាចបង្គាប់ឱ្យដាក់ប្រាតិភោគជាលក្ខខណ្ឌសម្រាប់ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នផងដែរ។

**៦.១.១. គោលបំណងនៃប្រាតិភោគ**

លក្ខណៈពិសេសនៃនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺតុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុបាន ដោយពុំចាំបាច់សួរកូនបំណុលដោយគ្រាន់តែឆ្លងកាត់ការធ្វើសេចក្ដីបញ្ជាក់ដំបូងជាការស្រេច។ ប៉ុន្តែដីកាសម្រេចរក្សាការពារ ក្នុងករណីខ្លះត្រូវប្រឈមមុខនឹងការលុបចោលទៅវិញ ត្រង់ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ផលប្រយោជន៍របស់កូនបំណុល គឺបណ្ដាលឱ្យកូនបំណុលខូចខាតជាច្រើន។ ដូច្នេះ ដើម្បីឆ្លើយតបនឹងការខូចខាតរបស់កូនបំណុលដែលកើតឡើងជាយថាហេតុទើបតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ លើសពីនេះទៅទៀត ការដាក់ប្រាតិភោគរបស់ម្ចាស់បំណុលក្នុងបំណងទប់ស្កាត់ការប្រើប្រាស់សិទ្ធិហួសប្រមាណ។

ជាក់ស្ដែងគោលបំណងនៃប្រាតិភោគ គឺដើម្បីធានាសងការខូចខាត និងសំណងជម្ងឺចិត្ត។ ម៉្យាងវិញទៀត កូនបំណុលនឹងមានសិទ្ធិជាអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត។ ប្រាតិភោគមានគោលបំណងទប់ស្កាត់ ឬបញ្ចៀសការប្រើប្រាស់សិទ្ធិដោយបំពានរបស់ម្ចាស់បំណុល ពោលគឺម្ចាស់បំណុលមិនអាចធ្វើការរក្សាការពារទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលតាមអំពើចិត្តនោះទេ ហេតុនេះ ប្រាតិភោគក៏ជាលក្ខខណ្ឌមួយដែលត្រូវបំពេញដោយម្ចាស់បំណុលផងដែរ ប្រសិនបើតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ។

ការដាក់ប្រាតិភោគ អាចជាលក្ខខណ្ឌនៃការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬជាលក្ខខណ្ឌនៃការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ក្នុងករណី តុលាការយល់ថាសំណុំរឿងរក្សាការពារណាមួយមានភាពចាំបាច់ ត្រូវដាក់ប្រាតិភោគហើយការដាក់ប្រាតិភោគជាលក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ គឺតុលាការនឹងចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ ដោយកំណត់អំពីអំឡុងពេលនៃការដាក់ចំនួន

ប្រាតិភោគ ទីកន្លែងដាក់ប្រាតិភោគ វិធីដាក់ប្រាតិភោគ និងទណ្ឌកម្ម ក្នុងករណីមិនគោរពតាមការកំណត់។ ក្នុងករណីម្ចាស់បំណុលបានអនុវត្តតាមការកំណត់របស់តុលាការ (បានដាក់ប្រាតិភោគ) តុលាការនឹងចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តាមការស្នើសុំរបស់ម្ចាស់បំណុល។

**៦.១.២. ចំនួននៃប្រាតិភោគ**

ករណីតុលាការបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការនឹងពិចារណាអំពីចំនួនប្រាតិភោគផ្អែកលើមាត្រដ្ឋានមួយចំនួនដូចជា៖

(១) ការខូចខាតដែលអាចកើតមានឡើងចំពោះកូនបំណុល (បច្ចុប្បន្ន និងអនាគត)

(២) ទំហំនៃការខូចខាត

(៣) លក្ខខណ្ឌដែលម្ចាស់បំណុលនឹងទទួលបានរក្សាការពារ

(៤) សេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល

(៥) ប្រភេទកម្មវត្ថុនៃការរក្សាការពារ (ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ឬនាវា ជាអាទិ៍)។

មូលដ្ឋានខាងលើនេះ ជាមាត្រដ្ឋានក្នុងការពិចារណាសម្រាប់កំណត់ប្រាតិភោគ បើសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលពុំមានភាពច្បាស់លាស់ខ្លាំង ចំនួនប្រាតិភោគនឹងមានចំនួនច្រើន បើសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលមានភាពច្បាស់លាស់ខ្លាំង ចំនួនប្រាតិភោគនឹងមានចំនួនទាប និងអាស្រ័យទៅលើប្រភេទកម្មវត្ថុ បើជាអចលនវត្ថុ ហើយជាការរឹបអូសជាបណ្ដោះអាសន្ន ផលប៉ះពាល់ចំពោះកូនបំណុលមានកម្រិតទាប ប៉ុន្តែបើជាចលនវត្ថុដែលធ្វើពាណិជ្ជកម្ម ដូចជា រថយន្តដឹកជញ្ជូនអ្នកដំណើរ ឬរថយន្តអាជីវកម្ម នៅពេលធ្វើការរឹបអូសជាបណ្ដោះអាសន្ននឹងអាចនាំឱ្យអាជីវកម្មរបស់កូនបំណុលជាប់គាំង។ ដោយហេតុថា ផលប៉ះពាល់ធ្ងន់បែបនេះ ជាទូទៅនឹងនាំឱ្យចំនួនប្រាតិភោគមានទំហំធំ ឬស្មើនឹងកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន។

នៅពេលដែលតុលាការសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ តុលាការក៏ត្រូវពិចារណាឱ្យបានល្អិតល្អន់លើផលប៉ះពាល់ និងឥទ្ធិពលដែលអាចនាំឱ្យមានការខូចខាតជាយថាហេតុ ដោយសារការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ដូច្នេះ តុលាការត្រូវសាកល្បងធ្វើការវាយតម្លៃលើការខូចខាត ដោយមានការប្រយ័ត្នប្រយែងបំផុតដែលនឹងអាចកើតមានឡើងចំពោះកូនបំណុល។ ម្យ៉ាងវិញទៀត តុលាការក៏ត្រូវគិតដល់លក្ខខណ្ឌសំខាន់ៗដែលម្ចាស់បំណុលត្រូវទទួលបានការការពារ។ បន្ទាប់ពីតុលាការពិចារណាលើការខូចខាតនាពេលអនាគត តុលាការក៏ត្រូវពិចារណាទៅដល់ការធ្វើសេចក្ដីបញ្ជាក់ដំបូង។

ដូច្នេះ មុននឹងចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺតុលាការគ្រាន់តែពិនិត្យលើឯកសារនៃ

សេចក្តីបញ្ជាក់ដំបូង ឬ/និង សួរម្ចាស់បំណុល រួចបញ្ជូនដីកាសម្រេចរក្សាការពារនោះទៅឱ្យកូនបំណុល។ មានន័យថា "បើការបញ្ជាក់ដំបូងមានលក្ខណៈរឹងមាំ នោះចំនួននៃប្រាតិភោគ គឺទាប ឬតិចតួច"។ ផ្ទុយទៅវិញ "បើការបញ្ជាក់ដំបូងពុំមានលក្ខណៈរឹងមាំ នោះតម្រូវការនៃការដាក់ប្រាតិភោគត្រូវមានកម្រិតខ្ពស់ ឬច្រើន"។ លើសពីនេះទៅទៀត តុលាការត្រូវពិចារណាដល់ប្រភេទនៃកម្មវត្ថុនៃការចេញដីការក្សាការពារអាចជាចលនវត្ថុ អចលនវត្ថុ ឬសិទ្ធិលើបំណុល។ ផ្អែកលើចំណុចសំខាន់ៗទាំងប៉ុន្មានខាងលើនេះ ទើបបង្កលក្ខណៈងាយស្រួលដល់តុលាការក្នុងការកំណត់ចំនួនប្រាតិភោគដែលតម្រូវឱ្យម្ចាស់បំណុលដាក់។

**៦.១.៣. វិធីនៃការដាក់ប្រាតិភោគ**

ចំនួនប្រាតិភោគ គឺជាប្រាក់ដែលតុលាការកំណត់ជាក់លាក់ ហេតុនេះ មានតែចំនួនទឹកប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ហើយតុលាការទទួលស្គាល់ថាសមរម្យ ឬទីតាំងដែលតុលាការបានកំណត់ (មាត្រា៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប៉ុណ្ណោះ ដូចជាមូលប្បទានបត្រ ជាអាទិ៍ ទើបអាចចាត់ទុកជាការតម្កល់ប្រាតិភោគ មានន័យថា ម្ចាស់បំណុលមិនអាចយកដីផ្សេងមកដាក់ធានា ដោយចាត់ទុកថាជាប្រាតិភោគនោះទេ ទោះបីដីនោះមានតម្លៃថ្លៃជាងដីដែលជាកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬលើសសិទ្ធិលើបំណុលដែលត្រូវរក្សាការពាររបស់ម្ចាស់បំណុលក៏ដោយ។ វិធីដាក់ប្រាតិភោគត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

ក្នុងករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគមុនពេលចេញដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ការដាក់ប្រាតិភោគជាលក្ខខណ្ឌមួយដើម្បីចេញដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះ។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនចេញដីការក្សាការពារ។ ម្យ៉ាងវិញទៀត តុលាការមិនចេញដីកាសម្រេចទេរហូតដល់ប្រាតិភោគត្រូវបានដាក់។

ក្នុងករណីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលភ្ជាប់ជាមួយនូវការបង្គាប់ឱ្យដាក់ប្រាតិភោគ ការដាក់ប្រាតិភោគ គឺជាលក្ខខណ្ឌមួយដើម្បីអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ដូច្នេះម្ចាស់បំណុលត្រូវដាក់ប្រាតិភោគមុនពេលអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលមិនអាចមានលទ្ធភាពអនុវត្តដីកាសម្រេចរក្សាការពារបានឡើយ រហូតដល់ពេលដែលខ្លួនបានដាក់ប្រាតិភោគ។

លើសពីនេះទៅទៀត ប្រាតិភោគអាចត្រូវបានដាក់ទៅតុលាការអនុវត្តការរក្សាការពារ ឬតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ។ ចំពោះការតម្កល់ ឬការផ្ញើ គឺជារបបមួយដែលមានករណីយកិច្ចដាក់ប្រាតិភោគដាក់ប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដើម្បីឱ្យអ្នកមានសិទ្ធិលើប្រាតិភោគនោះ មានសិទ្ធិទាមទារយកវត្ថុដែលតម្កល់ទុកនោះបាន។

ករណីនេះមាត្រា៧៣ កថាខណ្ឌទី១ បានចែងថា "អ្នកមានសិទ្ធិលើប្រាតិភោគក្នុងមាត្រានេះ សំដៅទៅ

លើបុគ្គលដែលទទួលការផ្តល់ប្រាតិភោគ ដើម្បីជាប្រយោជន៍របស់ខ្លួន”។

ចំពោះវិធីនៃការដាក់ប្រាតិភោគលម្អិតនឹងមានចែងនៅក្នុងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងសេចក្តីព្រាងនៅឡើយដែលនឹងត្រូវបញ្ចប់នាពេលដ៏ខ្លីខាងមុខនេះ។

**៦.១.៤. អំឡុងពេលនៃការដាក់ប្រាតិភោគ**

តុលាការត្រូវកំណត់អំឡុងពេលសមរម្យមួយនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដើម្បីឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។

**៦.២. ប្រាក់រំដោះ**

ប្រាក់រំដោះ សំដៅលើប្រាក់ដែលកូនបំណុលត្រូវផ្ញើនៅតុលាការ សម្រាប់ជំនួសឱ្យទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន និងដើម្បីទទួលបានការលុបចោលនូវការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[45]

**៦.២.១. គោលបំណងនៃប្រាក់រំដោះ**

ការរឹបអូសជាបណ្តោះអាសន្ន គឺដើម្បីរក្សាការពារនូវការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ នៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ពីចំនួននៃប្រាក់រំដោះ ដើម្បីទុកជាលទ្ធភាពឱ្យកូនបំណុលបានយកប្រាក់រំដោះ ដែលជាប្រាក់ផ្ញើទុកនៅតុលាការ ក្នុងការទទួលបានការរួចផុតពីការអនុវត្តពីការរឹបអូសជាបណ្តោះអាសន្ន។ មានន័យថា ក្នុងករណីដែលកូនបំណុលបានផ្ញើទឹកប្រាក់តាមចំនួនដែលតុលាការបានកំណត់នៅតុលាការ។

**ឧទាហរណ៍៖** សិទ្ធិលើបំណុលមានចំនួន ១០០ ០០០ ដុល្លារ ហើយអចលនវត្ថុដែលត្រូវរឹបអូសមានតម្លៃ ២០០ ០០០ ដុល្លារ នោះប្រាក់រំដោះ ត្រូវកំណត់ចំនួន ១០០ ០០០ ដុល្លារ។ ផ្ទុយទៅវិញ ប្រសិនបើសិទ្ធិលើបំណុលមានចំនួន ១០០ ០០០ដុល្លារ ហើយអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមានតម្លៃ ៨០ ០០០ ដុល្លារ នោះប្រាក់រំដោះត្រូវកំណត់ចំនួន ៨០ ០០០ ដុល្លារ។

ក្នុងករណីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយមិនសម្រេច ឬកំណត់អំពីចំនួនប្រាក់រំដោះនាំឱ្យសេចក្តីសម្រេចនោះ ជាសេចក្តីសម្រេចដែលពុំទាន់មានភាពត្រឹមត្រូវពេញលេញ និងបំពានសិទ្ធិស្របច្បាប់របស់កូនបំណុលនឹងក្លាយជាមូលហេតុនៃការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលមិនបានកំណត់អំពីចំនួនប្រាក់រំដោះ ជាការកើតឡើងនូវអំពើអនីត្យានុកូល ហេតុនេះកូនបំណុលអាចប្តឹងទាមទារសំណងពីតុលាការអំពីការធ្វេសប្រហែសបែបនេះ ដើម្បីឱ្យតុលាការទទួលខុសត្រូវចំពោះសំណង។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៧ កថាខណ្ឌទី១។

ដូច្នេះ ការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវបានលុបចោល ដែលជាហេតុដែលកូនបំណុលអាចចាត់ចែង ប្រើប្រាស់នូវទ្រព្យនោះបានដោយសេរី។ ម៉្យាងវិញទៀត ប្រសិនបើទ្រព្យនោះមានការកើនឡើងតម្លៃ កូនបំណុលអាចលក់បាន ចំណែកម្ចាស់បំណុលវិញ ទទួលបានចំនួនទឹកប្រាក់ដែលកូនបំណុលផ្ញើទុកនៅតុលាការនោះ ដោយម្ចាស់បំណុលត្រូវដាក់បណ្ដឹងអង្គសេចក្ដីថ្មីមួយវិញទៀត ក្នុងករណីដែលម្ចាស់បំណុលបានឈ្នះបណ្ដឹងអង្គសេចក្ដីនោះ ម្ចាស់បំណុលនឹងទទួលបាននូវប្រាក់រំដោះ។ ប្រាក់រំដោះ មានគោលបំណងការពារទៅដល់ផលប្រយោជន៍របស់ម្ចាស់បំណុល និងកូនបំណុល។

**៦.២.២. ចំនួននៃប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ន**

ចៅក្រម ជាអ្នកមានឆន្ទានុសិទ្ធិនៅក្នុងការសម្រេចពីទំហំ ឬចំនួននៃប្រាក់រំដោះ ដែលគ្មានមាត្រាណាមួយក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ច្បាស់លាស់ពីចំនួន នៃប្រាក់រំដោះពីការរឹបអូសជាបណ្ដោះអាសន្ននេះឡើយ។ ចំនួននៃប្រាក់រំដោះ គឺអាស្រ័យទៅលើទំហំ ឬតម្លៃនៃទ្រព្យសម្បត្តិរបស់កូនបំណុល ដែលម្ចាស់បំណុលស្នើសុំរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យសម្បត្តិនោះ។ ម៉្យាងវិញទៀត តុលាការអាចយកតម្លៃនៃទ្រព្យសម្បត្តិនោះ ធ្វើជាចំនួននៃប្រាក់រំដោះ ដោយសារតែប្រាក់រំដោះ ត្រូវចាត់ទុកជាប្រាក់ជំនួសទ្រព្យសម្បត្តិដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន។

## កថាភាគទី៧. នីតិវិធីនៃការពិនិត្យរឿងក្ដី និងការទាញហេតុផលដោយផ្ទាល់មាត់

### ៧.១. នីតិវិធីនៃការពិនិត្យរឿងក្ដី

**៧.១.១. ការពិនិត្យភស្តុតាងជាឯកសារ**

ម្ចាស់បំណុលត្រូវបង្ហាញឯកសារសេចក្ដីបញ្ជាក់ដំបូង ដើម្បីឱ្យតុលាការអាចសម្រេចថា តើសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារមានអត្ថិភាព ឬអត់ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ឬថាតើមានភាពចាំបាច់ដើម្បីចេញដីកាសម្រេចរក្សាការពារដែរឬទេ (មាត្រា៥៤១ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី)?

សេចក្ដីបញ្ជាក់ដំបូងត្រូវភ្ជាប់ជាមួយពាក្យសុំ ដើម្បីឱ្យតុលាការពិចារណា ដូច្នេះ ជាដំបូងតុលាការត្រូវពិនិត្យលើឯកសារអំពីសេចក្ដីបញ្ជាក់ដំបូងដូចជា ឯកសារថតចម្លងនៃកិច្ចសន្យា ប័ណ្ណកម្មសិទ្ធិលើទ្រព្យសម្បត្តិ មូលប្បទានបត្រ មតកសាសន៍ កំណត់ហេតុ រូបថត របាយការណ៍ដែលធ្វើឡើងដោយម្ចាស់បំណុល ឬឯកសារបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ ឬឯកសារផ្សេងទៀតដែលចាំបាច់សម្រាប់រក្សាការពារ។

**៧.១.២. ការសាកសួរម្ចាស់បំណុល**

តុលាការអាចហៅម្ចាស់បំណុលមកសាកសួរយកព័ត៌មានដែលទាក់ទងនឹងពាក្យសុំ ភស្តុតាងជាឯកសាររួមមាន លិខិតបញ្ជាក់ពីសិទ្ធិលើបំណុលបានដោយឱ្យម្ចាស់បំណុលបញ្ជាក់ឱ្យបានច្បាស់លាស់នូវគោលបំណង

ដែលចង់ឱ្យតុលាការចាត់ចែងរក្សាការពារ។[46] ការសាកសួរម្ចាស់បំណុលអាចឱ្យឆ្លើយជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ហើយតុលាការអាចអញ្ជើញម្ចាស់បំណុលមកតុលាការ និងសាកសួរម្ចាស់បំណុល ឬអាចឱ្យម្ចាស់បំណុលដាក់ឯកសារបន្ថែម។ នីតិវិធីនៃការសាកសួរម្ចាស់បំណុល គឺមិនធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូច្នេះ នីតិវិធីសាកសួរម្ចាស់បំណុលមិនត្រូវធ្វើជាសាធារណៈឡើយ។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ ហើយតុលាការមិនត្រូវធ្វើកំណត់ហេតុទេ។ ម្យ៉ាងវិញទៀត ការសួរម្ចាស់បំណុលគឺជាវិធីងាយៗសម្រាប់តុលាការក្នុងការធ្វើការបញ្ជាក់នូវខ្លឹមសារនៃពាក្យសុំ ឬភស្តុតាងជាឯកសារ។

**៧.១.៣. ការសាកសួរកូនបំណុល**

ការសម្រេចសេចក្តីចំពោះនីតិវិធីនៃការរក្សាការពារ តុលាការអាចសាកសួរកូនបំណុលបានផ្អែកលើមាត្រា ៥៣៥ កថាខណ្ឌទី១ មាត្រា១១៤ កថាខណ្ឌទី២។ នីតិវិធីនៃការសាកសួរកូនបំណុលគឺដូចគ្នានឹងនីតិវិធីនៃការសាកសួរម្ចាស់បំណុលដែរ ដូច្នេះនីតិវិធីនៃការសាកសួរកូនបំណុលមិនត្រូវធ្វើជាសាធារណៈឡើយ។ គេមិនចាំបាច់តម្រូវឱ្យមានវត្តមានភាគីទាំងពីរឡើយ ហើយតុលាការមិនត្រូវធ្វើកំណត់ហេតុទេ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រង់បទបញ្ញត្តិទូទៅ ការជំនុំជម្រះត្រូវធ្វើឡើងចំពោះមុខ ហើយគ្មានភាគីណាមួយត្រូវជំនុំជម្រះដោយមិនបានសាកសួរ ឬកោះហៅឡើយ ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខ ក៏ប៉ុន្តែនៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារមានចរិតលក្ខណៈដូចជា លក្ខណៈបណ្តោះអាសន្ន បន្ទាន់បង្ខំ បន្ទាប់បន្សំ និងសម្ងាត់ ហេតុដូច្នេះហើយគេមិនសូវសាកសួរកូនបំណុលទេ ព្រោះបារម្ភខ្លាចកូនបំណុលបង្កការលំបាកដល់ការអនុវត្ត ឬលួចបញ្ចៀសទ្រព្យសម្បត្តិដែលត្រូវចាត់ចែងរក្សាការពារ។ ប៉ុន្តែមានករណីលើកលែងមួយនៅក្នុងករណីនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ជាគោលការណ៍ដីកាសម្រេចមិនអាចចេញបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសាកសួរដែលកូនបំណុលអាចចូលរួមបាន ដោយសារតែការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នអាចជះឥទ្ធិពលយ៉ាងធំធេងដល់កូនបំណុល។[47] ការសាកសួរកូនបំណុល ជាវិធីមួយដែលអាចជួយការពារផលប្រយោជន៍ដល់កូនបំណុលដែរ ពេលតុលាការសាកសួរនូវព័ត៌មានមួយចំនួននោះ។ ក្នុងករណីដែលរឿងក្តីមានលក្ខណៈស្មុគស្មាញ ឬដីកាសម្រេចរក្សាការពារមើលទៅជះឥទ្ធិពលធំធេងចំពោះកូនបំណុល ឬមានលទ្ធភាពជឿជាក់ថា ការតវ៉ានឹងអាចធ្វើឡើងដោយកូនបំណុល តុលាការអាចសាកសួរកូនបំណុលដើម្បីផ្តល់ឱកាសឱ្យកូនបំណុលធ្វើការអះអាង ឬដាក់ឯកសារសម្រាប់ធ្វើសេចក្តីបញ្ជាក់ដំបូង។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៣៥ កថាខណ្ឌទី១ និងមាត្រា១១៤ កថាខណ្ឌទី២។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៨ កថាខណ្ឌទី៤។

### ៧.២. នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់

ដើម្បីដំណើរការនីតិវិធី តុលាការអាចជ្រើសរើសនីតិវិធីពីរ គឺ ការសាកសួរភាគី ឬការទាញហេតុផលផ្ទាល់មាត់ (មាត្រា១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងកិច្ចការរក្សាការពារ ភាគច្រើនតុលាការមិនសូវជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ទេ ពីព្រោះការទាញហេតុផលដោយផ្ទាល់មាត់មិនមែនជាលក្ខខណ្ឌរបស់ច្បាប់ឡើយ។ ប៉ុន្តែក្នុងករណីដែលរឿងក្តីនោះមានលក្ខណៈស្មុគស្មាញដែលតុលាការគិតថា ការសាកសួរភាគី និងការពិនិត្យឯកសារមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីចេញដីកាសម្រេច តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ពីព្រោះការសម្រេចសេចក្តីនៅក្នុងនីតិវិធីនៃការរក្សាការពារត្រូវធ្វើឡើងដោយដីកាសម្រេច ដូច្នេះមាត្រា១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្ត បើតុលាការសម្រេចជ្រើសរើសយកការទាញហេតុផលដោយផ្ទាល់មាត់ នីតិវិធីនេះត្រូវធ្វើជាសាធារណៈ ដែលភាគីសងខាងអាចមានវត្តមានបាន ហើយត្រូវធ្វើកំណត់ហេតុ។

**កថាភាគទី៨. ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

ការសម្រេចសេចក្តីលើពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយដីកាសម្រេចតាមបញ្ញត្តិមាត្រា៥៣៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បើខ្វះលក្ខខណ្ឌចាំបាច់សម្រាប់ការធ្វើបណ្តឹង ដែលអនុវត្តដូចគ្នាចំពោះនីតិវិធីនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូចជាសមត្ថភាពភាគី និងលក្ខណៈសម្បត្តិជាភាគី នោះពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននឹងត្រូវបានលើកចោល។ បើសិនខ្វះលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ពាក្យសុំនឹងត្រូវបានលើកចោលដែរ។ ចំពោះដីកាសម្រេចដែលលើកចោលពាក្យសុំនេះ អាចប្តឹងជំទាស់បាន (មាត្រា៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ អំឡុងពេលធម្មតានៃការប្តឹងជំទាស់ គឺ រយៈពេល ១ (មួយ) សប្តាហ៍ ប៉ុន្តែអំឡុងពេលនៃការប្តឹងជំទាស់នៅក្នុងករណីនេះ ត្រូវបានកំណត់ដល់ទៅ ២ (ពីរ) សប្តាហ៍ ដោយផ្អែកទៅតាមច្បាប់។

ចំណែក ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវចេញនៅពេលដែលលក្ខខណ្ឌទាមទារសម្រាប់ការរឹបអូសជាបណ្តោះអាសន្ន ក៏ដូចជាលក្ខខណ្ឌចាំបាច់ផ្សេងទៀតសម្រាប់ការធ្វើបណ្តឹងត្រូវបានបំពេញសព្វគ្រប់។ ជាគោលការណ៍ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយកំណត់ជាក់លាក់នូវកម្មវត្ថុ។ ប៉ុន្តែចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ អាចចេញបានដោយមិនចាំបាច់កំណត់កម្មវត្ថុទេ។ តុលាការត្រូវបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅភាគី ។[48]

**កថាភាគទី៩. ការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៣។

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធ និងផលប្រយោជន៍។[49] ការទទួលនូវការបញ្ជូន គឺជាការដាក់ខ្លួនក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការ ហេតុនេះហើយ ការធ្វើការបញ្ជូនចំពោះជនដែលមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការកម្ពុជា មិនអាចធ្វើបានទេ លើកលែងក្នុងករណីដែលជននោះយល់ព្រមទទួលការបញ្ជូនដោយស្ម័គ្រចិត្ត។ ការបញ្ជូននេះ ត្រូវភ្ជាប់ជាមួយនូវអានុភាពគតិយុត្តផ្សេងទៀតមានដូចជា តាមរយៈការបញ្ជូននេះអំឡុងពេលដែលអាចប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាននឹងចាប់ផ្ដើមដំណើរការ។

### ៩.១. ស្ថាប័នចាត់ចែង និងប្រតិបត្តិការបញ្ជូន

ស្ថាប័នដែលធ្វើការបញ្ជូន គឺមានមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន គឺក្រឡាបញ្ជី។ ម៉្យាងទៀត មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូនមានតួនាទី និងភារកិច្ច ដូចតទៅ៖

- ធ្វើ ឬផ្ដល់ឯកសារបញ្ជូនទៅអ្នកប្រតិបត្តិក្នុងការបញ្ជូន
- ផ្ដល់អំណាចទាក់ទងទៅនឹងការបញ្ជូន
- ទទួលរបាយការណ៍បញ្ជូនពីអ្នកប្រតិបត្តិក្នុងការបញ្ជូន
- យករបាយការណ៍បញ្ជូនទៅឱ្យចៅក្រមពិនិត្យមើលថាតើត្រឹមត្រូវដែរឬទេ
- យករបាយការណ៍បញ្ជូនដាក់ទុកក្នុងសំណុំរឿង។

ម៉្យាងវិញទៀត តួនាទី និងភារកិច្ចរបស់អ្នកប្រតិបត្តិក្នុងការបញ្ជូន គឺ ៖

- បញ្ជូនឯកសារទៅឱ្យបុគ្គលដែលត្រូវទទួលការបញ្ជូន
- ធ្វើរបាយការណ៍ទាក់ទងទៅនឹងការបញ្ជូន
- បញ្ជូនរបាយការណ៍ទៅតុលាការដើមវិញ។

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន មានដូចជាមន្ត្រីប៉ុស្តិ៍ប្រៃសណីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី ជាដើម ។[50] ឯកសារដែលត្រូវបញ្ជូន ជាឯកសារថតចម្លង លើកលែងតែករណីដែលបានកំណត់ពិសេសដោយច្បាប់។

### ៩.២. ការបញ្ជូនទៅបុគ្គលដែលអសមត្ថភាពក្នុងបណ្ដឹង

បុគ្គលដែលអសមត្ថភាព មានអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិបត្ថម្ភ។ ការបញ្ជូនរបស់បុគ្គលទាំង ៣ (បី) នេះ គឺអ្នកប្រតិបត្តិការបញ្ជូន ត្រូវបញ្ជូនទៅឱ្យអ្នកតំណាងស្របច្បាប់របស់បុគ្គលដែលអសមត្ថភាពនោះ ដែលក្នុងនោះមានដូចជា ចំពោះ អនីតិជន អ្នកប្រតិបត្តិការបញ្ជូនត្រូវបញ្ជូនឯកសារ

[49] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ១, នីតិវិធីបណ្ដឹង. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១១៧។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៤៦ កថាខណ្ឌទី៣។

ទៅឱ្យអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់អនីតិជន។ បើជាជននៅក្រោមអាណាព្យាបាលទូទៅវិញ ការបញ្ជូនត្រូវបញ្ជូនទៅឱ្យអ្នកអាណាព្យាបាលទូទៅ។ ក្នុងករណី អ្នកទទួលការបញ្ជូនជាជននៅក្រោមហិបត្ថម្ភវិញ អ្នកប្រតិបត្តិការបញ្ជូនត្រូវបញ្ជូនទៅឱ្យហិតូបត្ថម្ភកៈ។ លើកលែងតែក្នុងករណី អនីតិជនដែលទទួលបានអត្តាធីនភាព និងអនីតិជនដែលទទួលបានការយល់ព្រមពីអ្នកមានអំណាចមេបា ការបញ្ជូន គឺបញ្ជូនទៅកាន់បុគ្គលនោះផ្ទាល់។

**៩.៣. វិធីនៃការបញ្ជូន**

វិធីនៃការបញ្ជូនមានដូចជា ការបញ្ជូនដោយការប្រគល់ ការបញ្ជូនដោយការជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច ការបញ្ជូនដោយទុកចោល ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ។

**៩.៣.១. ការបញ្ជូនដោយការប្រគល់**

ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើតាមវិធីនៃការប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលនូវការបញ្ជូន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។[51] ម្យ៉ាងវិញទៀត ការបញ្ជូនត្រូវបញ្ជូនទៅលំនៅឋានរបស់បុគ្គលដែលត្រូវទទួលការបញ្ជូននោះ ប្រសិនបើបុគ្គលនោះគ្មានលំនៅឋាន ការបញ្ជូនត្រូវបញ្ជូនទៅទីសំណាក់របស់បុគ្គលនោះ។ លើសពីនេះទៅទៀត ក្នុងករណីដែលគ្មានលំនៅឋាន ការបញ្ជូនត្រូវបញ្ជូនទៅទីលំនៅចុងក្រោយរបស់បុគ្គលនោះ។ ទោះបីជាមានលំនោះឋាន ឬទីសំណាក់ក៏ដោយ ប្រសិនបើមានការជូនដំណឹងពីទីកន្លែងបញ្ជូន ដូច្នេះត្រូវធ្វើការបញ្ជូនទៅកាន់ទីកន្លែងនោះ។ ការបញ្ជូនខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

**៩.៣.២. ការបញ្ជូនដោយជួបប្រទះ**

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូនពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការបញ្ជូនអាចធ្វើបាននៅកន្លែងដែលជួបប្រទះជននោះ លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូននោះ។ ទោះបីជាបានដឹងពីលំនៅឋាន ទីសំណាក់ ឬកន្លែងដែលត្រូវធ្វើការបញ្ជូនក៏ដោយ ប្រសិនបើបុគ្គលដែលត្រូវធ្វើការបញ្ជូនពុំបានតវ៉ា ដូច្នេះអ្នកប្រតិបត្តិក្នុងការបញ្ជូនអាចធ្វើការបញ្ជូនទៅទីកន្លែងដែលជួបប្រទះ។ ការបញ្ជូនបែបនេះ គេហៅថាការបញ្ជូនដោយជួបប្រទះ។[52]

**៩.៣.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច**

ក្នុងករណីដែលអ្នកប្រតិបត្តិក្នុងការបញ្ជូនធ្វើការបញ្ជូនទៅលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលត្រូវទទួលការបញ្ជូន ប៉ុន្តែបុគ្គលដែលត្រូវទទួលការបញ្ជូននោះអវត្តមាន ដូច្នេះអ្នកប្រតិបត្តិការបញ្ជូនអាចធ្វើការប្រគល់ឯកសារនោះទៅកាន់បុគ្គលដែលមានវត្តមាននៅទីកន្លែងនោះ អាចជាអ្នកបម្រើ ឬអ្នកផ្សេងទៀតដែល

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៤៧ កថាខណ្ឌទី១។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥១។

ធ្វើការនៅទីនោះ ឬអ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន។ ការបញ្ជូនបែបនេះ គឺហៅថាការបញ្ជូនដោយបង្គ្រប់កិច្ច (មាត្រា២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**៩.៣.៤. ការបញ្ជូនដោយទុកចោល**

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ចនោះពុំព្រមទទួលយកឯកសារនោះដោយគ្មានមូលហេតុត្រឹមត្រូវ ដូច្នេះអ្នកប្រតិបត្តិការបញ្ជូន អាចទុកឯកសារនោះចោលនៅចំពោះមុខបុគ្គលនោះបាន។ ការបញ្ជូនបែបនេះ គេហៅថាការបញ្ជូនដោយទុកចោល (មាត្រា ២៥២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**៩.៣.៥. ការបញ្ជូនទៅបរទេស**

យោងតាមមាត្រា ២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងករណីដែលបុគ្គលដែលត្រូវទទួលការបញ្ជូនពុំមានលំនៅឋាន ទីសំណាក់ ឬលំនៅឋានចុងក្រោយនៅព្រះរាជាណាចក្រកម្ពុជា ការបញ្ជូនត្រូវធ្វើតាមលក្ខខណ្ឌដូចតទៅ៖

- ចំពោះជនបរទេស តុលាការត្រូវប្រគល់ភារកិច្ចទៅឱ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅប្រទេសនោះ
- ករណីជនជាតិខ្មែរនៅបរទេស តុលាការត្រូវប្រគល់កិច្ចការបញ្ជូនទៅឱ្យអគ្គរាជទូត ឬភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះឱ្យធ្វើការបញ្ជូនបាន
- ប្រសិនបើជនបរទេសដែលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តវិធីនៃការបញ្ជូនដូចជនជាតិខ្មែរដែរ។

**៩.៣.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ក្នុងករណីដែលទោះបីជាបានខំប្រឹងប្រែងស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬមិនអាចធ្វើការបញ្ជូនទៅបរទេស តាមរយៈការប្រគល់កិច្ចការជាដើម ដែលជាករណីដែលគ្មានវិធីអ្វីផ្សេងទៀតសម្រាប់ធ្វើការបញ្ជូនទេ ទីបញ្ចប់អាចទទួលស្គាល់ឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

ការបញ្ជូនតាមការផ្សាយជាសាធារណៈអាចធ្វើទៅបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌ ៤ (បួន) ខាងក្រោមនេះ៖

- ទោះបីជាខំរកយ៉ាងណាក៏ដោយ ក៏មិនអាចរកលំនៅឋាន ទីសំណាក់ ឬទីសំណាក់ចុងក្រោយរបស់អ្នកដែលត្រូវទទួលការបញ្ជូនបាន
- បើទោះបីជាដឹងពីទីសំណាក់ ឬលំនៅឋានចុងក្រោយ ក៏ការបញ្ជូនមិនអាចធ្វើទៅបាន
- មិនអាចធ្វើការបញ្ជូនទៅបរទេស
- តុលាការមិនបានទទួលលិខិតបញ្ជាក់ពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលប្រគល់ឱ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចធ្វើការបញ្ជូន។

ជាគោលការណ៍ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយក្រឡាបញ្ជីតាមរយៈពាក្យសុំរបស់ភាគី ។ ក៏ប៉ុន្តែ ប្រសិនបើតុលាការយល់ថាមានភាពចាំបាច់ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការអាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានដោយឆន្ទានុសិទ្ធិ ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។ បន្ទាប់ពីមានពាក្យសុំរបស់ភាគី ឬតុលាការបង្គាប់ឱ្យបញ្ជូនតាមការផ្សាយជាសាធារណៈ ក្រឡាបញ្ជី ត្រូវធ្វើឡើងដោយបិទប្រកាសនៅទីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬទីកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប ដែលប្រកាសថាក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលធ្វើការបញ្ជូន ហើយអាចប្រគល់ឯកសារបញ្ជូននោះទៅឱ្យបុគ្គលដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បាន។[53] តុលាការអាចចុះនៅក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ (មាត្រា២៥៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ការបញ្ជូនដោយការផ្សាយជាសាធារណៈនឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាសនោះ ។ [54]ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈលើកទី២ វិញ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាសនោះ។[55] ក្នុងករណីការបញ្ជូនតាមការផ្សាយជាសាធារណៈទៅបរទេស នឹងមានអានុភាពនៅអំឡុងពេល ៦ (ប្រាំមួយ) សប្តាហ៍គិតចាប់ពីថ្ងៃបញ្ជូន។

## ផ្នែកទី២. នីតិវិធីនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

### កថាភាគទី១. សមត្ថកិច្ចអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

ក្រោយពីតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តាមពាក្យសុំរបស់ម្ចាស់បំណុល ម្ចាស់បំណុលអាចដាក់ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការ ដែលមានសមត្ថកិច្ចអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ ដោយផ្អែកលើប្រភេទ និងកម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននីមួយៗ។ តុលាការដែលត្រូវអនុវត្តការចាត់ចែងរក្សាការពារត្រូវហៅថា តុលាការអនុវត្តការរក្សាការពារ (មាត្រា៥៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ ។[56]

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៦។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី២។

## កថាភាគទី២. ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

### ២.១. ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ចាំបាច់ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្ដីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។[57]

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និងទំហំនៃសេចក្ដីសុំនោះក្នុងពាក្យសុំអនុវត្តដោយបង្ខំ (មាត្រា៣៤៩ កថាខណ្ឌទី២ និងទី៣)។

### ២.២. ឯកសារដែលត្រូវភ្ជាប់ជាមួយ

ក្រោយពីម្ចាស់បំណុលបានទទួលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នពីតុលាការរួច ម្ចាស់បំណុលត្រូវដាក់ពាក្យសុំអនុវត្ត ហើយត្រូវភ្ជាប់មកជាមួយពាក្យសុំដូចខាងក្រោម៖

- លិខិតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ករណីនេះម្ចាស់បំណុលពុំចាំបាច់ស្នើសុំរូបមន្តអនុវត្តទេ (មាត្រា៥៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មូលហេតុដែលច្បាប់មិនតម្រូវឱ្យមានរូបមន្តអនុវត្ត ព្រោះការរឹបអូសជាបណ្ដោះអាសន្នជាបញ្ហាបន្ទាន់បង្ខំ ដូច្នេះ នីតិវិធីគប្បីត្រូវបានអនុវត្តយ៉ាងលឿនបំផុតដែលអាចធ្វើទៅបាន។ មូលហេតុផ្សេងទៀត គឺដោយសារដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវបានអនុវត្ត លុះត្រាតែមានពាក្យសុំពីភាគី ហើយដីកានេះ ត្រូវអនុវត្តក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ ។[58] ប៉ុន្តែ បើសិនជាការអនុវត្តចំពោះ ឬសម្រាប់ជនក្រៅពីភាគីដែលត្រូវកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយភ្ជាប់រូបមន្តអនុវត្ត (មាត្រា៥៦២ កថាខណ្ឌទី១)។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៤។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី២។

- លិខិតបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ កាលណាម្ចាស់បំណុលសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បានផ្តល់សិទ្ធិអំណាចឱ្យអ្នកតំណាងដោយអាណត្តិ សិទ្ធិអំណាចនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា៥៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ប៉ុន្តែបើមានបណ្តឹងអង្គសេចក្តី ហើយមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរួចហើយ សិទ្ធិតំណាងនេះ ក៏អាចធ្វើសកម្មភាពចំពោះការចាត់ចែងរក្សាការពារបានដែរ (មាត្រា៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយគ្រាន់តែធ្វើការចម្លងឯកសារផ្លូវការ រួចភ្ជាប់មកជាមួយពាក្យសុំអនុវត្តតែម្តង។

**កថាភាគទី៣. ការពិនិត្យមើលពាក្យសុំ**

ការដាក់ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អ្នកដាក់ពាក្យសុំត្រូវធ្វើពាក្យសុំជាលាយលក្ខណ៍អក្សរដោយសរសេរនូវឈ្មោះ អាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត សញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ និងសញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំ ដែលម្ចាស់បំណុលនៃការអនុវត្តសុំ ហើយតុលាការជាអ្នកធ្វើការពិនិត្យមើលពាក្យសុំឱ្យអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ។ ម៉្យាងវិញទៀត តុលាការដែលអនុវត្តត្រូវធ្វើការត្រួតពិនិត្យនូវឯកសារផ្សេងៗដែលត្រូវភ្ជាប់មកជាមួយនឹងពាក្យសុំអនុវត្តដែលក្នុងនោះមានលិខិតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លិខិតប្រគល់សិទ្ធិ លិខិតតំណាងដោយអាណត្តិ បញ្ជីឈ្មោះភាគីជាដើម។

**កថាភាគទី៤. ការពិនិត្យលក្ខខណ្ឌចាំបាច់នៃការអនុវត្តដីកាសម្រេច**

បន្ទាប់ពីតុលាការធ្វើការត្រួតពិនិត្យទៅលើពាក្យសុំអនុវត្តដែលម្ចាស់បំណុលបានដាក់ជូនតុលាការរួចមក តុលាការត្រូវមើលទៅលើលក្ខខណ្ឌចាំបាច់មួយចំនួនទៀត ដែលក្នុងនោះមានដូចជា លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អំឡុងពេលផ្សេងៗ។

**៤.១. លិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

តុលាការត្រូវត្រួតពិនិត្យមើលទៅលើឈ្មោះភាគីដែលមានសរសេរនៅក្នុងពាក្យសុំអនុវត្តថាមានលក្ខណៈដូចគ្នានៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដែរឬទេ។ នៅក្នុងករណីដែលឈ្មោះរបស់ភាគីដូចនៅក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការនឹងអនុវត្តដីកាសម្រេចនោះដោយផ្អែកតាមឯកសារចម្លងលិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ប៉ុន្តែនៅក្នុងករណីដែលឈ្មោះមិនដូចគ្នា ដូច្នេះការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវធ្វើឡើងដោយផ្អែកទៅលើលិខិតយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដោយភ្ជាប់នឹងរូបមន្តអនុវត្ត។[59]

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី១។

**៤.២. អំឡុងពេល**

នៅពេលដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំមានរយៈពេល ២ (ពីរ) សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលម្ចាស់បំណុលរឺអ្នកដាក់ពាក្យសុំ បានទទួលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នក្នុងការដាក់ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននោះ។[60] ក្នុងករណីដែលម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំ មិនបានដាក់ពាក្យសុំអនុវត្តដីកាសម្រេចក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ទេនោះ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននឹងគ្មានអានុភាពក្នុងការអនុវត្តឡើយ។

**៤.៣. ផ្សេងៗ**

ក្នុងករណីដែលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដោយឱ្យដាក់ប្រាតិភោគ ដោយប្រាតិភោគនេះ ជាលក្ខខណ្ឌមួយសម្រាប់ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ដូច្នេះ តុលាការត្រូវពិនិត្យមើលថាតើប្រាតិភោគត្រូវបានដាក់រួចហើយ ឬនៅ។

**កថាភាគទី៥. វិធីអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**

ចំពោះករណីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ។[61] ដើម្បីចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន ក្រឡាបញ្ជីត្រូវចេញលិខិតផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន។[62] ពាក្យថា ស្ថាប័នមានសមត្ថកិច្ចនៅទីនេះ សំដៅលើរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្តដែលអចលនវត្ថុស្ថិតនៅ។ បច្ចុប្បន្នអចលនវត្ថុនៅកម្ពុជាមួយចំនួនធំនៅមិនទាន់មានការចុះបញ្ជីដីធ្លីឱ្យបានត្រឹមត្រូវស្របតាមលិខិតបទដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះទេ។ ហេតុដូច្នេះ ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននេះនឹងធ្វើការបកស្រាយចំពោះ (១) ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី និង (២) ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី។

យោងលើការចុះបញ្ជីនៃការរឹបអូសជាបណ្ដោះអាសន្ន ដោយអនុលោមតាមការផ្ទុកផ្ដាក់ដែលបានលើកឡើងខាងលើ គឺការិយាល័យចុះបញ្ជីត្រូវផ្ញើនូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី (មាត្រា៥៦៧ កថាខណ្ឌទី៤ មាត្រា៤២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយក្រឡាបញ្ជីនោះត្រូវរក្សាទុកនូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះនៅក្នុងសំណុំរឿង។

ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការបញ្ជូនលិខិតផ្ទុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជី ដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន ហើយ

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦២ កថាខណ្ឌទី២។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៧។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៧ កថាខណ្ឌទី៣។

លិខិតផ្ទុកផ្តាក់ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ឈ្មោះតុលាការ លេខលិខិតផ្ទុកផ្តាក់ ឈ្មោះក្រឡាបញ្ជី កាលបរិច្ឆេទ ហត្ថលេខា និងត្រូវបោះត្រារបស់ក្រឡាបញ្ជី[63] ចំណុចដែលបានរៀបរាប់នេះ ជាចំណុចទូទៅដែលត្រូវសរសេរក្នុងលិខិតផ្ទុកផ្តាក់ ហើយត្រូវសរសេរបន្ថែមចំណុចមួយចំនួនទៀត ស្របតាមលិខិតផ្ទុកផ្តាក់។

### ៥.១. ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលបានចុះបញ្ជីដីធ្លី គឺជាអចលនវត្ថុដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលត្រូវបានស្គាល់ថាជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬហៅម៉្យាងទៀតថាជាប្លង់រឹង។ ក្នុងករណីដែលអចលនវត្ថុបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីរួចរាល់ ក្រឡាបញ្ជីត្រូវចេញលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្ត។[64] ហើយលិខិតផ្ទុកផ្តាក់នេះ ត្រូវសរសេរបន្ថែមចំណុចដូចខាងក្រោម៖

ក. កម្មវត្ថុ (សរសេរអំពីខ្លឹមសារចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន)។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ (លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំង)។

គ. គោលបំណងនៃការចុះបញ្ជី (ចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននូវកម្មសិទ្ធិ)។

ឃ. មូលហេតុ (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន)

ង. ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត (អាសយដ្ឋាន)។

ច. ឈ្មោះកូនបំណុលនៃការអនុវត្ត (អាសយដ្ឋាន)។

ដោយជូនភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[65] និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុផងដែរ។ បន្ទាប់មកទៀត មន្ត្រីសុរិយោដីថ្នាក់រាជធានីខេត្ត ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ត្រង់ បន្ទុកលើអចលនវត្ថុ ដោយត្រូវសរសេរថា "ត្រូវបានរឹបអូសជាបណ្តោះអាសន្នកម្មសិទ្ធិតាមដីកាសម្រេចលេខ............ ចុះថ្ងៃទី....... ខែ........... ឆ្នាំ............ របស់តុលាការ...................... លរ.................. (ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ)"។

---

[63] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៥។

[64] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៥ កថាខណ្ឌទី១ ចំណុចទី១។

[65] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៦។

## ៥.២. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី

អចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដីធ្លី ជាអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី និងត្រូវបានសន្មត់ថាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[66] ដោយស្គាល់ថាជាលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ឬអាចហៅម៉្យាងទៀតថាប្លង់ទន់។ ក្នុងករណីអចលនវត្ថុមិនទាន់ចុះបញ្ជីក្នុងសៀវភៅគោលដីធ្លីទេ ក្នុងនោះមានស្ថាប័នចំនួន ២ (ពីរ) ដែលអាចទទួលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រួមមានរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្ត ឬរដ្ឋបាលសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌដែលអចលនវត្ថុស្ថិតនៅ។[67] បន្ទាប់ពីបានទទួលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន រដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្ត និងរដ្ឋបាលសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌ ត្រូវចុះលេខរៀងនៃការទទួលលិខិតផ្ទុកផ្ដាក់នេះក្នុងសៀវភៅទទួលពាក្យសុំបញ្ជីអំពីសិទ្ធិប្រត្យក្សដែលបង្កើតដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងទៀត[68] ដោយចុះលេខរៀងនេះ ដើម្បីសម្គាល់ពីលំដាប់នៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ បើមានការដាក់ពាក្យសុំចុះបញ្ជីច្រើនលើអចលនវត្ថុតែមួយ។[69]

លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុត្រូវសរសេរដូចខាងក្រោម៖

ក. កម្មវត្ថុ (សរសេរអំពីខ្លឹមសារនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន)។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ (លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំង)។

គ. ភាគីនៃដីដែលត្រូវសន្មត់ (ឈ្មោះ និងអាសយដ្ឋាន)។

ឃ. គោលបំណងនៃការចុះបញ្ជី (ចុះបញ្ជីអំពីការរឹបអូសបណ្ដោះអាសន្ននូវកម្មសិទ្ធិ)។

ង. មូលហេតុ (ដីកាសម្រេចឱ្យរឹបអូសជាបណ្ដោះអាសន្នលេខ.......... ចុះថ្ងៃទី....... ខែ........ ឆ្នាំ.......)

ច. ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត។

ឆ. ចំពោះការរឹបអូស សរសេរឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត។

---

66 ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៤។

67 ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៥។

68 ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៥។

69 ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៧។

ដោយជូនភ្ជាប់ជូនឯកសារយថាភូតនៃដីកាសម្រេចជាបណ្តោះអាសន្ន និងសេចក្តីបញ្ជាក់ដំបូងអំពីកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តជាអាទិ៍។[70]

ទោះបីជារដ្ឋបាលសុរិយោដីថ្នាក់ក្រុងខណ្ឌ អាចទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នពិតមែន ប៉ុន្តែរដ្ឋបាលសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌមិនមានសិទ្ធិផ្តល់សេវារដ្ឋបាលទាក់ទងនឹងការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះទេ ដោយរដ្ឋបាលថ្នាក់ក្រុងស្រុកខណ្ឌត្រូវបញ្ជូនច្បាប់ដើមនៃលិខិតផ្ទុកផ្តាក់អំពីការរឹបអូសជាបណ្តោះអាសន្ន និងឯកសារពាក់ព័ន្ធផ្សេងៗទៀតទៅកាន់រដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្តដែលអចលនវត្ថុតាំងនៅ ដោយគ្មានការយឺតយ៉ាវ ហើយបន្ទាប់ពីរដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្តបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នរួចហើយ រដ្ឋបាលសុរិយោដីរាជធានីខេត្តត្រូវបញ្ជូនលិខិតផ្ទុកផ្តាក់នោះ និងឯកសារផ្សេងៗ ព្រមទាំងលិខិតអនុញ្ញាតឱ្យចាប់ផ្តើមនីតិវិធីចុះបញ្ជីលើកដំបូងទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុងស្រុកខណ្ឌដែលអចលនវត្ថុស្ថិតនៅ ដើម្បីអនុវត្តនីតិវិធីចុះបញ្ជីលើកដំបូងឱ្យបានឆាប់រហ័ស និងគ្មានការយឺតយ៉ាវ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។[71] ទន្ទឹមនឹងនេះម្ចាស់បំណុលនៃការអនុវត្តមានកាតព្វកិច្ចបង់ជាមុនការចំណាយក្នុងការចុះបញ្ជីលើកដំបូង ឬសោហ៊ុយនៃការរឹបអូសជាបណ្តោះអាសន្នជាអាទិ៍។ នៅពេលបញ្ចប់នីតិវិធីនៃការចុះបញ្ជីលើកដំបូង រដ្ឋបាលសុរិយោដីថ្នាក់រាជធានីខេត្តត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" ដូចការផ្ទុកផ្តាក់ឱ្យចុះបញ្ជីចំពោះអចលនវត្ថុដែលបានចុះបញ្ជីដីធ្លី (ប្លង់រឹង) ខាងលើនេះ។

**កថាភាគទី៦. ការផ្អាក និងការលុបចោលនូវការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ការផ្អាក ឬការលុបការអនុវត្តការរឹបអូសជាបណ្តោះអាសន្នមិនអាចផ្អាក ឬលុបចោលតាមអំពើចិត្តឡើយ គឺត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ទើបការអនុវត្តរឹបអូសជាបណ្តោះអាសន្នអាចត្រូវបានផ្អាក ឬលុបចោល។ ក្នុងចំណុចនេះនឹងសិក្សាពីមូលហេតុដែលនាំឱ្យការអនុវត្តការរឹបអូសជាបណ្តោះអាសន្នត្រូវបានតុលាការសម្រេចផ្អាក ឬលុបចោលតែម្តងដែលមានបង្ហាញក្នុងចំណុច (១) ការផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្ន (២) ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និង (៣) ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ដោយបង្ហាញអំពីនីតិវិធីផ្ទុកផ្តាក់ឱ្យលុបចោលការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន និងចំណុចដែលត្រូវសរសេរបន្ថែមក្នុងលិខិតផ្ទុកផ្តាក់នោះផងដែរ។

---

[70] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៦។

[71] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ៩។

### ៦.១. ការផ្អាកការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងចំណុចនេះនឹងធ្វើការបកស្រាយពីសញ្ញាណទូទៅទាក់ទងនឹងការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ព្រមទាំងមូលហេតុចម្បងផ្សេងៗ ដែលនាំឱ្យតុលាការសម្រេចផ្អាកការរឹបអូសជាបណ្ដោះអាសន្ន ដោយនឹងបញ្ជាក់នៅក្នុងចំណុច (១.១) ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន និង (១.២) មូលហេតុដែលនាំឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។

### ៦.១.១. ខ្លឹមសារនៃការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន

ការផ្អាកការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ជាស្ថានភាពដែលតុលាការអនុវត្តមិនអាចចាប់ផ្ដើម ឬបន្តការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមច្បាប់កំណត់ ហើយទំហំនៃការផ្អាកប្រែប្រួលតាមមូលហេតុនៃការផ្អាក។[72] ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នមិនត្រូវការចំណាយរយៈពេលដើម្បីអនុវត្តនោះទេ ដោយបញ្ចប់ត្រឹមដំណាក់កាលរឹបអូសជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។ ដូច្នេះហើយបើមូលហេតុនៃការផ្អាកការអនុវត្តបានកើតឡើងបន្ទាប់ពីការអនុវត្តរឹបអូសជាបណ្ដោះអាសន្នត្រូវបានបញ្ចប់នោះ ការផ្អាកការអនុវត្តរឹបអូសបណ្ដោះអាសន្ន គឺគ្មានន័យអ្វីសោះឡើយ។ ទោះបីជាយ៉ាងនេះក្ដីមិនមែនមានន័យថា ការផ្អាកការអនុវត្តក្នុងនីតិវិធីនេះមិនមានប្រសិទ្ធភាពនោះទេ គឺគ្រាន់តែទាមទារឱ្យផ្អាកមុនពេលបញ្ចប់នីតិវិធីអនុវត្តតែប៉ុណ្ណោះ។

### ៦.១.២. មូលហេតុដែលនាំឱ្យមានការផ្អាកការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

ការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ អាចត្រូវបានផ្អាកប្រសិនបើមានមូលហេតុដូចខាងក្រោមនេះ៖

#### ក. ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន

នៅពេលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការអាចបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្នបាន ប៉ុន្តែមិនមែនមានន័យថាការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នបានបង្កើតអានុភាពផ្អាក ឬលុបចោលការអនុវត្តនោះទេ គឺត្រូវមានសម្រេចដោយឡែកមួយទៀតដែលបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ ដោយដីកាសម្រេចផ្អាក ឬលុបចោលការការអនុវត្តនេះ ត្រូវធ្វើឡើងតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្តដោយឱ្យដាក់ប្រាតិភោគ រហូតដល់មានការសម្រេចសេចក្ដីលើពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសបណ្ដោះអាសន្ន ហើយត្រូវមានសេចក្ដីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេច

[72] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ៧០។

រឹបអូសជាបណ្តោះអាសន្ន និងការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្ត ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[73]

**ខ. ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

ទោះបីជាកូនបំណុលនៃការអនុវត្តបានដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដោយសារការផ្លាស់ប្តូរស្ថានភាពក៏ដោយក៏ការដាក់ពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះមិនបានបង្កើតអានុភាពឱ្យផ្អាក ឬលុបចោលការអនុវត្តនោះទេ។ ប៉ុន្តែតុលាការអាចបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្ត រហូតដល់មានដីកាសម្រេចពីពាក្យសុំទាមទារឱ្យលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយដីកាសម្រេចមួយដោយឡែកទៀតដែលត្រូវធ្វើឡើងតាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្តដោយឱ្យដាក់ប្រាតិភោគ និងមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពច្បាស់លាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងមានការបារម្ភថាការខូចខាតដែលមិនអាចសងបានដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[74]

**គ. បណ្តឹងតវ៉ាចំពោះការទាមទារ**

នៅពេលកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ហើយបើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានមួយរយៈ តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្តដោយឱ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគបាន។[75] បណ្តឹងតវ៉ាចំពោះការទាមទារ ជាបណ្តឹងដែលកូនបំណុលនៃការអនុវត្តតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារ[76] ដែលកំណត់ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយមូលហេតុសិទ្ធិដែលត្រូវបានរក្សាការពារដោយច្បាប់សារធាតុត្រូវបានប្រែប្រួលដោយសារការសង ការទូទាត់ ការលើកលែង ជាអាទិ៍។

**ឃ. បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត**

នៅពេលកូនបំណុលនៃការអនុវត្តបានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ហើយបើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នបានមួយរយៈ តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគបាន។[77] បណ្តឹងតវ៉ាចំពោះរូបមន្តអនុវត្តនេះ ជាបណ្តឹងដែលកូនបំណុលនៃ

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១។

[74] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*. គន្លឹទី៧. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧, មាត្រា៥៥១។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៧ និងមាត្រា៥៦៤។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៣ មាត្រា៣៦៧ និងមាត្រា៥៦៤។

[77] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៧ និងមាត្រា៥៦៤។

ការអនុវត្តតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តពិសេស ដោយអះអាងពីនត្ថិភាពនៃហេតុដែលត្រូវនឹងលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តរួមមាន ការបំពេញលក្ខខណ្ឌ ការមកដល់នៃពេលកំណត់មិនពិតប្រាកដ ឬការអនុញ្ញាតឱ្យបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត។[78]

**ង. បណ្តឹងតវ៉ារបស់តតិយជន**

នៅពេលកូនបំណុលនៃការអនុវត្ត បានដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ហើយបើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលអះអាងនោះ តុលាការដែលទទួលបណ្តឹងអាចបង្គាប់ឱ្យផ្អាកការអនុវត្តរឹបអូសជាបណ្តោះអាសន្នបានមួយរយៈ តាមពាក្យសុំរបស់កូនបំណុលនៃការអនុវត្ត ដោយឱ្យដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគបាន។[79]

បណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើឡើងដោយតតិយជន ក្នុងគោលបំណងឱ្យតតិយជនក្រៅពីបុគ្គលដែលទទួលអានុភាពនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទាមទារកុំឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ដោយហេតុថាការរឹបអូសជាបណ្តោះអាសន្នបានធ្វើឡើងចំពោះទ្រព្យសម្បត្តិរបស់តតិយជននោះ។[80]

**៦.២. ការលុបចោលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងចំណុចនេះនឹងធ្វើការបកស្រាយពីសញ្ញាណទូទៅទាក់ទងនឹងការលុបការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ព្រមទាំងមូលហេតុចម្បងផ្សេងៗ ដែលនាំឱ្យតុលាការសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្នដោយនឹងបញ្ជាក់នៅក្នុងចំណុច (៦.២.១) ខ្លឹមសារនៃការលុបការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង (៦.២.២) មូលហេតុដែលនាំឱ្យលុបការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។

**៦.២.១. ខ្លឹមសារនៃការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

ការលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ជាការបំបាត់ចេញនូវការអនុវត្តទាំងស្រុង ឬមួយផ្នែកដែលធ្វើរួចហើយដោយតុលាការអនុវត្ត ក្នុងដំណើរការនីតិវិធីនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។[81] ការលុបចោលការអនុវត្តដោយបង្ខំ ហើយមិនមានភាពខុសគ្នាពីការផ្អាកការអនុវត្តដីកាសម្រេចរឹបអូសជា

[78] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី.* គន្លឹះទី៧. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧, មាត្រា៣៦៤។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៦៧ និងមាត្រា៥៦៤។

[80] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី.* គន្លឹះទី៧. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧, មាត្រា៣៦៥។

[81] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ៧១។

បណ្តោះអាសន្ននោះទេ ព្រោះការលុបចោលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានមូលហេតុច្បាស់លាស់ជាមុនសិន ទើបតុលាការអាចសម្រេចលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ននោះបាន។

**៦.២.២. មូលហេតុដែលនាំឱ្យលុបចោលការអនុវត្តរឹបអូសជាបណ្តោះអាសន្ន**

តុលាការត្រូវលុបចោលការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្នុងករណីដែលមានមូលហេតុដូចរៀបរាប់ខាងក្រោម៖[82]

ក. ឯកសារយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្តក្រៅពីលិខិតយថាភូតដែលកំណត់ក្នុងចំណុច **ច** កថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ខ. ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។

គ. អនុសារសាលក្រមស្ថាពរ ឬអនុសារសាលដីកាស្ថាពរ ដែលប្រកាសថា ការផ្សះផ្សា ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។

ឃ. ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀត ដែលក្រឡាបញ្ជីបានធ្វើដែលបញ្ជាក់ថាលិខិតអនុវត្តចាប់ពីចំណុច **ខ** រហូតដល់ចំណុច **ង** កថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង ឬមូលហេតុផ្សេងទៀត។

ង. ឯកសារចម្លងយថាភូតនៃកំណត់ហេតុពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តី ដែលកំណត់ថាមិនឱ្យអនុវត្តរឹបអូសដោយបង្ខំ ឬដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។

ច. ឯកសារបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីរួចផុតពីការអនុវត្តដោយបង្ខំ។

ឆ. ឯកសារចម្លងយថាភូតនៃសេចក្តីដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្ត និងលុបចោលការចាត់ចែងការអនុវត្ត។[83]

ជ. កូនបំណុលនៃការអនុវត្តបានធ្វើការផ្ញើប្រាក់រំដោះស្មើនឹងចំនួនប្រាក់ដែលបានកំណត់ដោយតុលាការ។[84]

**កថាភាគទី៧. ការលុបចោលប្រាតិភោគ**

មាត្រា៧៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា "ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគបានបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវបានដាក់ប្រាតិភោគ តុលាការត្រូវចេញដីកាសម្រេចលុបចោលនូវប្រាតិភោគនោះតាមពាក្យសុំ"។ មានន័យថា ក្នុងករណីម្ចាស់បំណុលនៃរឿងក្តីរក្សាការពារឈ្នះបណ្តឹងអង្គសេចក្តី

[82] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៧០។
[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៧០ កថាខណ្ឌទី១ និងមាត្រា៥៦៤។
[84] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦៩។

ហើយសាលក្រមបានចូលជាស្ថាពរ ម្ចាស់បំណុលនោះអាចទទួលនូវប្រាតិភោគ ដែលខ្លួនបានដាក់តាមខ្លឹមសារនៃសេចក្តីបង្គាប់នៃមាត្រា៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់តុលាការនោះត្រឡប់មកវិញបាន។

ក្នុងករណីដែលតុលាការទទួលស្គាល់ថា មូលហេតុនៃការដាក់ប្រាតិភោគបានរលត់ តុលាការត្រូវចេញដីកាសម្រេចលុបប្រាតិភោគនោះ។ ម្ចាស់បំណុលអាចទទួលប្រាតិភោគត្រឡប់មកវិញបាន ដោយផ្អែកលើដីកាសម្រេចលុបប្រាតិភោគចោល។

**កថាភាគទី៨. ការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន**

ដើម្បីលុបចោលនូវការអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឱ្យធ្វើការលុបចោលការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[85] ដោយការផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នត្រូវធ្វើឡើងដូចការផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដែរ ពោលគឺលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នត្រូវបញ្ជូនទៅផ្នែកជួរមុខនៃច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី-ខេត្តជាមុនសិន បន្ទាប់មកទើបការិយាល័យច្រកចេញចូលតែមួយបញ្ជូនលិខិតផ្ទុកផ្តាក់នេះ បន្តទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្ត ដើម្បីដំណើរការនីតិវិធីបន្ទាប់។ អំឡុងពេលនោះផងដែរ ការិយាល័យច្រកចេញចូលតែមួយនឹងចេញ "បង្កាន់ដៃទទួលពាក្យ" ដើម្បីបញ្ជាក់អំពីការទទួលយកលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ទន្ទឹមនឹងនេះ ម្ចាស់បំណុលត្រូវបង់សេវាសាធារណៈ ដូចកំណត់ក្នុងប្រកាសស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផងដែរ។ ហើយលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖[86]

ក. កម្មវត្ថុ (សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន)។

ខ. អត្តសញ្ញាណនៃអចលនវត្ថុ (លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី)។

គ. ឈ្មោះកម្មសិទ្ធិករ (អាសយដ្ឋាន)។

ឃ. គោលបំណងនៃការចុះបញ្ជី (ការលុបចោលការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន)។

ង. មូលហេតុ (ដីកាសម្រេចលេខ និងឈ្មោះតុលាការ)។

ច. ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត (អាសយដ្ឋាន)។

ឆ. ឈ្មោះកូនបំណុលនៃការអនុវត្ត (អាសយដ្ឋាន)។

[85] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥២៨ និងមាត្រា៥៦៧ កថាខណ្ឌទី៥។

[86] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៧។

ហើយឯកសារដែលត្រូវជូនភ្ជាប់ គឺអាស្រ័យតាមមូលហេតុនៃការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។[87]

ភារកិច្ចរបស់សុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវសរសេរក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅខ្ទង់ត្រង់បន្ទុកលើអចលនវត្ថុ ដោយត្រូវសរសេរថា ត្រូវបានលុបការរឹបអូសជាបណ្តោះអាសន្ន.... ដែលតុលាការ......... បានចេញដីកាសម្រេចលេខ........ ចុះថ្ងៃទី....... ខែ..... ឆ្នាំ........ របស់តុលាការ........... លរ.......... ឬដកពាក្យសុំដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬដកពាក្យសុំអនុវត្តរឹបអូសជាបណ្តោះអាសន្ន ចុះថ្ងៃទី...... ខែ....... ឆ្នាំ....... (ជាទឹកខៀវ ឬខ្មៅ) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកក្រហម)។[88]

## ផ្នែកទី៣. បណ្តឹងឧបាស្រ័យចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅក្នុងផ្នែកទី៣នេះនឹងធ្វើការបកស្រាយលើកថាភាគចំនួន ៤ (បួន) សំខាន់មានដូចជា កថាភាគទី១ ការតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ កថាភាគទី២ ការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ កថាភាគទី៣ បណ្តឹងជំទាស់ និងកថាភាគទី៤ ការសុំឱ្យជំនុំជម្រះសាជាថ្មី។

### កថាភាគទី១. ការតវ៉ាចំពោះដីកាសម្រេច

#### ១.១. អត្ថន័យនៃការដាក់ពាក្យសុំតវ៉ា

ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមនៅក្នុងនីតិវិធីជាមុនក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មិនមែនដោយតុលាការជាន់ខ្ពស់ទេ តែដោយតុលាការថ្នាក់ដដែល ដែលចំណុចនេះស្រដៀងគ្នាទៅនឹងការតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្នុងនីតិវិធីនៃការដាស់តឿនដែរ (មាត្រា៣២៧ និងមាត្រា៣២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ លុបចោលដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ហើយចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ពាក្យសុំតវ៉ាចំពោះដីកាសម្រេចនេះ ត្រូវដាក់ទៅតុលាការនៃបណ្តឹងជំទាស់នោះដែរ។

#### ១.២. ការធ្វើពាក្យសុំតវ៉ា

កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុទៅ

---

[87] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ១៧ កថាខណ្ឌទី៥។

[88] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៣៣ ចំណុច ក។

តុលាការដែលបានចេញដីកាសម្រេច។[89] មួយវិញទៀត ពាក្យសុំតវ៉ាត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយពុំមានការកំណត់អំឡុងពេល ហើយពាក្យសុំតវ៉ាអាចដាក់នៅពេលណាក៏បានឱ្យតែដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅមានសុពលភាព។[90] លើសពីនេះទៅទៀត ការដាក់ពាក្យសុំតវ៉ាមិនធ្វើឱ្យអានុភាពអនុវត្តនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នផ្អាកដោយស្វ័យប្រវត្តិទេ គឺត្រូវមានសេចក្តីសម្រេចបណ្តោះអាសន្នដោយឡែកដែលបង្គាប់ឱ្យផ្អាកការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ឬលុបចោលការចាត់ចែងការអនុវត្ត។[91] សេចក្តីសម្រេចបណ្តោះអាសន្ននេះ អាចធ្វើបានតែក្នុងករណីដែលមានសេចក្តីបញ្ជាក់ដំបូងអំពីស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងអំពីការដែលមានការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះប៉ុណ្ណោះ ហើយការដាក់ប្រាតិភោគមានភាពចាំបាច់ជានិច្ចយោងតាមមាត្រា៥៥១ កថាខណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**“ស្ថានភាពដែលច្បាស់ថានឹងក្លាយជាមូលហេតុនៃការលុបចោលដីកាសម្រេចរក្សាការពារ”** សំដៅទៅលើស្ថានភាពដែលផ្ទុយយ៉ាងច្បាស់លាស់ និងអត្ថិភាពនៃសិទ្ធិដែលត្រូវរក្សាការពារ និងភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយឡែក។

**“ការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារការអនុវត្តការរក្សាការពារ”** សំដៅទៅលើករណីដែលសំណងជាប្រាក់តាមក្រោយទំនងជានឹងមិនអាចសងគ្រប់ចំពោះការខូចខាតរបស់កូនបំណុលបានឡើយ។[92]

**១.៣. ការវិនិច្ឆ័យលើពាក្យសុំតវ៉ា**

**ការវិនិច្ឆ័យ៖** នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ា តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬធ្វើការសាកសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានយោងតាមមាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីផ្តល់ទៅឱ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមក្នុងនីតិវិធី។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មិនចាំបាច់ទាល់តែថា នៅក្នុងកាលបរិច្ឆេទទាំងអស់ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាននោះទេ គឺគ្រាន់តែធានាឱ្យបាននូវកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានតែម្តងក៏ជាការគ្រប់គ្រាន់ដែរ។

---

[89] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥០។

[90] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ២០២។

[91] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥១។

[92] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ២០២។

**ការបញ្ចប់ការវិនិច្ឆ័យ៖** ជាគោលការណ៍ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលសមរម្យមួយ ដើម្បីធ្វើការបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ា។[93] ជាទូទៅ នៅក្នុងនីតិវិធីនៃការចេញដីកាសម្រេច តុលាការអាចបញ្ចប់ការវិនិច្ឆ័យរបស់ខ្លួនពេលណាក៏បានដោយនៅក្នុងនីតិវិធីនៃការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទនៃការបញ្ចប់ការវិនិច្ឆ័យ ដើម្បីផ្តល់ឱកាសឱ្យភាគីក្នុងការដាក់ឯកសារសម្រាប់ការវិនិច្ឆ័យទៅតុលាការឱ្យបានគ្រប់គ្រាន់។ ក៏ប៉ុន្តែ ប្រសិនការវិនិច្ឆ័យត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យបាន ព្រោះថាការធានានៅក្នុងនីតិវិធីត្រូវបានផ្តល់ឱ្យគ្រប់គ្រាន់ហើយ គឺដូចគ្នាទៅនឹងនីតិវិធីបណ្តឹងដែរ។[94]

**សេចក្តីសម្រេចពីពាក្យសុំតវ៉ា៖** នៅក្នុងដីកាសម្រេចអំពីពាក្យសុំតវ៉ា តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានភាពត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចទទួលស្គាល់ដីកាសម្រេចនោះ។[95] រីឯតុលាការត្រូវចេញដីកាសម្រេចផ្លាស់ប្តូរ ប្រសិនបើដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន មានផ្ទុកនូវចំណុចដែលត្រូវធ្វើការផ្លាស់ប្តូរ។ ករណីនេះរួមបញ្ចូលករណីដូចជាលក្ខខណ្ឌដែលម្ចាស់បំណុលត្រូវដាក់ប្រាតិភោគ ឬការបន្ថែមនូវប្រាតិភោគនៅក្នុងអំឡុងពេលកំណត់ណាមួយជាអាទិ៍។ តុលាការត្រូវចេញដីកាសម្រេចលុបចោលការរឹបអូសជាបណ្តោះអាសន្ន ប្រសិនបើដីកាសម្រេចនោះមានភាពមិនត្រឹមត្រូវ ហើយនៅក្នុងករណីនេះតុលាការអាចដាក់លក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន។ [96]

**អានុភាពនៃដីកាសម្រេច៖** ដីកាសម្រេចនេះ មិនមានអានុភាព បើមិនទាន់ចូលជាស្ថាពរទេ ក៏ប៉ុន្តែបើយល់ឃើញថាចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនេះមានអានុភាពភ្លាមៗបាន។[97]

**ការបញ្ជូនដីកាសម្រេច៖** ដីកាសម្រេចទាំងនេះត្រូវបញ្ជូនទៅភាគី ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចទាំងនេះ។

### កថាភាគទី២. ការលុបចោលដីកាសម្រេច

ក្រៅពីការលុបចោលដោយសារការតវ៉ា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចត្រូវបានលុបចោលនៅក្នុងករណីពីរទៀត ដែលមាននីតិវិធីដោយឡែកពីគ្នា គឺតាមពាក្យសុំរបស់កូនបំណុល ការលុបចោល

[93] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៣ វាក្យខណ្ឌទី១។

[94] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៣ វាក្យខណ្ឌទី២។

[95] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ២០៣។

[96] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៤ វាក្យខណ្ឌទី២។

[97] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៦។

ដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍ និងការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព។

**២.១. ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍**

ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍ តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តីហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យតាមពាក្យសុំរបស់កូនបំណុល (មាត្រា៥៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ការបង្គាប់នេះ ហៅថាការបង្គាប់ឱ្យដាក់ពាក្យបណ្តឹង។ គោលបំណងនៃការបង្គាប់នេះ គឺដើម្បីបង្ខំឱ្យម្ចាស់បំណុលទៅទទួលលិខិតអនុវត្តសម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិដែលត្រូវបានរក្សាការពារ។ ការកំណត់បែបនេះនឹងទប់ស្កាត់នូវការខូចខាតធ្ងន់ធ្ងរដែលអាចនឹងកើតមានដល់កូនបំណុល ដោយសារទុកស្ថានភាពដែលមានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នឱ្យយូរអង្វែង។ ហេតុនេះហើយ ការបង្គាប់ឱ្យដាក់ពាក្យបណ្តឹងអាចចេញបានដោយពុំមានលក្ខខណ្ឌទាមទារអ្វីទេ ប្រសិនបើមានពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនៃការដាក់ពាក្យបណ្តឹងអង្គសេចក្តីមិនត្រូវតិចជាង ២ (ពីរ) សប្តាហ៍ទេ។[98]

ប្រសិនបើម្ចាស់បំណុល មិនដាក់ឯកសារបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការបង្គាប់ឱ្យដាក់ពាក្យបណ្តឹងទេ តុលាការត្រូវលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំរបស់កូនបំណុល (មាត្រា៥៥៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ប្រសិនបើនៅក្រោយពេលដាក់ឯកសារបញ្ជាក់នេះហើយពាក្យបណ្តឹងអង្គសេចក្តីត្រូវបានដកវិញ ឬត្រូវបានលើកចោលនោះត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ ហើយករណីនេះ ក៏នឹងនាំទៅដល់ការចេញដីកាសម្រេចលុបចោលផងដែរ (មាត្រា៥៥៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ការចាប់ផ្តើមនីតិវិធីមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចសន្យាមជ្ឈត្តកម្មអំពីអង្គសេចក្តី (មាត្រា៥៥៧ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងការចាប់ផ្តើមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រសិនបើអង្គសេចក្តី គឺជារឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងក៏ត្រូវចាត់ទុកថាជាការដាក់ពាក្យបណ្តឹងអង្គសេចក្តីដែរ។ ដីកាសម្រេចលុបចោល ត្រូវបញ្ជូនទៅភាគី (មាត្រា៥៥៧ កថាខណ្ឌទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយបណ្តឹងជំទាស់អាចធ្វើបានចំពោះដីកាសម្រេចនេះ។[99]

**២.២. ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព**

ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ

[98] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៥៧ កថាខណ្ឌទី២។

[99] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១ ចំណុចក។

ភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នតាមពាក្យសុំរបស់កូនបំណុលបាន (មាត្រា៥៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ការផ្លាស់ប្តូរស្ថានភាពនេះត្រូវបានបែងចែកជាពីរប្រភេទ៖

**ប្រភេទទីមួយ** គឺករណីដែលនៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នមានការកើតឡើងនូវអង្គហេតុថ្មីដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះមានភាពមិនត្រឹមត្រូវ។ ជាក់ស្តែង ករណីដែលសិទ្ធិទាមទារទាំងអស់ដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នត្រូវបានសងគ្រប់ចំនួន ករណីដែលមានសាលក្រមនៃការជំនុំជម្រះលើកទី១ សម្រេចឱ្យម្ចាស់បំណុលចាញ់ក្តី នៅក្នុងបណ្តឹងអង្គសេចក្តី ករណីដែលកូនបំណុលក្លាយជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ដើម្បីសង ករណីដែលម្ចាស់បំណុលមិនធ្វើការអនុវត្តដោយបង្ខំ បើទោះបីជាបានបំពេញគ្រប់លក្ខខណ្ឌទាមទារដែលអាចអនុវត្តដោយបង្ខំបានហើយក៏ដោយជាអាទិ៍។

**ប្រភេទទីពីរ** គឺករណីដែលកូនបំណុលបានដឹងអំពីអង្គហេតុដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ មានភាពមិនត្រឹមត្រូវ ឬអាចធ្វើសេចក្តីបញ្ជាក់ដំបូងអំពីហេតុនោះ នៅក្រោយពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ទោះបីអង្គហេតុនោះបានកើតឡើងនៅពេលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នក៏ដោយ។ នៅក្នុងករណីនេះ កូនបំណុលត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង អំពីការផ្លាស់ប្តូរស្ថានភាពនោះ (មាត្រា៥៥៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## កថាភាគទី៣. បណ្តឹងជំទាស់

### ៣.១. អត្ថន័យនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកា។[100] នីតិវិធីនៃបណ្តឹងជំទាស់ មានលក្ខណៈងាយស្រួល និងឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្តឹងឧទ្ធរណ៍ ឬសាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេច។ បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហេតុដូច្នេះ ត្រង់ចំណុចនោះ ខុសពីការតវ៉ាដែលជាឧបាស្រ័យចំពោះដីកាសម្រេចទៅតុលាការសាមី។ ដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានទេ។[101] បណ្តឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។[102]

[100] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ១, នីតិវិធីបណ្តឹង. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ២២៥។

[101] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

[102] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២។

### ៣.២. ការធ្វើបណ្តឹងជំទាស់

ប្រសិនបើភាគីដែលបានគិតថា សិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន បានខូចខាតដោយសារដីកាសម្រេចរបស់តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ភាគីនោះអាចធ្វើបណ្តឹងជំទាស់ទៅតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់តាមនីតិវិធីដូចខាងក្រោម៖

#### ៣.២.១. តុលាការមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់ គឺជាតុលាការជាន់ខ្ពស់នៃតុលាការដែលចេញដីកាសម្រេច។ ជាក់ស្តែង សាលាដំបូងចេញដីកាសម្រេច ដូច្នេះ សាលាឧទ្ធរណ៍ គឺជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់។

#### ៣.២.២. ដីកាសម្រេច និងអំឡុងពេលដែលអាចប្តឹងជំទាស់

ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ អាចប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលបានទទួលការបញ្ជូននោះ៖

ក. ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ។

ខ. ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ។

គ. ដីកាសម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា៥៥៥ (ដីកាសម្រេចបង្គាប់ឱ្យធ្វើបដិទាន) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា នៅក្នុងកថាខណ្ឌទី១ មាត្រា៥៦០ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារជាអាទិ៍)។[103]

ប៉ុន្តែ បណ្តឹងជំទាស់មិនអាចអនុវត្តបានឡើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដែលបានធ្វើឡើងដោយតុលាការនៃបណ្តឹងជំទាស់។

បណ្តឹងជំទាស់ចំពោះសេចក្តីសម្រេចលើកចោល ត្រូវបានធ្វើឡើងចំពោះសេចក្តីសម្រេច ដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលអាចប្តឹងជំទាស់បាន ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង។[104]

### ៣.៣. របៀបប្តឹងជំទាស់

ដើម្បីប្តឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើម។ តុលាការដើម ត្រូវផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។

ពាក្យបណ្តឹងជំទាស់ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីចំណុចសំខាន់ៗដូចខាងក្រោម៖

---

[103] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៦១ កថាខណ្ឌទី១។

[104] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៥៤៤ កថាខណ្ឌទី១។

ក. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ. សញ្ញាណនៃដីកាសម្រេច

គ. សេចក្តីដែលសុំប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ

ឃ. មូលហេតុនៃបណ្តឹងជំទាស់។[105]

ក្នុងករណីដែលពុំបានសរសេរឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើមក្នុងពាក្យបណ្តឹងជំទាស់ទេ ម្ចាស់បណ្តឹងជំទាស់គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីចំណុចនោះទៅតុលាការក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹងជំទាស់នោះ។[106]

**៣.៤. អានុភាពនៃបណ្តឹងជំទាស់**

ជាគោលការណ៍ នៅក្នុងនីតិវិធីបណ្តឹងអង្គសេចក្តី បណ្តឹងជំទាស់មានអានុភាព ដូចជាៈ

ក. អានុភាពផ្អាកនូវការចូលជាស្ថាពរនៃដីកាសម្រេចដើម

ខ. អានុភាពនៃការផ្ទេរការជម្រះក្តី

គ. ការផ្អាកអានុភាពនៃដីកាសម្រេចដើម។[107]

អានុភាពផ្អាកនូវការចូលជាស្ថាពរនៃដីកាសម្រេចដើម ជាស្ថានភាពដែលរាំងការចូលជាស្ថាពរនៃដីកាសម្រេចរបស់តុលាការដើម ដោយសារអានុភាពនៃការដាក់ពាក្យបណ្តឹងជំទាស់តាមកំណត់ច្បាប់។

បណ្តឹងជំទាស់ ដែលបានធ្វើឡើងក្នុងអំឡុងពេល ដែលច្បាប់បានកំណត់មានអានុភាពផ្ទេរការទាមទារពីសាលាដំបូងទៅសាលាឧទ្ធរណ៍ មានន័យថាវិវាទរវាងម្ចាស់បំណុល និងកូនបំណុលនៅតុលាការជាន់ទាបមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការជាន់ទាបទៀតទេ ពោលគឺស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការ នៃបណ្តឹងជំទាស់។

បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម មានន័យថាក្នុងករណីដែលដីកាសម្រេចអំពីបណ្តឹងជំទាស់មិនទាន់បានចេញដីកាសម្រេចដើម មិនអាចមានអានុភាពអនុវត្តឡើយ។ ក្នុងអំឡុងពេលរហូតដល់ចេញសេចក្តីសម្រេចអំពីបណ្តឹងជំទាស់មានអានុភាព តុលាការនៃបណ្តឹងជំទាស់អាចចេញដីកាសម្រេចដែលបានកំណត់ដូចជា (១) បង្គាប់ឱ្យផ្អាកអានុភាពដីកាសម្រេចដើម ដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់

[105] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៣៥ មាត្រា៣០៤ កថាខណ្ឌទី២ មាត្រា២៦៥ កថាខណ្ឌទី២ និងមាត្រា៣០១ កថាខណ្ឌទី១។

[106] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣០១ កថាខណ្ឌទី២។

[107] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣០៥។

ប្រាតិភោគ និង (២) បង្គាប់ឱ្យផ្អាកនីតិវិធីអនុវត្តមួយផ្នែក ឬទាំងមូលដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ។[108]

**៣.៥. ការវិនិច្ឆ័យលើបណ្តឹងជំទាស់**

ក្នុងនីតិវិធីនៃបណ្តឹងជំទាស់ ត្រូវយកនីតិវិធីនៃការតវ៉ាចំពោះដីកាសម្រេចយកមកអនុវត្តនៅក្នុងនីតិវិធីបណ្តឹងជំទាស់នេះ ដែលមានដូចខាងក្រោមនេះ៖

**ការវិនិច្ឆ័យ៖** ការសម្រេចសេចក្តីលើបណ្តឹងជំទាស់ អាចធ្វើបានដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់។[109] ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់មិនធ្វើការទាញហេតុដោយផ្ទាល់មាត់អំពីបណ្តឹងជំទាស់ទេ តុលាការអាចធ្វើការសាកសួរម្ចាស់បណ្តឹងជំទាស់ ឬអ្នកផ្សេងទៀត ដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃបណ្តឹងបាន។

**ការបញ្ចប់ការវិនិច្ឆ័យ៖** តុលាការត្រូវសម្រេចបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យមួយ ឬប្រកាសនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន។

**ដីកាសម្រេច៖** ការសម្រេចសេចក្តីលើបណ្តឹងជំទាស់ ធ្វើឡើងដោយដីកាសម្រេច។[110] ទន្ទឹមនឹងនេះ ខ្លឹមសារនៃដីកាសម្រេចលើបណ្តឹងជំទាស់រួមមាន៖

ក. លើកចោលបណ្តឹងជំទាស់

ខ. ច្រានចោលនូវបណ្តឹងជំទាស់/តម្កល់ដីកាសម្រេចទុកជាបានការ

គ. លុបចោលនូវដីកាសម្រេចដើម

ឃ. ផ្លាស់ប្តូរនូវដីកាសម្រេចដើម។

ក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់ចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នជាលើកទីមួយ បណ្តឹងជំទាស់មិនអាចធ្វើបានទេចំពោះដីកាសម្រេចនេះ ព្រោះដីកាសម្រេចនេះបានបំពេញលក្ខខណ្ឌនៃប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់រួចហើយ។ ផ្ទុយទៅវិញ ក្នុងករណីដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និងលើកចោលពាក្យសុំតវ៉ា ឬពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននោះ នៅក្នុងបណ្តឹងអង្គសេចក្តីដែលកំពុងត្រូវបានចាត់ការនៅសាលាឧទ្ធរណ៍នោះបណ្តឹងជំទាស់អាចធ្វើទៅតុលាការកំពូលបាន ដើម្បីធានាឱ្យបាននូវប្រព័ន្ធនៃការជម្រះក្តីពីរថ្នាក់។

---

[108] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៤៣ កថាខណ្ឌទី២។

[109] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា៣៣៥ មាត្រា៣០៦ កថាខណ្ឌទី២។

[110] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

**ការបញ្ជូន៖** បន្ទាប់ពីចេញដីកាសម្រេចអំពីបណ្ដឹងជំទាស់ នីតិវិធីនៃការបញ្ជូនទៅភាគីទាំងសងខាងនឹងត្រូវយកមកអនុវត្តផងដែរ។

**កថាភាគទី៤. ការសុំឱ្យជំនុំជម្រះសាជាថ្មី**

នៅក្នុងមាត្រា៥៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា មាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុវត្តដូចគ្នា នៅក្នុងករណី សេចក្ដីសម្រេចដែលអាចប្ដឹងជំទាស់បានចូលជាស្ថាពរហេតុនេះ សេចក្ដីសម្រេចទាក់ទងនឹងដីកាសម្រេចរក្សាការពារដែលអាចប្ដឹងជំទាស់ហើយបានចូលជាស្ថាពរអាចដាក់ពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី។

ដីកាសម្រេចរក្សាការពារ ត្រូវអនុវត្តដូចគ្នាតាមមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច) មូលហេតុយោងតាមមាត្រា៥៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ ត្រូវយកមកអនុវត្តដូចគ្នានឹងបញ្ញត្តិពីគន្ថីទី២ ដល់គន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏រាប់បញ្ចូលផងដែរ។ ទោះបីជាដីកាសម្រេចទាក់ទងនឹងនីតិវិធីចាត់ចែងរក្សាការពារក៏ដោយ ក៏ក្នុងករណីនៃដីកាសម្រេចដែលអាចប្ដឹងជំទាស់ ហើយបានចូលជាស្ថាពរ ត្រូវបានអនុវត្តដូចគ្នាតាមមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងអាចដាក់ពាក្យសុំឱ្យជំនុះជម្រះសារជាថ្មីបាន។ ករណីនេះក៏មិនខុសគ្នា ទាំងករណីបណ្ដឹងជំទាស់ផ្អែកតាមមាត្រា៥៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងករណីបណ្ដឹងជំទាស់ផ្អែកតាមមាត្រាមាត្រា៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ។

ទន្ទឹមនឹងនេះ មាត្រា៥៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បញ្ញត្តិយ៉ាងច្បាស់អំពីការអនុវត្តដូចគ្នាតាមមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែទោះបីគ្មានបញ្ញត្តិនេះក៏ដោយ ក៏មាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវអនុវត្តដូចគ្នាតាមមាត្រា ៥៣៩ នៃក្រមរដ្ឋប្បវេណី ដូច្នេះអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន។ មួយវិញទៀត តាមមាត្រា៥៦១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងអំពីការអនុវត្តដូចគ្នាតាមមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី គ្រាន់តែបញ្ញត្តិដែលបញ្ជាក់អំពីការអនុវត្តដូចគ្នាតាមមាត្រា៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីដោយផ្អែកតាមមាត្រា ៥៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីតែប៉ុណ្ណោះ។

ដីកាសម្រេចរក្សាការពារជាការវិនិច្ឆ័យជាលក្ខណៈបណ្ដោះអាសន្ន តាមរយៈតុលាការហើយមិនមែនជាដីកាសម្រេចដែលកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិរបស់គូភាគីនោះទេ។ ប៉ុន្តែដីកាសម្រេចរក្សាការពារកម្រិតកូនបំណុលធ្វើការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ឬ/និង កំណត់ឋានៈជាបណ្ដោះអាសន្នជាអាទិ៍ ដែលនាំឱ្យកើតមានឡើងនូវអានុភាពកំណត់ជាក់លាក់មួយ។ អានុភាពនេះ យ៉ាងហោចណាស់នឹងបន្តរហូតដល់បញ្ចប់បណ្ដឹងអង្គសេចក្ដី។ នៅពេលដីកាសម្រេចរក្សាការពារដែលបានចូលជាស្ថាពរមានវិការៈធ្ងន់ធ្ងរ ប្រសិនបើមិនអនុញ្ញាតឱ្យលុបចោលដីកាសម្រេចនេះទេ គូភាគីយ៉ាងហោចណាស់នឹងមិនអាចទ្រាំទ្រនឹងអានុភាពនៃដីកាសម្រេច

រក្សាការពារដែលមានវិការៈធ្ងន់ធ្ងរ រហូតដល់បណ្តឹងអង្គសេចក្តីបានបញ្ចប់ និងនាំឱ្យមានភាពផ្ទុយនឹងយុត្តិធម៌។ ហេតុនេះ ក្រមនីតិវិធីរដ្ឋប្បវេណីក៏អនុញ្ញាតឱ្យប្រព័ន្ធចាត់ចែងរក្សាការពារអនុវត្តដូចគ្នាតាមប្រព័ន្ធជំនុំជម្រះបណ្តឹងអង្គសេចក្តីចំពោះការជំនុំជម្រះសាជាថ្មី ប្រសិនបើមានមូលហេតុតាមច្បាប់កំណត់។

គូភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងការរឹបអូសជាបណ្តោះអាសន្ននេះ អាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបានចំពោះដីកាសម្រេចដែលបានចូលជាស្ថាពរ ក្នុងករណីដែលបណ្តឹងជំទាស់បានផុតអំឡុងពេល។

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ផ្នែកទី១. បញ្ហាប្រឈម

### កថាភាគទី១. បញ្ហាប្រឈមក្នុងនីតិវិធីនៃការសម្រេចសេចក្តី

ការទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជាដំណើរការមួយដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំ ដែលតម្រូវឱ្យមានការចូលរួមពីសំណាក់មន្ត្រីតុលាការ និងម្ចាស់បំណុលយ៉ាងសកម្ម។ ទន្ទឹមនឹងនេះ ដើម្បីបញ្ចៀសពីភាពស្មុគស្មាញ និងសាំញ៉ាំក្នុងនីតិវិធីនៃការសម្រេចសេចក្តី ម្ចាស់បំណុលទាមទារឱ្យមានចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងការចាត់ចែងរក្សាការពារ។ មួយវិញទៀត ក្នុងនីតិវិធីនៃការសម្រេចសេចក្តីនៅក្នុងសំណុំរឿងរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាពពីសំណាក់មន្ត្រីតុលាការផងដែរ។ ដូច្នេះ នៅក្នុងកថាភាគនេះនឹងរៀបរាប់ពីបញ្ហាប្រឈមនៅក្នុងនីតិវិធីនៃការសម្រេចសេចក្តីក្នុងសំណុំរឿងរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលធ្វើការបែងចែកជា ២ (ពីរ) ចំណុចធំៗ មានដូចជា (១.១) ទិដ្ឋភាពជាក់ស្តែងរបស់ចៅក្រមក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ និង (១.២) សកម្មភាពរបស់ម្ចាស់បំណុលក្នុងនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

#### ១.១. ទិដ្ឋភាពជាក់ស្តែងរបស់ចៅក្រមក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន

##### ១.១.១. ការយល់ដឹងរបស់ចៅក្រមនៅមានកម្រិត

ចៅក្រមត្រូវស្វែងយល់ឱ្យបានច្បាស់លាស់អំពីបទប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធដែលទាក់ទងនឹងគោលគំនិតនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដោយហេតុថា របបរក្សាការពារជានីតិវិធីមួយមានលក្ខណៈបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលដែលរងចាំសាលក្រមចុងក្រោយដែលត្រូវអនុវត្ត។ មួយវិញទៀត នៅពេលមានបណ្តឹងលើអង្គសេចក្តីដែលត្រូវចាត់ការនោះ គឺត្រូវចំណាយពេលវេលាវែងដែលមិនអាចកំណត់បាន នៅក្នុងអំឡុងពេលនីតិវិធីអង្គសេចក្តីនេះ ពេលខ្លះម្ចាស់បំណុលអាចបាត់បង់នូវផលប្រយោជន៍ ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុលដែលលាក់ទុកនូវទ្រព្យសម្បត្តិ តាមរយៈការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំ ប្រទានកម្ម សន្តតិកម្ម ហ៊ីប៉ូតែក ជាដើម ដែលធ្វើឱ្យម្ចាស់បំណុលជួបការលំបាកក្នុងការអនុវត្តសិទ្ធិនៅពេលឈ្នះក្តី។ ប្រសិនបើចៅក្រមដែលជាអ្នកសម្រេចសេចក្តីពុំបានយល់ដឹងពីគោលគំនិតសំខាន់ៗ នៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នោះនឹងបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលក្រោយពេលឈ្នះបណ្តឹងលើអង្គសេចក្តី។

ហេតុដូច្នេះ ចៅក្រមដែលជាអ្នកសម្រេចសេចក្តីត្រូវប្រឹងប្រែង ដើម្បីធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយភាពយុត្តិធម៌ និងឆាប់រហ័សក្នុងនាមជាអ្នកដឹកនាំនីតិវិធី ដោយអនុលោមតាមគោលគំនិតសំខាន់ៗនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

**១.១.២. ភាពយឺតយ៉ាវនៃនីតិវិធី**

ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ជានីតិវិធីមួយមានលក្ខណៈបណ្តោះអាសន្ន ហើយបន្ទាន់បង្ហំ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលរង់ចាំសេចក្តីសម្រេចចុងក្រោយដែលត្រូវអនុវត្តពោល គឺត្រូវអនុវត្តឱ្យបានលឿនមុនពេលកូនបំណុលចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន។ ហេតុនេះការអនុវត្តការរឹបអូសជាបណ្តោះអាសន្នអាចធ្វើទៅបាន មុនពេលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានបញ្ជូនទៅកូនបំណុល។ វិធានរក្សាការពារមានលក្ខណៈប្រញាប់ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬបង្ការកុំឱ្យមានការខូចខាតធ្ងន់ធ្ងរកើតមានឡើងចំពោះម្ចាស់បំណុល តាមរយៈការទទួលស្គាល់សិទ្ធិរបស់ម្ចាស់បំណុលនៅពេលមានការស្នើសុំដោយតុលាការមិនចាំបាច់ធ្វើការសាកសួរកូនបំណុលនោះទេ គ្រាន់តែពិនិត្យសេចក្តីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់។ ប៉ុន្តែ ក្នុងករណីខ្លះ ការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមានភាពយឺតយ៉ាវ និងមានភាពស្មុគស្មាញខ្លាំងដែលបណ្តាលឱ្យម្ចាស់បំណុលអាចបាត់បង់នូវផលប្រយោជន៍ ដោយសារតែចេតនាទុច្ចរិតរបស់កូនបំណុលដែលលាក់ទុកទ្រព្យសម្បត្តិ តាមរយៈការផ្ទេរ ការដោះដូរ ការលក់ ការបញ្ចាំ ប្រទានកម្ម សន្តតិកម្ម ហ៊ីប៉ូតែក ជាអាទិ៍ ដែលធ្វើឱ្យម្ចាស់បំណុលជួបការលំបាកក្នុងការអនុវត្តសិទ្ធិនៅពេលឈ្នះក្តី។ ភាពយឺតយ៉ាវនៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ដែលបណ្តាលមកពីភាពអសកម្មរបស់មន្ត្រីតុលាការ ឬពុំមានបទប្បញ្ញត្តិច្បាប់ចែងជាក់លាក់ពីថិរវេលាក្នុងការចេញសេចក្តីសម្រេចសម្រាប់ដាក់បន្ទុកដល់ចៅក្រមដែលទទួលបន្ទុកក្នុងសំណុំរឿងរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនេះ។ បញ្ហាយឺតយ៉ាវនេះអាចធ្វើប៉ះពាល់ដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើតុលាការ និងវិស័យយុត្តិធម៌ផង ហើយថែមទាំងប៉ះពាល់ដល់គោលគំនិតនៃក្រមនីតិវិធីទាក់ទងនឹងការរឹបអូសជាបណ្តោះអាសន្នផងដែរ។

**១.១.៣. ការធ្វេសប្រហែសក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន**

នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវសម្រេចអំពីប្រាក់រំដោះ ហើយចំនួនប្រាក់រំដោះត្រូវស្មើនឹងសិទ្ធិលើបំណុលសរុបដែលម្ចាស់បំណុលមានចំពោះកូនបំណុល គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ឬមានតម្លៃស្មើកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន។ ក្នុងករណីខ្លះ តុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយមិនសម្រេច ឬកំណត់អំពីចំនួនប្រាក់រំដោះ នាំឱ្យសេចក្តីសម្រេចនោះជាសេចក្តីសម្រេចដែលពុំទាន់មានភាពត្រឹមត្រូវពេញលេញ និងបំពានសិទ្ធិស្របច្បាប់របស់កូនបំណុលនឹងក្លាយជាមូលហេតុនៃការតវ៉ាចំពោះដីកាសម្រេចនោះ។ ម្យ៉ាងវិញទៀត

ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលមិនបានកំណត់អំពីចំនួនប្រាក់រំដោះ ជាការកើតឡើងនូវអំពើអនីត្យានុកូលសម្រាប់កូនបំណុលផងដែរ។

**១.២. សកម្មភាពរបស់ម្ចាស់បំណុលក្នុងនីតិវិធីចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន**

ម្ចាស់បំណុលមានតួនាទីសំខាន់ណាស់ ដើម្បីឱ្យនីតិវិធីរឹបអូសជាបណ្ដោះអាសន្នចាប់ផ្ដើម ដោយសារពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវចាប់ផ្ដើមតាមរយៈពាក្យសុំរបស់ម្ចាស់បំណុល។ ប្រសិនបើគ្មានពាក្យសុំរបស់ម្ចាស់បំណុល តុលាការក៏មិនអាចចេញដីកាសម្រេចរឹបអូសបានដែរ ព្រោះវាបំពានគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី។ ទន្ទឹមនឹងនេះ ចំណេះដឹងរបស់ម្ចាស់បំណុលពាក់ព័ន្ធនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ក៏ជាបញ្ហាប្រឈមមួយដ៏សំខាន់ផងដែរ ព្រោះប្រសិនបើម្ចាស់បំណុលពុំមានចំណេះដឹងផ្នែកច្បាប់ ហើយខ្លួនមិនបានពឹងពាក់មេធាវីដើម្បីផ្ដល់សេវាប្រឹក្សាផ្លូវច្បាប់ និងតំណាងឱ្យខ្លួនក្នុងនីតិវិធីក្យាការពារនោះ ម្ចាស់បំណុលអាចប្រឈមមុខនឹងការខាតបង់នូវផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន ក្នុងករណីដែលម្ចាស់បំណុលធ្វើសកម្មភាពខុសពីច្បាប់អនុញ្ញាត។ កត្តានេះ ក៏ជាកត្តាមួយដែលធ្វើឱ្យម្ចាស់បំណុលខូចខាតនូវផលប្រយោជន៍របស់ខ្លួនដោយសារសកម្មភាពខ្លះរបស់ម្ចាស់បំណុលបានធ្វើឡើយដោយបំពាន ឬដោយអសកម្មភាពព្រោះភាពមិនបានដឹងនីតិវិធី។

**កថាភាគទី២. បញ្ហាប្រឈមក្នុងនីតិវិធីនៃការអនុវត្តដីកាសម្រេច**

ក្រោយពេលដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុត្រូវបានចេញ នៅក្នុងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ មន្ត្រីអនុវត្ត និងម្ចាស់បំណុលចាំបាច់ត្រូវមានការយល់ដឹងពីផ្នែកច្បាប់ ដើម្បីជៀសវាងពីបញ្ហាប្រឈមមួយចំនួន ដែលអាចកើតឡើងក្នុងនីតិវិធីអនុវត្តដីកាសម្រេច។

ចំណុចខាងក្រោមនេះ ជាបញ្ហាប្រឈមក្នុងនីតិវិធីនៃការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ៖

**២.១. ទិដ្ឋភាពជាក់ស្ដែងរបស់មន្ត្រីអនុវត្ត (ក្រឡាបញ្ជី)**

**២.១.១. ភាពយឺតយ៉ាវនៃនីតិវិធី**

នៅក្នុងការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ក្រឡាបញ្ជីដែលមានតួនាទីជាជំនួយការស្ថាប័នតុលាការ និងជាអ្នករៀបចំទុកដាក់ឯកសាររដ្ឋបាល ដើម្បីឱ្យដំណើរការតុលាការប្រព្រឹត្តបានល្អ។ ក្រៅពីនេះ ក៏ដើរតួនាទីសំខាន់ក្នុងការរៀបចំលិខិតផ្ទុកផ្ដាក់ចុះបញ្ជីអចលនវត្ថុ ហើយក៏ជាសេនាធិការមួយរូបក្នុងការរៀបចំលិខិតផ្ទុកផ្ដាក់ និងបញ្ជូនឯកសារទៅរដ្ឋបាលសុរិយោដី។

កិច្ចការងារសំខាន់បំផុតគឺ ក្រឡាបញ្ជី ជាអ្នកធ្វើលិខិតផ្ទុកផ្ដាក់រឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុទៅរដ្ឋបាលសុរិយោដីថ្នាក់ជាតិ និងស្ថាប័នពាក់ព័ន្ធទើបអចលនវត្ថុនោះ អាចចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន

តាមអំណាចដោយបង្ខំរបស់តុលាការបាន។[111] ភាពយឺតយ៉ាវក្នុងការចេញលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី ក្រោយពេលម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តរក្សាការពារ អាចធ្វើឱ្យម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍របស់ខ្លួន ដោយសារកូនបំណុលអាចដឹងខ្លួន ហើយឆ្លៀតឱកាសចាត់ចែងទ្រព្យរបស់ខ្លួន ដើម្បីបញ្ចៀសពីការរឹបអូសជាបណ្ដោះអាសន្នរបស់ម្ចាស់បំណុលតាមរយៈតុលាការ។ ម្យ៉ាងវិញទៀត សំណុំរឿងអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុខ្លះ អាចត្រូវបានទុកចោល ឬកប់ចោលដែលជាហេតុនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ម្ចាស់បំណុល។

### ២.១.២. ការបញ្ជូនលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

ការបញ្ជូនលិខិតផ្ទុកផ្ដាក់ទៅមន្ត្រីសុរិយោដី ជាសមត្ថកិច្ចរបស់ក្រឡាបញ្ជី ដោយហេតុថា ក្រឡាបញ្ជីជាអ្នកទទួលបន្ទុកចាត់ចែងកិច្ចការបញ្ជូនរបស់តុលាការ។ ភាពយឺតយ៉ាវនៃការបញ្ជូនលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី គឺជាកំហុសនីតិវិធីមួយដែលធ្វើឱ្យម្ចាស់បំណុលបាត់បង់នូវផលប្រយោជន៍ ដោយសារកូនបំណុលលួចចាត់ចែងនូវទ្រព្យសម្បត្តិរបស់ខ្លួន មុនពេលលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីបានទៅដល់មន្ត្រីសុរិយោដី។ ភាពយឺតយ៉ាវនេះថែមទាំងធ្វើប៉ះពាល់ដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើតុលាការ និងវិស័យយុត្តិធម៌ផងដែរ ដោយសារពុំមានបទប្បញ្ញត្តិច្បាប់ណាមួយ ដែលបានកំណត់ថិរវេលាច្បាស់លាស់ក្នុងការបញ្ជូនសម្រាប់ដាក់បន្ទុកដល់ក្រឡាបញ្ជី ដើម្បីអនុវត្តតួនាទីរបស់ខ្លួន។ ពេលខ្លះក្រឡាបញ្ជីមិនបានអនុវត្តការបញ្ជូនឱ្យបានត្រឹមត្រូវតាមនីតិវិធីបញ្ជូនដែលកំណត់ក្នុងច្បាប់តាមរយៈស្ថាប័នដែលទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនឡើយ ដោយហេតុថា ការធ្វើបែបនេះត្រូវចំណាយសោហ៊ុយច្រើន និងប្រើប្រាស់ពេលវេលាច្រើន។ ដូច្នេះ ក្រឡាបញ្ជីបានប្រើម្ចាស់បំណុល ឬមេធាវីរបស់ម្ចាស់បំណុលដើម្បីបញ្ជូនលិខិតផ្ទុកផ្ដាក់ជំនួសខ្លួន។

### ២.២. ទិដ្ឋភាពជាក់ស្ដែងរបស់មន្ត្រីចុះបញ្ជីផ្ទុកផ្ដាក់ (មន្ត្រីសុរិយោដី)

ចំណេះដឹងរបស់មន្ត្រីសុរិយោដី ដែលទទួលបន្ទុកក្នុងការចុះបញ្ជីផ្ទុកផ្ដាក់ការរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុ តាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជីនៅមានកម្រិត។ ដោយហេតុថា នៅមុនពេលដែលមានប្រកាសអន្តរក្រសួងស្ដីពី នីតិវិធីនៃការចុះបញ្ជីទាក់ទងទៅនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីនោះ ការចុះបញ្ជីចំពោះអចលនវត្ថុដែលមិនចុះបញ្ជី មន្ត្រីសុរិយោដី មិនមានទម្រង់ច្បាស់លាស់សម្រាប់ធ្វើការផ្ទុកផ្ដាក់អចលនវត្ថុនោះទេ ហើយក៏មិនមានបទប្បញ្ញត្តិណាមួយត្រូវបានបង្កើតឡើងនៅឡើយ។ ដូច្នេះ ការចុះបញ្ជីរបស់មន្ត្រីសុរិយោដី គឺអនុវត្តតាមទម្លាប់តែប៉ុណ្ណោះ។ ទោះបីជាបច្ចុប្បន្ននេះមានប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងទៅនឹងការចាត់ចែងរក្សាការពារ

[111] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១, ប្រការ៧។

និងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីនោះ ក៏ការចុះបញ្ជីផ្ទុកផ្ដាក់នៅមានភាពយឺតយ៉ាវ និងស្មុគស្មាញផងដែរ ដោយមន្ត្រីសុរិយោដីមួយចំនួននៅតែមិនទាន់យល់ដឹងច្បាស់ពីនីតិវិធីនៃការចុះបញ្ជីផ្ទុកផ្ដាក់តាមប្រកាសអន្តរក្រសួងខាងលើផងដែរ។

**កថាភាគទី៣. ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល**

ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវធ្វើឡើងចំពោះអចលនវត្ថុរបស់កូនបំណុលតែប៉ុណ្ណោះ។ ករណីខ្លះដោយសារការធ្វេសប្រហែស ឬកំហុសជាណាមួយរបស់ម្ចាស់បំណុលក្នុងការស្វែងរកអត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុល ដែលធ្វើឱ្យការរឹបអូសជាបណ្ដោះអាសន្នបែរជាត្រូវបានធ្វើឡើងចំពោះអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល តែជាអចលនវត្ថុរបស់តតិយជន ឬរដ្ឋ។

នៅក្នុងកថាភាគនេះនឹងរៀបរាប់អំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនមែនជារបស់កូនបំណុលដូចខាងក្រោម៖

**៣.១. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់តតិយជន**

ការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ មានគោលដៅកម្រិតនូវសិទ្ធិចាត់ចែងនូវទ្រព្យសម្បត្តិរបស់កូនបំណុល។ ករណីខ្លះ ម្ចាស់បំណុលបានដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល តុលាការក៏បានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយម្ចាស់បំណុលបានដាក់ពាក្យសុំអនុវត្តរក្សាការពារ និងតុលាការបានធ្វើលិខិតផ្ទុកផ្ដាក់ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នទៅរដ្ឋបាលសុរិយោដី។ ប៉ុន្តែលិខិតផ្ទុកផ្ដាក់ចុះបញ្ជីអំពីការរឹបអូសបានទៅដល់រដ្ឋបាលសុរិយោដីនៅក្រោយកាលបរិច្ឆេទ ដែលអចលនវត្ថុរបស់កូនបំណុលកំពុងស្ថិតក្នុងនីតិវិធីផ្ទេរកម្មសិទ្ធិពីកូនបំណុលទៅតតិយជន។ ករណីនេះ នៅពេលដែលរដ្ឋបាលសុរិយោដីបានទទួលលិខិតផ្ទុកផ្ដាក់ដូចករណីខាងលើ រដ្ឋបាលសុរិយោដីត្រូវឆ្លើយតបទៅតុលាការ ដោយមិនអាចចុះបន្ទុកតាមខ្លឹមសារនៃលិខិតរបស់តុលាការបានឡើយ ដោយមូលហេតុថា រដ្ឋបាលសុរិយោដីបានទទួលសំណុំបែបបទចុះបញ្ជីលក់ទិញរបស់កូនបំណុលទៅឱ្យអ្នកទិញ (តតិយជន) មុនពេលទទួលសំណុំបែបបទរបស់តុលាការ ផ្អែកតាមប្រការ៩ កថាខណ្ឌទី៤ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ៣០ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ និងមាត្រា៥៦៧ កថាខណ្ឌទី៤ មាត្រា៤២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះកម្មវត្ថុនៃការរក្សាការពារនេះមិនមែនជាទ្រព្យសម្បត្តិរបស់កូនបំណុលឡើយ។ បញ្ហានេះ ក៏ជាបញ្ហាប្រឈមមួយដែលធ្វើឱ្យម្ចាស់បំណុលខាតបង់នូវពេលវេលា និងផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួនផងដែរ។

**ឧទាហរណ៍៖** ក្នុងករណីដែលម្ចាស់បំណុល បានដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះដី ០១ (មួយ) កន្លែង របស់កូនបំណុល ខាងតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ហើយម្ចាស់បំណុលក៏បានដាក់ពាក្យសុំអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ហើយតុលាការបានធ្វើលិខិតផ្ទុកផ្ដាក់ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ទៅរដ្ឋបាលសុរិយោដី

ដោយលិខិតផ្ទុកផ្ដាក់នោះបានទៅដល់ខាងសុរិយោដីចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ នៅខណៈពេលដែលដី ០១ (មួយ) កន្លែងនោះ ស្ថិតក្នុងនីតិវិធីផ្ទេរកម្មសិទ្ធិពីឈ្មោះកូនបំណុលទៅឱ្យតតិយជនម្នាក់ទៀត ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣។ នៅក្នុងករណីនេះរដ្ឋបាលសុរិយោដីមិនអាចចុះបន្ទុកអំពីការរឹបអូសជាបណ្ដោះអាសន្ន តាមខ្លឹមសារនៃលិខិតរបស់ខាងតុលាការបានឡើយ ដោយសារតែអចលនវត្ថុដែលជាដី ០១ (មួយ) កន្លែង នោះ មិនមែនជាកម្មសិទ្ធិរបស់កូនបំណុលទៀតឡើយ។

**៣.២. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ**

ករណីខ្លះ ម្ចាស់បំណុលបានដាក់ពាក្យសុំដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់ កូនបំណុល ដោយសារការអះអាងរបស់កូនបំណុលថាអចលនវត្ថុនោះជារបស់ខ្លួន ដើម្បីធ្វើឱ្យម្ចាស់បំណុល មានជំនឿទុកចិត្តពេលបង្កើតសិទ្ធិលើបំណុលរបស់ខ្លួនជាមួយម្ចាស់បំណុល។ ករណីនេះ តុលាការក៏បានចេញ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នតាមពាក្យសុំរបស់ម្ចាស់បំណុល។ ប៉ុន្តែ នៅពេលដែលតុលាការបាន ចេញលិខិតផ្ទុកផ្ដាក់តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុលទៅរដ្ឋបាលសុរិយោដី មន្ត្រីសុរិយោដីនឹងបដិសេធមិន ធ្វើការចុះបញ្ជីរឹបអូស ដោយហេតុថាអចលនវត្ថុនេះមិនមែនជាទ្រព្យសម្បត្តិរបស់កូនបំណុលតែជាទ្រព្យសម្បត្តិ របស់រដ្ឋ។ ករណីខាងលើ ក៏ជាបញ្ហាប្រឈមមួយដែលធ្វើឱ្យម្ចាស់បំណុលខាតបង់ពេលវេលា និងផលប្រយោជន៍ តាមផ្លូវច្បាប់របស់ខ្លួនផងដែរ។

**ឧទាហរណ៍៖** លោក **ក** និង លោក **ខ** បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគលើទំហំទឹកប្រាក់ ចំនួន ១០ ០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដោយលោក **ខ** យល់ព្រមយកដីរបស់ខ្លួនចំនួន ០១ (មួយ) កន្លែង ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខ០០០១ ដើម្បីដាក់ធានាឱ្យលោក **ក**។ ក្រោយមក លោក **ខ** មិនបានអនុវត្តកាតព្វកិច្ចសងប្រាក់ លោក **ក** បានដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្នលើដីរបស់លោក **ខ** ហើយតុលាការក៏បានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ បន្ទាប់មក តុលាការបានចេញលិខិតផ្ទុកផ្ដាក់ ចុះបញ្ជីលើដីនោះទៅរដ្ឋបាលសុរិយោដី ប៉ុន្តែរដ្ឋបាលសុរិយោដីបានបដិសេធមិនចុះបន្ទុកអំពីការរឹបអូសជា បណ្ដោះអាសន្នតាមខ្លឹមសារនៃលិខិតរបស់ខាងតុលាការបានឡើយ ដោយសារតែអចលនវត្ថុដែលជាដី ០១ (មួយ) កន្លែង នោះជាអចលនវត្ថុរបស់រដ្ឋ ហើយមិនមែនជាកម្មសិទ្ធិរបស់កូនបំណុលឡើយ។

**កថាភាគទី៤. បន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល**

**៤.១. បន្ទុកសោហ៊ុយសម្រាប់សេវាផ្នែកច្បាប់ និងសោហ៊ុយផ្សេងៗ**

ករណីម្ចាស់បំណុលពុំមានចំណេះដឹងផ្នែកច្បាប់ ឬការយល់ដឹងផ្នែកច្បាប់នៅមានកម្រិត ដើម្បីដំណើរការ នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុឱ្យមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់ ម្ចាស់បំណុល គប្បីរកសេវាផ្នែកច្បាប់ពីមេធាវីសម្រាប់ពិគ្រោះយោបល់ និងតំណាងឱ្យខ្លួននៅក្នុងនីតិវិធីរក្សាការពារ ជៀសវាង ការធ្វើសកម្មភាពណាមួយដែលខូចខាតនូវផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។ ករណីនេះ ម្ចាស់បំណុលត្រូវរក សេវាផ្នែកច្បាប់ពីបុគ្គលដែលមានវិជ្ជាជីវៈ និងចំណេះដឹងផ្នែកច្បាប់ ហើយបុគ្គលដែលច្បាប់អនុញ្ញាតឱ្យផ្ដល់ សេវាផ្នែកច្បាប់ឱ្យម្ចាស់បំណុល គឺជាមេធាវី។ ប៉ុន្តែ ដោយហេតុថាមេធាវី ជាបុគ្គលឯកជនមិនមែនជាមន្ត្រីរាជការ

ដូច្នេះ ម្ចាស់បំណុលចាំបាច់ត្រូវចំណាយប្រាក់ផ្ទាល់ខ្លួន ដើម្បីពឹងពាក់សេវាមេធាវីសម្រាប់ការពារផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។

ទន្ទឹមនឹងនេះ ម្ចាស់បំណុលត្រូវទទួលខុសត្រូវលើបន្ទុកសោហ៊ុយផ្សេងៗមានដូចជា ពន្ធដាក់ពាក្យសុំប្រាក់ប្រដាប់ក្តីរបស់តុលាការក្រៅពីពន្ធ សោហ៊ុយក្នុងការធ្វើដំណើរ និងសេវារដ្ឋបាលក្នុងការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ជាអាទិ៍។

### ៤.២. បន្ទុកសោហ៊ុយក្នុងការស្វែងរកអត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុល

ការស្វែងរកអត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុល គឺជាបន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល ដោយហេតុថា ច្បាប់បានផ្តល់បន្ទុកហានិភ័យនេះចំពោះម្ចាស់បំណុលក្នុងស្វែងរក ដើម្បីទទួលបានការការពារនូវសិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់របស់ខ្លួន។ ករណីនេះ អចលនវត្ថុដែលកម្មវត្ថុនៃការស្វែងរកត្រូវបានបែងចែកជា ២ (ពីរ) ទម្រង់ដូចជា អចលនវត្ថុដែលបានចុះបញ្ជី និងអចលនវត្ថុដែលមិនបានចុះបញ្ជី។

#### ៤.២.១. អចលនវត្ថុដែលបានចុះបញ្ជី

ក្នុងការស្វែងរកអត្តសញ្ញាណអចលនវត្ថុដែលបានចុះបញ្ជីរបស់កូនបំណុល ម្ចាស់បំណុលត្រូវចំណាយសោហ៊ុយផ្សេងៗយ៉ាងច្រើន ដើម្បីស្វែងរកទិន្នន័យដែលពាក់ព័ន្ធនឹងអត្តសញ្ញាណអចលនវត្ថុ ដែលចុះបញ្ជីរបស់កូនបំណុលនៅស្ថាប័នមានសមត្ថកិច្ចក្នុងការកំណត់អត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុលឱ្យត្រឹមត្រូវ និងច្បាស់លាស់។ ស្ថាប័នមានសមត្ថកិច្ចមានដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានពន្ធដារ ជាដើម។ ការស្វែងរកទិន្នន័យនៃអចលនវត្ថុរបស់អ្នកដទៃ គឺជាការពិបាក និងត្រូវចំណាយខ្ពស់ ព្រោះបច្ចុប្បន្ននេះ ពុំទាន់មានលិខិតបទដ្ឋានគតិយុត្ត ឬ ស្ថាប័នផ្លូវការណាមួយ ដែលអនុញ្ញាតឱ្យម្ចាស់បំណុលអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅស្វែងរកទិន្នន័យទ្រព្យសម្បត្តិរបស់អ្នកដទៃឡើយ។ ដោយសារតែបច្ចុប្បន្ននេះការស្វែងរកអត្តសញ្ញាណអចលនវត្ថុរបស់កូនបំណុល គឺជាការស្វែងរកក្រៅឯកសារក្រៅផ្លូវការតាមរយៈមន្ត្រីដែលបម្រើការតាមស្ថាប័នដែលទទួលបន្ទុកក្នុងការគ្រប់គ្រងទិន្នន័យនៃការចុះបញ្ជីអចលនវត្ថុ។ ដូច្នេះសោហ៊ុយនៃការស្វែងរកចំពោះអត្តសញ្ញាណអចលនវត្ថុដែលបានចុះបញ្ជីរបស់កូនបំណុលត្រូវការចំណាយខ្ពស់ ព្រោះមិនទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយកំណត់ពីកម្រៃសេវាសាធារណៈជាក់លាក់ណាមួយឡើយ។

#### ៤.២.២. អចលនវត្ថុដែលមិនបានចុះបញ្ជី

ការស្វែងរកអត្តសញ្ញាណអចលនវត្ថុដែលមិនបានចុះបញ្ជី គឺមានភាពលំបាកយ៉ាងខ្លាំង និងត្រូវចំណាយខ្ពស់ ដោយហេតុថាបច្ចុប្បន្ននេះពុំទាន់ស្ថាប័នផ្លូវការ ឬលិខិតបទដ្ឋានគតិយុត្តណាមួយសម្រាប់គ្រប់គ្រងទិន្នន័យអចលនវត្ថុដែលមិនបានចុះបញ្ជីនៅឡើយ។ ករណីនេះ ម្ចាស់បំណុលត្រូវចំណាយសោហ៊ុយចុះទៅស្វែងរកនៅតាមអាជ្ញាធរមូលដ្ឋាន ឬអគ្គនាយកដ្ឋានពន្ធដារ។ ប៉ុន្តែ ដោយសារអចលនវត្ថុរបស់កូនបំណុលមិនទាន់ត្រូវបានចុះបញ្ជី ដូច្នេះការស្វែងរកអត្តសញ្ញាណនៃអចលនវត្ថុនោះ ត្រូវចំណាយខ្ពស់ និងភាពលំបាកខ្លាំងក្នុងការកំណត់អត្តសញ្ញាណរបស់ម្ចាស់។ ទន្ទឹមនឹងនេះ ទោះបីម្ចាស់បំណុលបានចំណាយសោហ៊ុយច្រើនសម្រាប់

ស្វែងរកអត្តសញ្ញាណក៏ដោយ ក៏មិនប្រាកដថាម្ចាស់បំណុលអាចទទួលបានអត្តសញ្ញាណពីអចលនវត្ថុរបស់កូនបំណុលផងដែរ។

**៤.៣. សោហ៊ុយអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនបានចុះបញ្ជី**

ដើម្បីអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជី គឺជាបន្ទុកសោហ៊ុយយ៉ាងធ្ងន់ធ្ងរសម្រាប់ម្ចាស់បំណុលដែលកំពុងទទួលការខូចខាតផលប្រយោជន៍ពីសំណាក់កូនបំណុល។ ដោយហេតុថា ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុមិនបានចុះបញ្ជី ម្ចាស់បំណុលដែលមានក្នុងលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីមានកាតព្វកិច្ចបង់ជាមុននូវការចំណាយក្នុងការចុះបញ្ជីដីលើកដំបូង ដើម្បីឱ្យអចលនវត្ថុដែលមិនបានចុះបញ្ជីរបស់កូនបំណុលក្លាយជាអចលនវត្ថុដែលបានចុះបញ្ជីវិញ ទើបម្ចាស់បំណុលអាចប្រើប្រាស់យន្តការរក្សាការពារយ៉ាងមានប្រសិទ្ធភាព ដែលបញ្ហានេះ បានក្លាយជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ម្ចាស់បំណុល ដែលត្រូវទទួលរងការខាតបង់ពីសំណាក់កូនបំណុលហើយ បែរជាមកត្រូវទទួលបន្ទុកសោហ៊ុយក្នុងការចុះបញ្ជីដីលើដំបូងជំនួសកូនបំណុលទៀត។ ទន្ទឹមនឹងនេះ ករណីម្ចាស់បំណុលមិនបានបង់សោហ៊ុយចាំបាច់សម្រាប់ចុះបញ្ជីលើកដំបូងនោះទេ មន្ត្រីចុះបញ្ជីមានសិទ្ធិផ្អាកនីតិវិធីចុះបញ្ជីលើកដំបូងចំពោះដីនោះបាន។

## ផ្នែកទី២. ដំណោះស្រាយ

### កថាភាគទី១. ដំណោះស្រាយក្នុងនីតិវិធីនៃការសម្រេចសេចក្តី

**១.១. ដំណោះស្រាយនៃបញ្ហាប្រឈមពាក់ព័ន្ធនឹងចៅក្រម**

**១.១.១. ការពង្រឹងចំណេះដឹងតាមរយៈការបណ្តុះបណ្តាលបន្ត**

ចំណេះដឹងរបស់អ្នកអនុវត្តច្បាប់ ក៏ដូចជាមនុស្សគ្រប់រូបអាចទទួលបាន ដោយសារការទទួលយកនូវបាតុភូតសង្គមនានា ឆ្លងកាត់បទពិសោធន៍របស់សង្គម និងការងារដែលជាវិជ្ជាជីវៈរបស់ខ្លួន។ ឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ ពិតជាកត្តាកំណត់ដ៏សំខាន់មួយ ប៉ុន្តែការចង់ដឹង ចង់យល់ ចង់ចេះរបស់បុគ្គលម្នាក់ៗ គឺអាស្រ័យទៅតាមឆន្ទៈរបស់បុគ្គលនោះ ពោលគឺចំណេះដឹងនូវបញ្ហាណាមួយក៏ចំណុះទៅតាមឆន្ទៈរបស់បុគ្គលនោះផងដែរ។ ចំណេះដឹងពិតប្រាកដ មិនអាចកើតមានដោយងាយស្រួលនោះឡើយ ប្រសិនបើពុំមានការតស៊ូ ព្យាយាម និងអត់ធ្មត់ក្នុងការស្វែងយល់។ ដូច្នេះ ដើម្បីចូលរួមក្នុងការអនុវត្តដោយប្រសិទ្ធភាពនូវក្រមនីតិវិធីរដ្ឋប្បវេណី ទាមទារឱ្យអ្នកអនុវត្តច្បាប់ត្រូវព្យាយាមធ្វើការសិក្សាជាប្រចាំដោយខ្លួនឯង រួមជាមួយនឹងការបណ្តុះបណ្តាលមកពីមជ្ឈដ្ឋានខាងក្រៅ ដើម្បីសន្សំនូវចំណេះដឹងទាំងនោះ។ អ្នកអនុវត្តច្បាប់ត្រូវមានជំនឿទុកចិត្តលើខ្លួនឯង ទើបអាចអូសទាញបាននូវជំនឿទុកចិត្តរបស់ពលរដ្ឋមកលើខ្លួនបាន រួមទាំងជំនឿទុកចិត្តលើស្ថាប័នតុលាការផងដែរ។

**១.១.២. ការពន្លឿននីតិវិធីនៃការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

ដើម្បីឱ្យនីតិវិធីសម្រេចសេចក្តីនៅក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុប្រកបដោយប្រសិទ្ធភាព និងមានភាពឆាប់រហ័ស ចៅក្រមត្រូវប្រឹងប្រែង ដើម្បីធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យ

ប្រព្រឹត្តទៅដោយភាពយុត្តិធម៌ និងឆាប់រហ័ស។ ក្នុងនាមជាអ្នកអនុវត្តនីតិវិធី ចៅក្រមត្រូវប្រឹងប្រែង និងគប្បីជៀសវាងនូវការប្រើពាក្យសម្តី ឬអំពើណាមួយដែលនាំឱ្យមានការសង្ស័យអំពីភាពយុត្តិធម៌ ដូចសុភាសិតច្បាប់មួយឃ្លាពោលថា "យុត្តិធម៌យឺតយ៉ាវស្មើនឹងការបដិសេធនូវយុត្តិធម៌" ជាពាក្យសុភាសិតច្បាប់ដែលត្រូវបានទទួលស្គាល់ជាសកល ដូច្នេះ តុលាការមិនត្រឹមតែប្រឹងប្រែងដោះស្រាយបណ្តឹង ពោលគឺដឹកនាំនីតិវិធីបណ្តឹងឱ្យប្រព្រឹត្តទៅដោយយុត្តិធម៌ប៉ុណ្ណោះទេ គឺថែមទាំងព្យាយាមអនុវត្តច្បាប់ស្តីពីនីតិវិធីដោយឆាប់រហ័សទៀតផងដែរ ទើបជាការដោះស្រាយដោយយុត្តិធម៌ពិតៗ។ ការជំនុំជម្រះក្តីត្រូវប្រតិបត្តិដោយត្រឹមត្រូវតាមច្បាប់។ នៅក្នុងវិវាទផ្នែករដ្ឋប្បវេណី ចៅក្រមត្រូវផ្អែកលើវិធាននៃការដោះស្រាយបណ្តឹង ដែលត្រូវបានកំណត់ក្នុងបទដ្ឋានគតិយុត្តស្តីពីនីតិវិធីរដ្ឋប្បវេណី និងលើមូលដ្ឋានច្បាប់សារធាតុ។ ទន្ទឹមនឹងនេះ គប្បីមានបទប្បញ្ញត្តិច្បាប់ចែងជាក់លាក់ពីថិរវេលាសម្រាប់ចៅក្រមក្នុងការចេញសេចក្តីសម្រេចដល់ម្ចាស់បំណុល ដើម្បីធានាពីភាពច្បាស់លាស់ក្នុងការអនុវត្តនីតិវិធីរឹបអូសជាបណ្តោះអាសន្ន។ ប្រសិនបើចៅក្រមមិនអនុវត្តតាមនីតិវិធីច្បាប់ដែលបានកំណត់ ឬមានចេតនាពន្យាពេល គប្បីមានទណ្ឌកម្មវិន័យណាមួយទៅលើចៅក្រមដែលប្រព្រឹត្តកំហុស។

ដូច្នេះ ចៅក្រមជាប្រធានមួយនៃសកម្មភាពនីតិវិធីដោះស្រាយបណ្តឹង ហើយត្រូវមានការទទួលខុសត្រូវ (កាតព្វកិច្ច) ធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយយុត្តិធម៌ និងប្រកបដោយភាពឆាប់រហ័ស។ ពិតមែនតែចៅក្រមមានសិទ្ធិសម្រេចសេចក្តី ប៉ុន្តែមិនមានន័យថា ការសម្រេចសេចក្តី (ដោះស្រាយបណ្តឹង) អាចធ្វើទៅបានដោយមិនគិតគូរចំពោះពេលវេលានោះឡើយ។

**១.១.៣. ទណ្ឌកម្មវិន័យ**

ករណីចៅក្រមដែលជាប្រធានមួយនៃសកម្មភាពនីតិវិធីដោះស្រាយបណ្តឹង ហើយត្រូវមានការទទួលខុសត្រូវ (កាតព្វកិច្ច) ធានារ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយយុត្តិធម៌ និងប្រកបដោយភាពឆាប់រហ័ស ប៉ុន្តែខ្លួនបែរជាបានប្រព្រឹត្តនៅកំហុសណាមួយពេលបំពេញមុខងារ គប្បីមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិណាមួយចែងកំណត់អំពីទណ្ឌកម្មវិន័យ ដើម្បីឱ្យការជំនុំជម្រះក្តីត្រូវប្រតិបត្តិដោយត្រឹមត្រូវតាមច្បាប់។

**១.២. ដំណោះស្រាយនៃបញ្ហាប្រឈមពាក់ព័ន្ធនឹងម្ចាស់បំណុល**

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ម្ចាស់បំណុលទាមទារឱ្យមានចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន។ ករណីនេះប្រសិនបើម្ចាស់បំណុលពុំមានចំណេះដឹងផ្នែកច្បាប់ ឬមានភាពមមាញឹកខ្លះ ដែលមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ម្ចាស់បំណុល អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាមរយៈអ្នកតំណាងដោយអាណត្តិរបស់ខ្លួន។ ជាគោលការណ៍ បុគ្គលដែលមានលក្ខណៈសម្បត្តិជាអ្នកតំណាងដោយអាណត្តិ ត្រូវតែជាមេធាវី។

## កថាភាគទី២. ដំណោះស្រាយបញ្ហាប្រឈមក្នុងនីតិវិធីនៃការអនុវត្តដីកាសម្រេច

### ២.១. ការពន្លឿននីតិវិធីរបស់មន្ត្រីអនុវត្ត (ក្រឡាបញ្ជី)

### ២.១.១. ឆន្ទៈក្នុងការអនុវត្តច្បាប់

ក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ និងជាសេនាធិការរបស់តុលាការ ក្រឡាបញ្ជី ត្រូវមានឆន្ទៈខ្ពស់ក្នុងការបម្រើសេវាកម្មផ្លូវច្បាប់ដល់ប្រជាពលរដ្ឋដែលមកពឹងពាក់ឱ្យមានភាពឆាប់រហ័ស ដើម្បីទទួលយុត្តិធម៌តាមរយៈតុលាការ។ ក្រឡាបញ្ជី ដែលមានតួនាទីសំខាន់ជាអ្នករៀបចំទុកដាក់ឯកសាររដ្ឋបាល ដើម្បីឱ្យដំណើរការតុលាការប្រព្រឹត្តបានល្អ ត្រូវចេញលិខិតផ្ទុកផ្ដាក់តាមការស្នើសុំរបស់ម្ចាស់បំណុលឱ្យបានឆាប់រហ័ស។ ម្យ៉ាងវិញទៀត ដើម្បីពង្រឹងក្នុងការអនុវត្តច្បាប់របស់ក្រឡាបញ្ជីក្នុងការចេញលិខិតផ្ទុកផ្ដាក់ឱ្យបានឆាប់រហ័ស ចាំបាច់ត្រូវមានបទប្បញ្ញត្តិច្បាប់កំណត់ជាក់លាក់ពីថិរវេលាក្នុងការចេញលិខិតផ្ទុកផ្ដាក់ ដើម្បីជាបន្ទុកសម្រាប់ក្រឡាបញ្ជី។ ករណីក្រឡាបញ្ជីមិនបាន ចេញលិខិតផ្ទុកផ្ដាក់តាមថិរវេលាដែលកំណត់ដោយច្បាប់ដោយសារចេតនាទុច្ចរិតណាមួយ ក្នុងគោលបំណងបង្កភាពលំបាកដល់ម្ចាស់បំណុល និងភាពយឺតយ៉ាវដល់នីតិវិធី គប្បីមានច្បាប់ ឬបទប្បញ្ញត្តិណាមួយចែងពីទណ្ឌកម្មវិន័យសម្រាប់ក្រឡាបញ្ជីដែលអនុវត្តខុសនីតិវិធីច្បាប់នោះ។

### ២.១.២. ការពង្រឹងនីតិវិធីបញ្ជូនលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័ស

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធ និងផលប្រយោជន៍។[112] ការបញ្ជូននេះត្រូវភ្ជាប់ជាមួយនូវអានុភាពគតិយុត្តផ្សេងទៀតមានដូចជា តាមរយៈការបញ្ជូននេះអំឡុងពេលដែលអាចប្ដឹងឧបាស្រ័យបាននឹងចាប់ផ្ដើមដំណើរការ។ ប្រសិនបើការបញ្ជូនមិនបានអនុវត្តត្រឹមត្រូវតាមនីតិវិធី ឬការបញ្ជូនមានភាពយឺតយ៉ាវដែលមិនអាចទទួលយកបាន គឺបណ្ដាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បំណុលយ៉ាងខ្លាំង។ ដូច្នេះ ដើម្បីឱ្យការបញ្ជូនមានប្រសិទ្ធភាព និងឆាប់រហ័ស ក្រឡាបញ្ជីគប្បីប្រើប្រាស់គ្រប់មធ្យោបាយបញ្ជូនលិខិតផ្ទុកផ្ដាក់ទៅមន្ត្រីសុរិយោដីឱ្យបានឆាប់រហ័ស ចៀសវាងទុកលិខិតផ្ទុកផ្ដាក់ចោល។ ដើម្បីពង្រឹងក្នុងការអនុវត្តច្បាប់របស់ក្រឡាបញ្ជីក្នុងការចេញលិខិតផ្ទុកផ្ដាក់ឱ្យបានឆាប់រហ័ស ចាំបាច់ត្រូវមានបទប្បញ្ញត្តិច្បាប់កំណត់ជាក់លាក់ពីថិរវេលាក្នុងការចេញនូវលិខិតផ្ទុកផ្ដាក់ជាបន្ទុកសម្រាប់ក្រឡាបញ្ជី។ ករណីក្រឡាបញ្ជីមិនបានចេញលិខិតផ្ទុកផ្ដាក់តាមថិរវេលាដែលកំណត់ដោយច្បាប់ គប្បីឱ្យមានការដាក់ទណ្ឌកម្មវិន័យសម្រាប់ក្រឡាបញ្ជីដែលអនុវត្តខុសនីតិវិធីច្បាប់។

[112] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ១, នីតិវិធីបណ្ដឹង. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០, ទំព័រ១១៧។

**២.២. ការពង្រឹងសមត្ថភាពរបស់មន្ត្រីចុះបញ្ជីផ្ទុកផ្តាក់ (មន្ត្រីសុរិយោដី)**

ដើម្បីឱ្យមន្ត្រីសុរិយោដីដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីផ្ទុកផ្តាក់កាន់តែមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសិក្ខាសាលាស្តីពីប្រធានបទពាក់ព័ន្ធនឹងការចុះបញ្ជីផ្ទុកផ្តាក់លើអចលនវត្ថុដែលតាមលិខិតផ្ទុកផ្តាក់របស់មន្ត្រីតុលាការ ឬរៀបចំការបណ្តុះបណ្តាលផ្ទៃក្នុងចំពោះមន្ត្រីសុរិយោដី។ មួយវិញទៀត មន្ត្រីសុរិយោដីខ្លួនឯងគប្បីមានឆន្ទៈខ្ពស់ក្នុងនាមជាមន្ត្រីបម្រើរាស្ត្រ និងអនុវត្តនីតិវិធីតាមច្បាប់កំណត់ជាធរមាន។ ម្យ៉ាងវិញទៀត ដើម្បីពង្រឹងដល់ការអនុវត្តការចុះបញ្ជីផ្ទុកផ្តាក់ឱ្យមានប្រសិទ្ធភាពខ្ពស់ ត្រូវមានច្បាប់កំណត់ជាក់លាក់ដើម្បីកំណត់ពីភារៈកិច្ចរបស់មន្ត្រីសុរិយោដី និងទណ្ឌកម្មចំពោះមន្ត្រីដែលមិនបានអនុវត្តតាមច្បាប់កំណត់។

**កថាភាគទី៣. ដំណោះស្រាយចំពោះការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល**

**៣.១. អចលនវត្ថុដែលជាកម្មសិទ្ធិរបស់តតិយជន**

មុនពេលម្ចាស់បំណុលសម្រេចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ម្ចាស់បំណុលត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀតផ្ទាត់អំពីអត្តសញ្ញាណអចលនវត្ថុដែលកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នមុនពេលខ្លួនដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ មួយវិញទៀត ម្ចាស់បំណុល ត្រូវតាមដានឱ្យបានជាប់លាប់ពីសកម្មភាពផ្សេងៗរបស់កូនបំណុល ដើម្បីបង្ការកូនបំណុលដែលមានចេតនាទុច្ចរិតក្នុងការចាត់ចែងទ្រព្យសម្បត្តិខ្លួនទៅតតិយជន ក្នុងគោលបំណងបញ្ចៀសពីការគេចវេសកាតព្វកិច្ចណាមួយចំពោះម្ចាស់បំណុល។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលអាចស្វែងរកអ្នកជំនាញ ដើម្បីស្រាវជ្រាវឱ្យបានដឹងច្បាស់ពីប្រវត្តិអចលនវត្ថុដែលខ្លួនមានបំណងក្នុងការរឹបអូសជាបណ្តោះអាសន្ន ជៀសវាងការរឹបអូសនោះប៉ះលើអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល។

**៣.២. អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ**

ករណីនេះ ក៏មិនខុសពីដំណោះស្រាយខាងលើចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់តតិយជនដែរ ដូច្នេះ ម្ចាស់បំណុល ត្រូវយកចិត្តទុកដាក់ក្នុងការស្វែងរកអំពីអត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន មុនពេលខ្លួនដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលត្រូវសើុបសួរពីប្រវត្តិដីធ្លីអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ដើម្បីបញ្ជាក់ឱ្យពីអត្តសញ្ញាណលើដីដែលជាកម្មវត្ថុនៃការរឹបអូសឱ្យបានច្បាស់លាស់ថា ជាដីកម្មសិទ្ធិរបស់កូនបំណុលឬយ៉ាងណា ជៀសវាងការរឹបអូសលើអចលនវត្ថុដែលមិនមែនជារបស់កូនបំណុល។ ទន្ទឹមនឹងនេះ អាជ្ញាធរមានសមត្ថកិច្ចគប្បីមានបង្កើនការផ្សព្វផ្សាយឱ្យបានច្រើនពីអត្តសញ្ញាណអចលនវត្ថុដែលជាកម្មសិទ្ធិរបស់រដ្ឋឱ្យបានទូលំទូលាយ ដើម្បីជៀសវាងបញ្ហាវិវាទផ្សេងៗពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់រដ្ឋ។ លើសពីនេះទៀត រដ្ឋត្រូវបង្កើនយន្តការចុះបញ្ជីលើក្បាលដីដែលមិនទាន់បានចុះបញ្ជី ដើម្បីបង្កើតភាពងាយស្រួល និងបង្កើនសុវត្ថិភាពជំនួញទាក់ទងនឹងដីធ្លី។

### កថាភាគទី៤. បន្ទុកសោហ៊ុយរបស់ម្ចាស់បំណុល

#### ៤.១. បង្កើតយន្តការក្នុងការកាត់បន្ថយចំណាយ និងការផ្តល់សេវាប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃ

ម្ចាស់បំណុល អាចស្វែងរកសេវាប្រឹក្សាសេវាផ្នែកច្បាប់ឥតគិតថ្លៃពីសំណាក់មេធាវីស្ម័គ្រចិត្តសម្តេចតេជោ ដើម្បីទទួលសេវាប្រឹក្សាយោបល់ និងតំណាងតាមផ្លូវច្បាប់ ប្រសិនបើម្ចាស់បំណុលពុំមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការស្វែងរកសេវាច្បាប់ពីសំណាក់មេធាវីឯកជន។ ទន្ទឹមនឹងនេះ ម្ចាស់បំណុលអាចស្វែងរកសេវាផ្នែកច្បាប់ផ្សេងទៀតពីសំណាក់មេធាវីដែលស្ម័គ្រចិត្តផ្តល់សេវាការពារក្តីដោយឥតគិតកម្រៃប្រចាំសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីខេត្ត ដើម្បីជួយសម្រាលបន្ទុកសោហ៊ុយសម្រាប់ម្ចាស់បំណុល។

លើសពីនេះទៅទៀត ដើម្បីកាត់បន្ថយការចំណាយសោហ៊ុយក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន រដ្ឋត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដែលចែងពីកម្រៃសេវាសាធារណៈក្នុងការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នឱ្យបានជាក់លាក់។ ទន្ទឹមនឹងនេះ ដើម្បីកាត់បន្ថយបន្ទុកសោហ៊ុយធ្វើដំណើររបស់ភាគី តុលាការមិនត្រូវធ្វើការកោះហៅសាកសួរភាគីជាច្រើនលើកជាច្រើនសារ និងមិនត្រូវពន្យាពេលក្នុងការសម្រេចសេចក្តីលើពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះឡើយ។

#### ៤.២. បង្កើតយន្តការគ្រប់គ្រងទិន្នន័យរបស់អចលនវត្ថុ

#### ៤.២.១. យន្តការគ្រប់គ្រងទិន្នន័យលើអចលនវត្ថុដែលបានចុះបញ្ជី

ដើម្បីសម្រួលដល់ម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនលើទ្រព្យសម្បត្តិរបស់កូនបំណុល ចាំបាច់ត្រូវបង្កើតយន្តការពិសេសមួយ ដែលទាមទារឱ្យក្រសួងមានសមត្ថកិច្ចគ្រប់គ្រងលើទិន្នន័យចំពោះអចលនវត្ថុដែលបានចុះបញ្ជីចូលរួមសហការ។ ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាក្រសួងមានសមត្ថកិច្ចលើអចលនវត្ថុដែលមានចុះបញ្ជី ត្រូវបង្កើតយន្តការតាមរយៈការបង្កើតលិខិតបទដ្ឋានគតិយុត្ត ដែលអនុញ្ញាតឱ្យម្ចាស់បំណុលអាចស្វែងរកទិន្នន័យពាក់ព័ន្ធនឹងអចលនវត្ថុរបស់កូនបំណុល ដោយគ្រាន់តែបង្ហាញនូវលិខិតបញ្ជាក់ពីសិទ្ធិលើបំណុលដែលត្រូវបានទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។ ការបង្កើតយន្តការនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងសម្រួលដល់ម្ចាស់បំណុលក្នុងការចំណាយស្វែងរកទ្រព្យសម្បត្តិរបស់កូនបំណុល និងបង្កើតកម្រៃសេវាសារធារណៈសម្រាប់ក្រសួងសាមីផងដែរ។

#### ៤.២.២. យន្តការគ្រប់គ្រងទិន្នន័យលើអចលនវត្ថុដែលមិនបានចុះបញ្ជី

នៅពេលបច្ចុប្បន្ននេះ ពុំមានស្ថាប័នផ្លូវការ ឬលិខិតបទដ្ឋានគតិយុត្តណាមួយសម្រាប់គ្រប់គ្រងទិន្នន័យអចលនវត្ថុដែលមិនបានចុះបញ្ជី ដែលជាមូលហេតុនាំឱ្យការពិបាកស្វែងរកអត្តសញ្ញាណម្ចាស់អចលនវត្ថុដែលមិនបានចុះបញ្ជីសម្រាប់ប្រមូលពន្ធលើអចលនវត្ថុខាងលើ និងគ្រប់គ្រងលើអត្តសញ្ញាណរបស់ម្ចាស់អចលនវត្ថុនោះឱ្យបានគ្រប់ជ្រុងជ្រោយ។ ដូច្នេះ រដ្ឋត្រូវបង្កើតស្ថាប័នផ្លូវការ និងលិខិតបទដ្ឋានគតិយុត្តមួយសម្រាប់គ្រប់គ្រងលើទិន្នន័យអចលនវត្ថុដែលមិនបានចុះបញ្ជី ដើម្បីធានាថាអចលនវត្ថុដែលមិនបានចុះបញ្ជីត្រូវបានគ្រប់គ្រងជ្រុងជ្រោយប្រកបដោយប្រសិទ្ធភាព។

**៤.៣. សោហ៊ុយអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជី**

ដើម្បីអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជីរបស់កូនបំណុល ម្ចាស់បំណុលត្រូវទទួលបន្ទុកសោហ៊ុយយ៉ាងធ្ងន់ធ្ងរ ដូច្នេះ ដើម្បីសម្រួលបន្ទុកសោហ៊ុយដល់ម្ចាស់បំណុលពាក់ព័ន្ធនឹងបញ្ហាការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជី រដ្ឋគប្បីមានការបង្កើតយន្តការណាមួយ តាមរយៈការតាក់តែងលិខិតបទគតិយុត្តដែលកំណត់អំពីសោហ៊ុយ និងរយៈពេលក្នុងការចុះបញ្ជីលើកដំបូងលើអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ន ដើម្បីអនុញ្ញាតឱ្យម្ចាស់បំណុលរៀបចំនូវសោហ៊ុយផ្សេងៗសម្រាប់ចំណាយក្នុងការមុនការចុះបញ្ជី។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាប្រធានបទស្តីពី **"ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ"** រួចមក យើងអាចសង្កេតបានថា ការរឹបអូសជាបណ្តោះអាសន្នមានចរិតលក្ខណៈពិសេសចំនួន ០៤ (បួន) ដូចជា លក្ខណៈបណ្តោះអាសន្ន លក្ខណៈបន្ទាន់បង្ខំ លក្ខណៈបន្ទាប់បន្សំ និងលក្ខណៈសម្ងាត់ ដែលលក្ខណៈពិសេសទាំងអស់នេះហើយបានធ្វើឱ្យនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នមានលក្ខណៈសម្បត្តិប្លែកខុសពីនីតិវិធីផ្សេងទៀត។ តុលាការអាចចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់កូនបំណុលបាន ទោះបីជាតុលាការនៃបណ្តឹងអង្គសេចក្តីមិនទាន់បានសម្រេចឱ្យច្បាស់លាស់ពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលក៏ដោយ ហើយថ្វីត្បិតបើការសម្រេចបែបនេះធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់កូនបំណុលពិតមែន។ ប៉ុន្តែ ផ្អែកតាមទស្សនៈម្ខាងទៀត គឺគ្រាន់តែដើម្បីការពារសិទ្ធិរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ បើមិនបានសិក្សាឱ្យស៊ីជម្រៅពីនីតិវិធីនេះ កូនបំណុលអាចនឹងមើលឃើញថាច្បាប់បានលំអៀងទៅកាន់ម្ចាស់បំណុល ជាក់ស្តែងមិនមានភាពលំអៀងណាមួយកើតឡើងក្នុងវិស័យច្បាប់នោះទេ ដោយហេតុថាការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុក៏បានបញ្ញត្តិពីហេតុដែលការពារកូនបំណុលពីការបាត់បង់ប្រយោជន៍ស្របច្បាប់ ដោយសារការអនុវត្តរឹបអូសជាបណ្តោះអាសន្នផងដែរ រួមមានការបង្គាប់ម្ចាស់បំណុលឱ្យដាក់ប្រាតិភោគ ការដាក់ប្រាក់រំដោះ ដែលសុទ្ធសឹងតែជាយន្តការប្រើប្រាស់ក្នុងគោលបំណងការពារកូនបំណុលឱ្យជៀសផុតពីការប្រើប្រាស់សិទ្ធិទាំងបំពានរបស់ម្ចាស់បំណុល។ មួយវិញទៀត ការដាក់ប្រាក់រំដោះមិនត្រឹមតែការពារប្រយោជន៍កូនបំណុលពីការរឹបអូសជាបណ្តោះអាសន្នទេ ប្រព័ន្ធនេះក៏បានធ្វើឱ្យម្ចាស់បំណុលស្ងប់ចិត្តថានឹងទទួលបានការសងនៅពេលឈ្នះបណ្តឹងអង្គសេចក្តីផងដែរ។

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នមិនចាំបាច់បំពេញលក្ខខណ្ឌដូចការអនុវត្តដោយបង្ខំនោះទេ ដោយការអនុវត្តការរឹបអូសជាបណ្តោះអាសន្នមិនត្រូវការរូបមន្តអនុវត្តទេ ហើយការអនុវត្តការរឹបអូសជាបណ្តោះអាសន្នអាចធ្វើទៅបានមុនពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវបញ្ជូនទៅដល់កូនបំណុល។ ការបញ្ញត្តិបែបនេះ ដើម្បីជៀសវាងការដឹងខ្លួនជាមុនរបស់កូនបំណុល ហើយធ្វើសកម្មភាពមួយចំនួនដូចជា ការចាត់ចែងអចលនវត្ថុនោះទៅតតិយជន ដែលនាំឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវប្រែក្លាយជាអស់ន័យ ហើយម្ចាស់បំណុលនឹងនៅតែខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួនដដែល។ សូមបញ្ជាក់ម្តងទៀតថា នីតិវិធីរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីបណ្តោះអាសន្នដើម្បីធានាឱ្យការអនុវត្តបង្ខំនាពេលអនាគតអាចធ្វើទៅបានដោយរលូន និងគ្មានឧបសគ្គមករារាំងនាពេលអនុវត្តតែប៉ុណ្ណោះ ហេតុនេះទើបយើងឃើញថានីតិវិធីរឹបអូសជាបណ្តោះអាសន្ន មានលក្ខណៈស្ទើរតែដូចគ្នានឹងនីតិវិធីអនុវត្តដោយបង្ខំទាំងទ្រឹស្តី និងការអនុវត្ត។ ជាការពិតណាស់នៅក្រោយពេលអនុវត្តរឹបអូសជាបណ្តោះអាសន្នចប់ ហើយលក្ខខណ្ឌនៃការអនុវត្តដោយបង្ខំត្រូវបាន

បំពេញនោះ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន ត្រូវបម្លែងទៅជាការអនុវត្តដោយបង្ខំវិញបានត្រឹមទំហំនៃការអនុវត្ត មានន័យថានីតិវិធីបន្ទាប់ គឺអាចអនុវត្តលក់ដោយបង្ខំតាមផ្លូវតុលាការយកតែម្តង ដោយមិនចាំបាច់ដើរនីតិវិធីអនុវត្តដោយបង្ខំសាជាថ្មីវិញនោះទេ។ ដូច្នេះ ប្រសិនបើម្ចាស់បំណុលជ្រើសរើសយកនីតិវិធីរឹបអូសជាបណ្តោះអាសន្នមកប្រើប្រាស់នោះ ម្ចាស់បំណុលរឹតតែចំណេញពេលវេលានៅពេលខ្លួនឈ្នះបណ្តឹងអង្គសេចក្តី ហើយធានាដល់ការអនុវត្តដោយបង្ខំនាពេលអនាគត។ ទន្ទឹមនឹងនេះ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន អាចត្រូវបានតុលាការសម្រេចឱ្យផ្អាក ឬលុបចោលតាមពាក្យសុំរបស់កូនបំណុលប្រសិនបើមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ដោយក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ញើកផ្តាក់ចុះបញ្ជីពីការរឹបអូសជាបណ្តោះអាសន្នទៅកាន់រដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចលុបចោលការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន។

នៅពេលតុលាការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននៅដំណាក់កាលដំបូងបំផុតកូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នទៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន បន្ទាប់ពីទទួលពាក្យសុំតវ៉ា តុលាការនឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន បន្ទាប់ពីបញ្ចប់នីតិវិធីតុលាការនឹងចេញដីកាសម្រេចអំពីពាក្យសុំតវ៉ា។ ក្នុងករណីភាគីមិនពេញចិត្តចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាភាគីអាចដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការនៃបណ្តឹងជំទាស់មិនខុសគ្នានោះទេ តុលាការនៃបណ្តឹងជំទាស់នឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសាកសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ហើយតុលាការនឹងចេញដីកាសម្រេចអំពីបណ្តឹងជំទាស់ ដែលមានអត្ថន័យទទួលស្គាល់ ផ្លាស់ប្តូរ ឬលុបចោល។ គួរបញ្ជាក់ដែរថាក្រៅពីការលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារដីកាសម្រេចអំពីពាក្យសុំតវ៉ា ឬដីកាសម្រេចអំពីបណ្តឹងជំទាស់ នៅមានមូលហេតុពីរទៀតដែលធ្វើឱ្យដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវបានលុបចោល រួមមាន ការលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារមិនដាក់បណ្តឹងអង្គសេចក្តី ជាអាទិ៍ ឬការលុបដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នដោយសារការផ្លាស់ប្តូរស្ថានភាព។

នៅក្នុងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ នៅមានបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធនឹងមន្ត្រីអនុវត្តច្បាប់ កង្វះលិខិតបទដ្ឋានគតិយុត្ត និងម្ចាស់បំណុលផងដែរ។ ហើយបញ្ហាទាំងនេះ ចាំបាច់ត្រូវមានការកែទម្រង់ដោយបានល្អ ទើបអាចអូសទាញបាននូវជំនឿទុកចិត្តរបស់ពលរដ្ឋមកលើមន្ត្រីមានសមត្ថកិច្ចរួមទាំងជំនឿទុកចិត្តមកលើស្ថាប័នតុលាការផងដែរ។ ក្នុងនាមជាជាអ្នកបម្រើសេវាយុត្តិធម៌ អាជ្ញាធរដែលពាក់ព័ន្ធត្រូវខិតខំប្រឹងប្រែង និងគប្បីជៀសវាងនូវការប្រើពាក្យសម្តី ឬអំពើណាមួយ ដែលនាំឱ្យមានការសង្ស័យអំពីភាពយុត្តិធម៌ ដូចសុភាសិតច្បាប់មួយឃ្លាពោលថា "យុត្តិធម៌យឺតយ៉ាវស្មើនឹងការបដិសេធនូវយុត្តិធម៌" ជាពាក្យ

សុភាសិតច្បាប់ដែលត្រូវបានទទួលស្គាល់ជាសកល។

សរុបសេចក្តីមក ថ្វីត្បិតតែនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្ន ជានីតិវិធីមានលក្ខណៈមិនមានភាពអចិន្ត្រៃយ៍ពិតមែន ប៉ុន្តែនីតិវិធីនេះបានផ្តល់មកវិញជាលទ្ធផលជាទីគាប់ចិត្ត ហើយមិនត្រូវការពេលវេលាយូរសម្រាប់អនុវត្តឡើយ ទោះបីជាលំហូរនីតិវិធីមានភាពលំបាក ប៉ុន្តែបើសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅនោះអ្នកអនុវត្តនឹងដឹងច្បាស់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់នីតិវិធីនេះ សម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងសង្គមរស់នៅបច្ចុប្បន្ន ហើយនីតិវិធីនេះពិតជាដើរតួយ៉ាងសំខាន់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ភាគី បើប្រើប្រាស់ឱ្យបានត្រឹមត្រូវស្របតាមអង្គហេតុ និងស្ថានភាពជាក់ស្តែងនីមួយៗ។ ក្នុងនាមជាអ្នកសិក្សាផ្នែកនីតិសាស្ត្រមួយរូប យើងគប្បីសិក្សាពីរបបគតិយុត្តឯកសារនីមួយៗឱ្យយល់ដឹងកាន់តែច្បាស់លាស់ជាមុនសិន មុននឹងប្រើប្រាស់ជាផ្លូវការដើម្បីជៀសវាងពីការបាត់បង់ ឬខូចខាតប្រយោជន៍ស្របច្បាប់របស់បុគ្គលណាម្នាក់ដោយសារប្រើប្រាស់មិនបានត្រឹមត្រូវ។

# អនុសាសន៍

# អនុសាសន៍

នីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនេះ គឺមានការលំបាកខ្លាំងណាស់ក្នុងការសម្រេចសេចក្ដីព្រោះក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា យើងត្រូវបានស្ថាបនា និងឧបត្ថម្ភដោយប្រទេសជប៉ុនដោយសារតែការអនុវត្តច្បាប់ត្រូវធ្វើឡើងតាមរបៀបអនុវត្តរបស់ប្រទេសជប៉ុន។ ហេតុនេះតម្រូវឱ្យអ្នកច្បាប់គ្រប់មជ្ឈដ្ឋានគួរតែស្វែងយល់ឱ្យបានស៊ីជម្រៅ ជាពិសេសអ្នកអនុវត្តច្បាប់ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន និងលើកស្ទួយវិស័យយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាយើង។ មួយវិញទៀត យើងខ្ញុំយល់ថាប្រជាពលរដ្ឋមួយចំនួនធំនៅមិនទាន់មានការយល់ដឹងទូលំទូលាយអំពីនីតិវិធីនៃការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនៅឡើយ ទោះបីមានក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដែលមានប្រកាសឱ្យប្រើអស់រយៈពេលជាង១០ ឆ្នាំក៏ដោយ។

ទន្ទឹមនឹងនេះ ឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ ពិតជាកត្តាកំណត់ដ៏សំខាន់មួយ ប៉ុន្តែការចង់ដឹង ចង់យល់ ចង់ចេះ គឺអាស្រ័យដោយបុគ្គលម្នាក់ៗ យោងទៅតាមឆន្ទៈរបស់បុគ្គលនោះ ពោលគឺចំណេះដឹងនូវបញ្ហាណាមួយក៏ចំណុះទៅតាមឆន្ទៈរបស់បុគ្គលនោះផងដែរ។ ចំណេះដឹងពិតប្រាកដមិនអាចកើតមានដោយងាយស្រួលនោះឡើយ ប្រសិនបើពុំមានការតស៊ូ ព្យាយាម អត់ធ្មត់ក្នុងការស្វែងយល់។ ដូច្នេះ ដើម្បីចូលរួមក្នុងការអនុវត្តដោយប្រសិទ្ធភាពនូវក្រមនីតិវិធីរដ្ឋប្បវេណីទាមទារឱ្យអ្នកអនុវត្តច្បាប់ត្រូវព្យាយាមធ្វើការសិក្សាជាប្រចាំដោយខ្លួនឯង រួមជាមួយនឹងការបណ្ដុះបណ្ដាលមកពីមជ្ឈដ្ឋានខាងក្រៅ ដើម្បីសន្សំនូវចំណេះដឹងទាំងនោះ។ អ្នកអនុវត្តច្បាប់ត្រូវមានជំនឿទុកចិត្តលើខ្លួនឯង ទើបអាចអូសទាញបាននូវជំនឿទុកចិត្តរបស់ពលរដ្ឋមកលើខ្លួនបាន រួមទាំងជំនឿទុកចិត្តលើស្ថាប័នតុលាការផងដែរ។

**ជាអនុសាសន៍៖**

ម្ចាស់បំណុល ប្រសិនបើដឹងថាខ្លួនមិនអាចដើរតួជាភាគីរហូតដល់ចប់ចុងចប់ដើមទេ ម្ចាស់បំណុលគួរតែជ្រើសតាំងអ្នកតំណាងឱ្យខ្លួនជាមុនកុំឱ្យមានការលំបាកនៅពេលអនុវត្តការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ពីព្រោះបើសិនជាអ្នកអនុវត្តមិនមែនជាភាគីទេ នោះការអនុវត្តការរឹបអូសជាបណ្ដោះអាសន្នត្រូវការយ៉ាងចាំបាច់នូវឯកសារចម្លងយថាភូត ហើយត្រូវមានភ្ជាប់មកជាមួយនូវរូបមន្តអនុវត្តទៀត នោះហើយវាជាលំបាក។ មួយវិញទៀត ប្រសិនបើម្ចាស់បំណុលពុំមានចំណេះដឹងផ្នែកច្បាប់ ម្ចាស់បំណុលអាចប្រើប្រាស់សិទ្ធិតំណាងដោយអាណត្តិតាមរយៈអ្នកតំណាងអាណត្តិរបស់ខ្លួន។ ជាគោលការណ៍ បុគ្គលដែលមានលក្ខណៈសម្បត្តិជាអ្នកតំណាងដោយអាណត្តិ ត្រូវតែជាមេធាវី។

ម្ចាស់បំណុល គប្បីប្រញាប់ប្រញាល់ក្នុងការដាក់ពាក្យសុំរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុក្នុងករណីដែលខ្លួនបានដឹងពីចេតនាទុច្ចរិតរបស់កូនបំណុល ហើយក្នុងករណីដែលខ្លួនមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដើម្បីការពារផលប្រយោជន៍

ស្របច្បាប់របស់ខ្លួន និងដើម្បីបង្ការទុកពីហានិភ័យដែលកើតឡើងដោយថាហេតុដោយចេតនាទុច្ចរិតរបស់កូនបំណុលក្នុងការគេចវេសពីការទទួលខុសត្រូវចំពោះម្ចាស់បំណុល។

ក្រសួងយុត្តិធម៌គួរតែធ្វើសិក្ខាសាលាឱ្យបានញឹកញាប់ ដើម្បីឱ្យអ្នកច្បាប់ និងប្រជាពលរដ្ឋគ្រប់រូបយល់កាន់តែច្បាស់អំពីនីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ឬការចាត់ចែងរក្សាការពារនេះ។ អ្នកច្បាប់គ្រប់រូបគួរតែគោរពច្បាប់ និងប្រកាន់នូវសីលធម៌។ ជាពិសេស គឺអ្នកអនុវត្តច្បាប់ដែលគួរធ្វើបែបនេះ ដើម្បីធានាឱ្យបាននូវអនាគតិនៅពេលខ្លួនកំពុងអនុវត្តច្បាប់។ ប្រការសំខាន់មួយទៀត ដើម្បីបង្កើតការយល់ដឹងសម្រាប់អ្នកអនុវត្តច្បាប់ និងប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គឺជាការបន្តផ្សព្វផ្សាយ និងបណ្តុះបណ្តាលផ្សេងៗសម្រាប់អ្នកអនុវត្តច្បាប់ដូចជាចៅក្រម ក្រឡាបញ្ជី និងមេធាវីឱ្យបានយល់ច្បាស់ស៊ីជម្រៅ និងអនុវត្តឱ្យបានត្រឹមត្រូវ និងមានភាពរស់រវើកនូវបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ កម្មវិធីនៃការផ្សព្វផ្សាយត្រូវតែរៀបចំឱ្យមានពេលវេលាសមរម្យ និងជាញឹកញាប់ ដើម្បីធានាឱ្យបាននិរន្តរភាពនៃការងារចៅក្រម មេធាវីផង និងប្រសិទ្ធភាពនៃការផ្សព្វផ្សាយបណ្តុះបណ្តាលផងដែរ។

ចំនួនប្រាតិភោគ និងចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន អ្នកធ្វើច្បាប់គួរធ្វើបន្ថែមនូវមាត្រាដែលកំណត់អំពីចំនួនប្រាតិភោគ និងចំនួនប្រាក់រំដោះ ដោយសារតែបើតុលាការមានការធ្វេសប្រហែសនោះវានឹងនាំឱ្យមានការពិបាកដល់គូភាគីជាក់ជាពុំខាននៅពេលនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់។

តុលាការគប្បីត្រូវយកចិត្តទុកដាក់ នៅក្នុងការបញ្ជូនដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ននេះទៅឱ្យភាគី ដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនដីកាសម្រេចនោះ អាចរកមធ្យោបាយការពារខ្លួន និងដាក់ភស្តុតាងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនបានទាន់ពេលវេលា។ ចៅក្រមដែលជាអ្នកសម្រេចសេចក្តីត្រូវតែធ្វើការសម្រេចសេចក្តីត្រូវពិនិត្យមើលលក្ខខណ្ឌចាំបាច់នានាសម្រាប់ការចេញដីកាសម្រេច និងពិចារណា។ មុនធ្វើការសម្រេចសេចក្តី ចៅក្រមត្រូវយកចំណេះដឹង និងសមត្ថភាពដែលខ្លួនមានយកមកប្រើឱ្យអស់លទ្ធភាព។ ចៅក្រមមិនត្រូវសម្រេចសេចក្តីដោយអគតិទាំងបួន គឺភ័យាគតិ ឆន្ទាគតិ មោហាគតិ និង ទោសាគតិ និងប្រកាន់ខ្ជាប់នូវសុគតិធម៌ទាំងប្រាំមានដូចជាវិរិយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ និងបញ្ញាវុឌ្ឍិនិច្ឆ័យ៕

# សន្ទានុក្រម

# សន្ទានុក្រម

“ក”

**ការចាត់ចែងរក្សាការពារ**
គឺជាវិធានការដែលតុលាការចាត់ចែងបណ្ដោះអាសន្នតាមពាក្យសុំរបស់បុគ្គលណាមួយ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលនោះ។ ការចាត់ចែងរក្សាការពារមានបីប្រភេទ គឺ ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈ(ស្ថានភាព)ជាបណ្ដោះអាសន្ន។

**ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី**
គឺជាការប្រគល់ភារកិច្ច និងការតម្រូវឱ្យចុះបញ្ជី។

“ឆ”

**ឆន្ទានុសិទ្ធិ**
១-អំណាចដែលច្បាប់ប្រគល់ដល់ចៅក្រមឱ្យរើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួនមកដោះស្រាយបញ្ហាណាមួយ។
២-អំណាចរបស់ចៅក្រមក្នុងការធ្វើសកម្មភាពក្នុងនីតិវិធីនៃបណ្ដឹងដោយមិនបាច់មានពាក្យសុំរបស់ភាគី។

“ដ”

**ដីកាសម្រេច**
គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនមែនជាសាលក្រមទេ។

“ត”

**តុលាការមានសមត្ថកិច្ច**
គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹងវិនិច្ឆ័យសេចក្ដីលើរឿងក្ដី ហើយចេញសាលក្រម ឬសាលដីកាបាន។

“ប”

**បណ្ដឹងជំទាស់**
គឺជាបណ្ដឹងឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ (ដែលជា តុលាការនៃបណ្ដឹងជំទាស់) ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្ដូរដីកាសម្រេចដើម។

**បណ្ដឹងអង្គសេចក្ដី**
គឺជាពាក្យទាមទាររបស់ភាគីណាមួយ ដើម្បីឱ្យតុលាការសម្រេចសេចក្ដីលើអង្គសេចក្ដី។

| | |
|---|---|
| **ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ** | គឺជាប្រាក់ប្រដាប់ក្តីមួយប្រភេទ ដែលភាគីត្រូវបង់នូវចំនួនចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង បញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងៗ តាមនីតិវិធីក្នុងបណ្តឹង។ |

"**ព**"

| | |
|---|---|
| **ពន្ធដាក់ពាក្យសុំ** | គឺជាប្រាក់ប្រដាប់ក្តីមួយប្រភេទដែលត្រូវបង់នៅពេលដាក់បណ្តឹងទៅតុលាការ។ |

"**ម**"

| | |
|---|---|
| **មូលប្បទានបត្រ** | គឺជាមូលបត្រជួញដូរបានមួយប្រភេទដែលតាមនោះបហារ៉ក (អ្នកចេញបញ្ជា) ចុះហត្ថលេខាបញ្ជាដោយឥតលក្ខខណ្ឌទៅធនាគារ (បហារិត) ឱ្យផ្តល់ទឹកប្រាក់ជាក់លាក់មួយចំនួនទៅកាន់មូលបត្រនោះ។ |
| **ម្ចាស់បំណុល** | គឺជាបុគ្គលដែលមានសិទ្ធិឥណទេយ្យ (សិទ្ធិលើបំណុល)។ |

"**ល**"

| | |
|---|---|
| **លំនៅឋាន** | គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ៗ។ |

"**ស**"

| | |
|---|---|
| **សមត្ថកិច្ចផ្តាច់មុខ** | គឺជាអំណាចដែលផ្តល់ឱ្យតុលាការណាមួយជាកំណត់ក្នុងការទទួលបណ្តឹង វិនិច្ឆ័យរឿងក្តីចេញសាលក្រម ឬសាលដីកា។ |
| **សិទ្ធិតំណាងដោយអាណត្តិ** | គឺជាសិទ្ធិរបស់អ្នកតំណាងដែលទទួលបានតាមកិច្ចសន្យាអាណត្តិ ដើម្បីធ្វើសកម្មភាពក្នុងនីតិវិធីចំពោះមុខតុលាការក្នុងនាមជាម្ចាស់សិទ្ធិ។ |
| **សិទ្ធិលើបំណុល** | គឺជាសិទ្ធិទាមទាររបស់បុគ្គលម្នាក់ (ម្ចាស់បំណុល) ចំពោះបុគ្គលម្នាក់ទៀត (កូនបំណុល) ឱ្យផ្តល់នូវតាវកាលិកអ្វីមួយ។ |

"**អ**"

| | |
|---|---|
| **អង្គសេចក្តី** | គឺជាខ្លឹមសារជាមូលដ្ឋាននៃកម្មវត្ថុរបស់បណ្តឹងរដ្ឋប្បវេណី។ |
| **អចលនវត្ថុ** | គឺជាដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ។ល។ សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់បានកំណត់ថាជាអចលនវត្ថុ។ |
| **អ្នកតំណាងដោយអាណត្តិ** | គឺជាអ្នកដែលទទួលសិទ្ធិតំណាងដោយអាណត្តិ។ |

# គន្លនិខ្មេស

# គន្ថនិទ្ទេស

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណី, លេខនស/ រកម/១២០៧/០៣១, ០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦។
- ច្បាប់ភូមិបាល, លេខនស/រកម/០៨០១/១៤, ៣០ សីហា ២០០១។
- ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ ប្រក.ដនស/១១, ០៣ ឧសភា ២០១១។
- ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២១៤ ប្រក.ដនស, ២១ វិច្ឆិកា ២០១៤។
- សារាចររបស់ក្រសួងយុត្តិធម៌ស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី, លេខ០៤សរាចរ៨៤, ០៨ កញ្ញា ១៩៨៤។

## ២. ឯកសារផ្សេងទៀត

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី. គន្លឹទី៧. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៧។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ២, ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភាគ១, នីតិវិធីបណ្តឹង. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០។
- អ៊ី ម៉ាណូកា, ការចុះបញ្ជីរឹបអូសអចលនវត្ថុក្នុងនីតិវិធីអនុវត្តដោយបង្ខំ. ភ្នំពេញ៖ សមាគមសាលាត្រាជូ, ២០១៦។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ ៖ | ពាក្យសុំចេញដីកាសម្រេចរក្សាការពារ |
| ឧបសម្ព័ន្ធទី២ ៖ | លិខិតតំណាងដោយអាណត្តិ |
| ឧបសម្ព័ន្ធទី៣ ៖ | លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ |
| ឧបសម្ព័ន្ធទី៤ ៖ | ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ចំនួន ០៣ (បី) ច្បាប់ |
| ឧបសម្ព័ន្ធទី៥ ៖ | ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារ |
| ឧបសម្ព័ន្ធទី៦ ៖ | លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី៧ ៖ | គំរូលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី៨ ៖ | គំរូលិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន |
| ឧបសម្ព័ន្ធទី៩ ៖ | ដីកាបញ្ជូនចំនួន ០១ (មួយ) ច្បាប់ |
| ឧបសម្ព័ន្ធទ១០ ៖ | បង្កាន់ដៃទទួលពាក្យរដ្ឋបាលខេត្តសៀមរាប |
| ឧបសម្ព័ន្ធទី១១ ៖ | ក្រមនីតិរដ្ឋប្បវេណី គន្ថីទី៧ ការចាត់ចែងរក្សាការពារ |
| ឧបសម្ព័ន្ធទី១២ ៖ | ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជី លេខ២១៤ ប្រក.ដនស ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃទី......ខែ......ឆ្នាំ......

## ពាក្យសុំចេញដីកាសម្រេចរក្សាការពារ

**ម្ចាស់បំណុល៖** ឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ មានទីលំនៅបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**មេធាវីតំណាងដោយអាណត្តិ៖** កញ្ញាមេធាវី អត្តលេខ ក្រុមមេធាវី ដែលមានទីតាំងការិយាល័យអគារលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**សហកូនបំណុល៖** លោក ភេទ កាន់អត្តសញ្ញាណប័ណ្ណលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងប្រពន្ធ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

លោក ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ចុះថ្ងៃទី ខែ ឆ្នាំ និងប្រពន្ធ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

សាលាដំបូងរាជធានីភ្នំពេញ
ចេញ
ថ្ងៃទី......ខែ......ឆ្នាំ......

### សូមគោរពជូន

### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក. ខ្លឹមសារនៃដីកាសម្រេចរក្សាការពារឲ្យតុលាការចេញ**

ស្នើសុំតុលាការចេញដីកាសម្រេចរក្សាការពារ រឹបអូសជាបណ្ដោះអាសន្ន៖

១. រឹបអូសជាបណ្ដោះអាសន្ន និងហាមឃាត់សហកូនបំណុលមិនឱ្យធ្វើការលក់-ដូរ ផ្ទេរ ជួល បញ្ចាំ ធ្វើអច្ច័យទាន-អំណោយ ឬប្រទានកម្ម និងធ្វើឲ្យខូចខាតតម្លៃជាបណ្ដោះអាសន្ននូវអចលនវត្ថុដូចខាងក្រោម៖

ក. អចលនវត្ថុ មានទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្បាលដីលេខ ទំហំ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ។

ខ. អចលនវត្ថុ មានទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្បាលដីលេខ ទំហំ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ។

គ. អចលនវត្ថុ មានទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្បាលដីលេខ ទំហំ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ។

ឃ. អចលនវត្ថុ មានទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្បាលដីលេខ ទំហំ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចេញដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ឈ្មោះ និង ឈ្មោះ ។

ង. អចលនវត្ថុ មានទីតាំងស្ថិតនៅ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្បាលដីលេខ ទំហំ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចេញដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ឈ្មោះ និង ឈ្មោះ ។

២. ដើម្បីទទួលបាននូវការលុបចោលការអនុវត្តវិធានការអភិរក្សជាបណ្តោះអាសន្ន សហកូនបំណុលត្រូវធ្វើប្រាក់រំដោះនៅតុលាការចំនួន USD ( ដុល្លារអាមេរិក) ។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហកូនបំណុល ។

## **ខ. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ**

1. លោក និងលោក ជាអគ្គនាយក ក្រុមហ៊ុន រួមមានបុរី និងបុរី ដែលមានតម្រូវការសាងសង់បុកគ្រឹះផ្ទះនៅបុរីរបស់ខ្លួន ហើយ លោក និងលោក បានព្រមព្រៀងគ្នាជាមួយលោក ជាអ្នកតំណាងឱ្យក្រុមហ៊ុន មានអាសយដ្ឋានស្ថិតនៅដីឡូលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ បានធ្វើការបុកគ្រឹះផ្ទះបុរី និងបុរី ។ បន្ទាប់ពីលោក បានធ្វើការបុកគ្រឹះផ្ទះខាងលើ ជូន លោក និងលោក រួចហើយ ប៉ុន្តែអ្នកទាំងពីរ មិនទាន់បានបង់ប្រាក់ថ្លៃបុកគ្រឹះតាមការសន្យាជូនលោក នោះឡើយ ។
2. លុះដល់ ខែ ឆ្នាំ លោក និងលោក ជាអគ្គនាយក បានចុះកិច្ចសន្យាសងប្រាក់ថ្លៃបុកគ្រឹះផ្ទះក្នុង បុរី និងបុរី ដែលបានជំពាក់មានទឹកប្រាក់សរុបចំនួន USD ( ដុល្លារអាមេរិក) ជូនលោក ។
3. បន្ទាប់ពីចុះកិច្ចសន្យាលោក និងប្រពន្ធ និងលោក និងប្រពន្ធ បានធ្វើការសងប្រាក់ជាបន្តបន្ទាប់ ហើយប្រពន្ធ របស់លោក លោក និង ប្រពន្ធ របស់លោក បានធ្វើការព្យាយាមដោះស្រាយទូទាត់ប្រាក់ថ្លៃបុកគ្រឹះផ្ទះក្នុង បុរី និងបុរី ដែលនៅសល់មានចំនួន USD ( ដុល្លារអាមេរិក) ដោយបានសន្យាសងថ្ងៃនេះថ្ងៃនោះ ជូនលោក ប៉ុន្តែជាក់ស្តែង ប្រពន្ធ របស់លោក និង ប្រពន្ធ របស់លោក មិនអនុវត្តកាតព្វកិច្ចតាមសន្យារបស់ខ្លួនឡើយ ដូច្នេះទើបលោក បានទៅដល់ក្រុមហ៊ុន ផ្ទាល់តែម្តង ហើយប្រពន្ធរបស់លោក លោក និង ប្រពន្ធ របស់លោក ក៏បានចេញមុខចរចារ និង ដោះស្រាយបំណុលដែលបានជំពាក់ថ្លៃបុកគ្រឹះផ្ទះនេះ។
4. ដើម្បីដល់ជាទំនុកចិត្ត លោក និង លោក បានចេញមូលប្បទានបត្រចំនួន ០៣ (បី) សន្លឹក ដែលមានទឹកប្រាក់សរុប USD ( ដុល្លារអាមេរិក) សម្រាប់ទូទាត់ថ្លៃបុកគ្រឹះផ្ទះ រួមមាន៖ លើកទី០១ មូលប្បទានបត្រលេខ របស់ធនាគារ ស្ថាបនា (SATHAPANA BANK) ចុះថ្ងៃទី ដែលមានទឹកប្រាក់ចំនួន USD ( ដុល្លារអាមេរិក) លើកទី០២ មូលប្បទានបត្រលេខ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK Plc.) ចុះថ្ងៃទី ដែលមានទឹកប្រាក់ចំនួន USD ( ដុល្លារអាមេរិក)

និងលើកទី០៣ មូលប្បទានបត្រលេខ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK Plc.) ចុះថ្ងៃទី ដែលមានទឹកប្រាក់ចំនួន USD ( ហាសិបដុល្លាអាមេរិក) ជូនលោក ។

